# ឯកសារស្តីពីមតិយោបល់របស់អង្គការមិនមែនរដ្ឋាភិបាល
# ដែលធ្វើការតាមវិស័យនៅលើសេចក្តីព្រាងលើកទីមួយ
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣

ចងក្រងដោយៈ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

កុម្ភៈ ២០១០

# មាតិកា

ទំព័រ


១. កំណែទម្រង់ដីធ្លី ........ ៣
២. កំណែទម្រង់ ព្រៃឈើ ........ ២១
៣. វិស័យកសិកម្ម ........ ២៥
៤. វិស័យនេសាទ ........ ២៨
៥. ធនធានរ៉ែ និងផលប៉ះពាល់សង្គម និងបរិស្ថានពីឧស្សាហកម្មនិស្សារណៈកម្ម ........ ៣៣
៦. ការគ្រប់គ្រងចំណូលឧស្សាហកម្មនិស្សារណៈកម្ម ........ ៤០
៧. សិទ្ធិទទួលព័ត៌មាន ........ ៤៤
៨. អភិបាលកិច្ចល្អ ក្នុងផ្នែកការប្រឆាំងអំពើពុករលួយ ........ ៤៧
៩. សិទ្ធិកុមារ ........ ៥១
១០. កិច្ចអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី និងវិស័យថាមពល ........ ៥៦
១១. កាការពារបរិស្ថាន អភិរក្ស និងការប្រែប្រួលអាកាសធាតុ ........ ៦៧
១២. ប្រសិទ្ធិភាពជំនួយ ........ ៧៨
១៣. ការដាក់បញ្ចូលពិការភាព ........ ៨០
១៤. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការវិភាជន៍ថវិកាជាតិ ........ ១០០
១៥. ការដាក់បញ្ចូលសមិទ្ធផល គោលដៅ និងសកម្មភាពសំខាន់ៗរបស់អាជ្ញាធរសវកម្មជាតិ ........ ១០៣
១៦. ការដាក់បញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ........ ១០៥
១៧. វិស័យអប់រំ ........ ១១១

**កំណែទម្រង់ដីធ្លី**

| លេខទំព័រ* | លេខកថាខ័ណ្ឌ** | អត្ថបទដើមដកស្រង់ពីសេចក្តីព្រាងលើកទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ | យោបល់អង្គការមិនមែនរដ្ឋាភិបាល ឬការស្នើឱ្យមានការកែប្រែ |
|---|---|---|---|
| ៥៤ | ១០៤ | រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថាកំណែទម្រង់ដីធ្លីមានសារៈសំខាន់ណាស់សម្រាប់ការលើកកម្ពស់ស្ថិរ ភាពសង្គម ការអភិវឌ្ឍទីផ្សារដីធ្លីប្រកបដោយប្រសិទ្ធភាពចីរភាពបរិស្ថាន និងសម្រាប់ ការបង្កើនផលិតកម្ម កសិកកម្មតាមរយៈការផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ពិសេសជូនដល់ប្រជា កសិករដែលកំពុងធ្វើការដាំដុះលើដីធ្លីដែលពួកគាត់កំពុងកាន់កាប់។ ការផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជា ពលរដ្ឋមានសារៈសំខាន់ណាស់សម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង ការប្រើប្រាស់ដីជាពិសេសការគ្រប់គ្រងដីកម្មសិទ្ធិរដ្ឋដើម្បីធានាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី តាមរូបភាពមួយដែលមានតម្លាភាពនិងសមធម៌ព្រមទាំងដើម្បីបន្តកាត់បន្ថយភាពក្រីក្រ ដោយជួយឱ្យប្រជាពលរដ្ឋអាច មានលទ្ធភាពប្រើប្រាស់ទីផ្សារហិរញ្ញវត្ថុ ដោយប្រើប្រាស់ប័ណ្ណកម្មសិទ្ធិជាវត្ថុបញ្ចាំក្នុងការខ្ចីបុល។ តាមការប៉ាន់ស្មាននៅក្នុងឆ្នាំ ២០០១ ក្បាលដីប្រមាណ ពី ៦ ទៅ ៧លាននៅទូទាំងប្រទេសត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិឱ្យ។ | - ចំនួនតួលេខ ដែលបង្ហាញពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីប្រមាណពី ៦ទៅ ៧លានក្បាលដី នៅទូទាំងប្រទេសជូនប្រជាពលរដ្ឋនៅក្នុង ឆ្នាំ២០០១ ជាចំនួនដែលមិនសមាមាត្រទៅនឹងចំនួនប្រជាពលរដ្ឋ ដែលមាននៅពេលនោះហើយយន្តការសំរាប់ការចុះបញ្ជី ក៏នៅ មិនទាន់មានដំណើរការល្អដែលនឹងអាចមានលទ្ធភាពធ្វើការចុះបញ្ជីបានដូចក្នុងចំនួនដែលបានលើកឡើងនេះដែរ។ |
| ៥៥ | ១០៦ | សមិទ្ធផលធំៗជាច្រើន ត្រូវធ្វើឱ្យសម្រេចបាននៅក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។ ប័ណ្ណចំនួន ១.៦៦៤.២៩៧ ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋ ក្នុងនោះមាន ៣/៤ ជាដីនៅតំបន់ជនបទ និង ១/៤ ជាដីតំបន់ទីក្រុងទីប្រជុំជន ហើយប័ណ្ណកម្មសិទ្ធិដីធ្លីចំនួន ១.០៧០.៦៦៥ ត្រូវបានផ្តល់តាមរយៈការចុះ<br>បញ្ជីមានលក្ខណៈជាប្រព័ន្ធ និង ៥៩៣.៦៤៥ ប័ណ្ណ តាមរយៈការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ពោលគឺប្រមាណ ២៣ភាគរយ ទៅ ២៤ភាគរយ នៃចំនួនក្បាលដីសរុបទូទាំងប្រទេសដែលមាន ប្រមាណ ៦- | - តាមការសង្កេតកន្លងមកឃើញថា ការចុះបញ្ជីដីធ្លីធ្វើឡើងនៅតាមតំបន់ជនបទច្រើនជាងទីក្រុង (៣/៤ នៅតំបន់ជន បទ និង ១/៤ តំបន់ទីក្រុងទីប្រជុំជន) ដែលសុទ្ធតែជាដី កសិកម្មរបស់ប្រជាកសិករ និងគ្មានទំនាស់ដែលធ្វើអោយការចុះបញ្ជីប្រព្រឹត្តទៅបានដោយងាយ។<br>- សូមពន្លឿនការចុះបញ្ជីដីនៅតាមតំបន់ទីក្រុង ឬទីប្រជុំជនអោយបានឆាប់រហ័សថែមទៀត និងអោយបានច្រើនជាងនៅទីជនបទនៅក្នុងផែនការប្រចាំឆ្នាំរបស់ក្រសួងរៀបចំ ដែនដីដើម្បី |

| | | | |
|---|---|---|---|
| | | ៧លានក្បាលដី។ ចំណុចដៅ ដែលបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ កម្ពុជាសម្រាប់ឆ្នាំ២០១០ គឺការចុះបញ្ជីដីឱ្យបាន ៣២ភាគរយ នៃចំនួនក្បាលដីសរុបទូទាំង ប្រទេស ដែលក្នុងនោះ ២៤ភាគរយជាដីដែលត្រូវកាន់កាប់ដោយប្រជាកសិករ ។ ចំណុចដៅរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ កម្ពុជាសម្រាប់ឆ្នាំ២០១៥គឺការចុះបញ្ជីដីឱ្យបាន៦៥ភាគរយ នៃចំនួនក្បាល ដីសរុបទូទាំងប្រទេស ដែលក្នុងនោះ ៤៨,៧៥ភាគរយ ជាដីដែលត្រូវកាន់កាប់ដោយប្រជាកសិករ ។<br>ក្នុងចំណោមប័ណ្ណកម្មសិទ្ធិដីធ្លីដែលបានផ្តល់ជូនរហូតមកដល់បច្ចុប្បន្ននេះគឺមាន៧០ភាគរយជាប្រភេទ ទ្រព្យរួមប្តីប្រពន្ធ ២០ ភាគរយ ជាទ្រព្យ ផ្ទាល់របស់ស្ត្រី ៥ភាគរយជាទ្រព្យផ្ទាល់របស់បុរស និង ៥ភាគរយផ្សេងទៀតជាទ្រព្យផ្ទាល់របស់ទីអារាម ។ | កាត់បន្ថយទំនាស់ដីធ្លី ដែលជាបញ្ហាក្តៅនាពេលបច្ចុប្បន្ន និង ដើម្បីអោយប្រជាពលរដ្ឋអាចប្រើប្រាស់ប័ណ្ណ កម្មសិទ្ធិទាំងនោះជាប្រយោជន៍នៅក្នុងការប្រកបរបរពាណិជ្ជកម្មផ្សេងៗបាន ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ។ |
| ៥៦ | ១១០ | ដើម្បីពង្រឹង ការរៀបចំដែនដីដំណើរការកសាងក្របខណ្ឌគោលនយោបាយនិងគតិយុត្តពាក់ព័ន្ធនឹងវិស័យនេះដូចជាគោលនយោបាយរៀបចំដែនដីគោលនយោបាយជាតិស្តីពីលំនៅឋាន សារាចរណែនាំ ស្តីពីនិតិវិធីដោះស្រាយសំណង់បណ្តោះអាសន្នក្នុងទីក្រុង ឬទីប្រជុំជននិងច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងតែប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌក្រុមការងារអន្តរក្រសួង។ លើទិដ្ឋភាព បច្ចេកទេសនៃដំណើរការកសាងផែនទីប្រើប្រាស់ដីធ្លីរបស់ក្រុងទីប្រជុំជន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បាននិងកំពុងបន្តផ្តល់ការគាំទ្រ បច្ចេកទេសដល់អាជ្ញាធររដ្ឋបាល ក្រុងស្រុកខណ្ឌរាជធានីខេត្ត ដើម្បីពិគ្រោះយោបល់ផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបានសម្រាប់ ផែនការប្រើប្រាស់ដីធ្លី ទីក្រុង និងប្រជុំជនកំពុងដំណើរការប្រមូលនិងវិភាគទិន្នន័យនៅក្នុងខេត្ត ចំនួន១០។ ជាលទ្ធផល | - នៅក្នុងដំណើរការរៀបចំប្លង់គោល រាជធានី ស្រុក ខណ្ឌ និងការកសាងក្របខណ្ឌគោលនយោបាយ និងគតិយុត្តពាក់ ព័ន្ធនឹងវិស័យនេះសូមអោយមានការចូលរួមពិគ្រោះយោបល់ជាសាធារណៈពីសំណាក់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ក៏ដូចជាអ្នកពាក់ព័ន្ធផ្សេងៗទៀត និងសូមធ្វើការផ្សព្វផ្សាយ អំពីការងារទាំងអស់នេះជាសាធារណៈ ដើម្បីបង្ហាញពីតម្លាភាព និងសមធម៌ នៅក្នុងការគ្រប់គ្រងនិងរៀបចំដែនដី។ |

| | | | |
|---|---|---|---|
| | | ក្រុងស្ទឹងហាវ និងក្រុងបាវិត បានបញ្ចប់ជាស្ថាពរ និងឈានទៅធ្វើការបញ្ចប់ ផែនការប្រើប្រាស់ដីទីក្រុង និងទីប្រជុំជនចំនួនបីបន្ថែមទៀត គឺ ក្រុងក្រចេះ ក្រុងអ្នកលឿងនិងក្រុងអន្លង់វែង។ បន្ថែមពីលើផែនការប្រើប្រាស់ដីទីក្រុង នៅមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រាជធានីភ្នំពេញនិងខេត្តមួយចំនួនទៀត ដែលមានសក្ដានុពលទីផ្សារដីនិងសំណង់ក៏បាននិងកំពុងតែសហការរៀបចំផងដែរ ដូចជា ប្លង់គោលខេត្ត ព្រះសីហនុ ខេត្តកែប ខេត្តកំពង់ចាម ។ | |
| ៥៧ | ១១១ | រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តគោលនយោបាយបែងចែកដីដល់ប្រជាជនគ្មាននិងឬខ្វះដីតាមរយៈ កម្មវិធីផ្ដល់ដីសម្បទានសង្គមកិច្ច។ ដោយឡែកការបែងចែកដី ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ ដែលបានចែងនៅក្នុងផែនការអភិវឌ្ឍនយុទ្ធសាស្ត្រជាតិ (ផយអជ) ២០០៦-២០១០ បានកំណត់ផ្ដល់ដីឱ្យបានចំនួន១០.០០០ គ្រួសារដែលគ្មាននិងឬខ្វះដី។ ដើម្បីឈានទៅសម្រេចបានចំណុចដៅ ដែលមានចែងនៅក្នុង ផយអជ រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរណែនាំនូវការបែងចែកផែន ការសម្បទានដីសង្គមកិច្ចដោយកំណត់ រាជធានី ខេត្ត នីមួយៗ ត្រូវរកដីដើម្បីធ្វើផែនការអនុវត្តឱ្យ បានចំនួន ៤១៦ គ្រួសារ យ៉ាងតិចចាប់ពីឆ្នាំ ២០០៩។ រាជរដ្ឋាភិបាលបាន និងកំពុងជំរុញញដំណើរ ការធ្វើអត្តសញ្ញាណ និងចំណាត់ថ្នាក់ដីរដ្ឋ លើផ្ទៃដីសរុបប្រមាណ ៣៦.៩១៧ ហិកតា នៅក្នុងខេត្ត ចំនួន ១២ ខេត្ត សម្រាប់ធ្វើការបែងចែកដីដល់ ១៤.៧៩១ គ្រួសារ ក្រីក្រដែល គ្មានដី ដែលក្នុងនោះ :<br>• បែងចែកដី ៤.៧០០ហិកតា ដល់គ្រួសារចំនួន ៧៨៣គ្រួសារ តាមរយៈរូបភាពសម្បទាន ដីសង្គមកិច្ចនៃ គម្រោងបែងចែកដីសង្គមកិច្ច | - ការបែងចែកដីសម្បទានសង្គមកិច្ចខ្លះ កន្លងមកមិនបានធ្វើ ការចុះពិនិត្យទីតាំង និងព្រំប្រទល់អោយបានច្បាស់លាស់ទេ ដែលធ្វើអោយមានការត្រួតស៊ីគ្នាជាមួយនឹងដីសម្បទាន សេដ្ឋកិច្ចរបស់ក្រុមហ៊ុនឯកជនមួយចំនួនឬត្រួតស៊ីគ្នាលើដីដែលកាន់កាប់ដោយប្រជាពលរដ្ឋមូលដ្ឋានដែលធ្វើអោយប្រជាពលរដ្ឋទាំងនោះទទួលរងនូវការបណ្ដេញចេញ និងមានបញ្ហាទំនាស់ដីធ្លីកើតឡើង។<br>- ការធ្វើសម្បទានដីកន្លងមក មិនបានរៀបចំអោយមានហេដ្ឋា រចនាសម្ព័ន្ធមូលដ្ឋាន ដូចជា ផ្លូវ សាលារៀន មណ្ឌលសុខភាព បង្គន់អនាម័យ និងអណ្ដូងទឹកជាដើម ដល់ប្រជាពលរដ្ឋដែលនឹងត្រូវផ្លាស់ទៅរស់នៅទីនោះឡើយ ដែលធ្វើអោយពួកគាត់ជួបប្រទះនិងបញ្ហាសុខមាលភាពក្នុងការរស់នៅ។<br>- នៅក្នុងការរៀបចំដីសម្បទានសង្គមកិច្ចលើកក្រោយទៀតសំណូមពរអោយមានការស្ថាបនាជាមុននូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ជាមូលដ្ឋានជាមុនសិន មុននឹងអោយប្រជាពលរដ្ឋចូល ទៅរស់នៅតំបន់នោះ។ |

| | | | |
|---|---|---|---|
| | | និងអភិវឌ្ឍន៍សេដ្ឋកិច្ចដែលបាននិងកំពុងអនុវត្ត នៅខេត្តកំពង់ចាម ។<br>• បែងចែកដី ៩.៥១៤ហិកតា សម្រាប់គ្រួសារក្រីក្រដែលគ្មានដីចំនួន ១៩០គ្រួសារ នៅខេត្តក្រចេះ ។<br>• ដីដែលបានដោះមីនរួច ១២៩ហិកតា សម្រាប់ ៩៥ គ្រួសារ នៅខេត្តឧត្តរមានជ័យ ។<br>• ដីចំនួន ១.០១៩ហិកតា សម្រាប់គ្រួសារយោធិនពិការចំនួន ៣១៧គ្រួសារ នៅតាកែនកោះស្លា ស្រុកឈូក ខេត្តកំពត ។<br>• ដីចំនួន ២.០៧៤ហិកតា នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ សម្រាប់គ្រួសារយោធា ដែលកំពុងឈរជើង ការពារតំបន់ព្រំដែនកម្ពុជា-ថៃ ចំនួន ៩០៣គ្រួសារ ។<br>• ស្របពេលជាមួយគ្នា ប្រមុខរាជរដ្ឋាភិបាលបានផ្ដល់ដីចំនួន ៤.៥០០ហិកតា សម្រាប់រៀបចំ ភូមិអភិវឌ្ឍន៍ ថ្មីឈ្មោះភូមិ "ធម្មជាតិ" សម្រាប់ ៧៩៣គ្រួសារ នៅតំបន់ប្រាសាទព្រះវិហារក្រោមថវិកាផ្ទាល់របស់រាជរដ្ឋាភិបាលកម្ពុជា ។ | - គំរោងបែងចែកដីសម្បទានសង្គមកិច្ច មានចំនួនតិចតួច ណាស់បើប្រៀបធៀបទៅនឹងចំនួនប្រជាពលរដ្ឋដែលក្រីក្រ នៅក្នុងប្រទេសកម្ពុជា។ |
| ៩៧ | ១១២ | ជាមួយនិងវឌ្ឍនភាព ដែលសម្រេចបានគួរឱ្យកត់សម្គាល់ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលនឹង ទាមទារនូវផែនការសកម្មភាពជាក់លាក់ដើម្បីផ្ដល់ទំនុកជូនដល់ប្រជាជនក្នុងការអនុវត្តគោល<br>នយោបាយគ្រប់គ្រងដីធ្លី រួមមាន :<br>• ការកសាងវប្បធម៌នៃការចុះបញ្ជី<br>និងការកសាងជំនឿរបស់ប្រជាពលរដ្ឋលើប្រព័ន្ធសុរិយោដី ដោយត្រូវផ្ដើមចេញពីការពិនិត្យឡើងវិញនូវបរិបថនៃការផ្ដល់សេវាលើការងារសុរិយោដី និងសំណង់ | - តាមការសង្កេតកន្លងមកឃើញថា ការផ្ដល់ដីសម្បទានសេដ្ឋកិច្ចគឺមានទំហំលើសពីការកំណត់ដែលបានចែងនៅក្នុងច្បាប់ភូមិបាលនិងគ្មានការចាត់វិធានការចុះពិនិត្យ និងដកហូតវិញនោះទេ។<br>- ការផ្ដល់ដីសម្បទានសេដ្ឋកិច្ច គឺកំណត់លើផែនទីតែប៉ុណ្ណោះ មិនបានចុះទៅធ្វើការពិនិត្យដល់ទីតាំងនិងកំណត់ព្រំប្រទល់អោយបានច្បាស់លាស់នោះទេដែលជាហេតុធ្វើអោយមានការត្រួតស៊ីគ្នាជាមួយដីរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ ឬដី |

| | | | |
|---|---|---|---|
| | | តាមប្រព័ន្ធច្រកចេញចូលតែមួយប្រកបដោយតម្លាភាពនិងគណនេយ្យភាពឆាប់រហ័សនិងច្បាស់លាស់រួមទាំងការពិនិត្យឡើងវិញនូវអត្រាសម្រាប់វាយតម្លៃពន្ធប្រថាប់ត្រាលើការចុះបញ្ជីដីធ្លីបន្តដោយការបង្កើតឡើងប្រព័ន្ធព័តិមានដីធ្លីប្រព័ន្ធវាយតម្លៃនិងផែនទីថ្លៃដីមួយច្បាស់លាស់ មានតម្លាភាព ការចូលរួមនិងសមស្របតាមស្ថានភាពជាក់ស្តែងនៃទីផ្សារដីនៅកម្ពុជាតាមរយៈការបង្កើតភ្នាក់ងារពិសេសសម្រាប់ប្រតិបត្តិការ ។<br>• ការគ្រប់គ្រងការប្រើប្រាស់ និងបែងចែកដីធ្លីត្រូវមានតម្លាភាព សមធមិ ប្រសិទ្ធិភាពស្របតាមលក្ខណៈ ធម្មជាតិនៃដី និងមានចិរភាព។ ពង្រឹងការគ្រប់គ្រងដីរដ្ឋ តាមរយៈឧបករណ៏ផែនការកម្មប្រើប្រាស់ដីធ្លីគ្រប់ថ្នាក់គ្រប់កម្រិតសម្រាប់តម្រង់ទិសការអភិវឌ្ឍ និងការត្រួតពិនិត្យការអភិវឌ្ឍដី ការទប់ស្កាត់ការប្រមូលដីបង្កកទុកក្នុងដៃក្រុមមនុស្សមួយក្តាប់តូច ការកាប់រានទន្រ្ទានដីរដ្ឋ ដីព្រៃដីតំបន់ការពារ។ កំណត់ដីសមស្របសម្រាប់ផ្តល់ដល់គ្រួសារក្រីក្រដែលគ្មានដីក្នុងគោលដៅសម្បទានដីសង្គមកិច្ច និងកិច្ច ការការពារជាតិនិងការតាំងលំនៅថ្មីរបស់ប្រជាជនដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍនានារបស់រដ្ឋក៏ដូចជារបស់ក្រុមហ៊ុនឯកជននិងការអនុវត្តវិធានការណ៏ដកហូតមកវិញដីរដ្ឋដែលកាន់កាប់ដោយខុសច្បាប់ដែលមិនអនុវត្តបានត្រឹមត្រូវតាមកិច្ចសន្យាផ្តល់សម្បទានដីសេដ្ឋកិច្ចនិងដែលមានទំហំ លើសពីការកំណត់នៃច្បាប់ភូមិបាល ។ | សម្បទានរបស់ក្រុមហ៊ុនផ្សេងទៀតដែលធ្វើអោយមាន ទំនាស់ដីធ្លីកើតឡើង។<br>- មុននឹងធ្វើការផ្តល់ដីសម្បទានសេដ្ឋកិច្ចសូមធ្វើការចុះទៅពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានជាមុនសិនព្រោះវាអាចនឹងធ្វើអោយប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់។<br>- មានដីសម្បទានសេដ្ឋកិច្ចជាច្រើនកន្លែងដែលផ្តល់អោយទៅបុគ្គលតែម្នាក់ ដែលផ្ទុយពីអ្វីដែលបានចែងនៅក្នុងច្បាប់ភូមិបាល ។សូមមេត្តាធ្វើការត្រួតពិនិត្យឡើងវិញនិងធ្វើចំណាត់ការចំពោះបញ្ហានេះ។<br>- ការទិញដីបង្កកទុករបស់ឈ្មួញឱកាសនិយមនៅតែកើតមានដោយគ្មានការចាត់វិធានការអ្វីទាំងអស់។<br>- ការផ្តល់ដីសម្បទានសេដ្ឋកិច្ចកន្លងមកមិនបានធ្វើការវាយ តំលៃផលប៉ះពាល់បរិស្ថាន និងសង្គមបានគ្រប់ជ្រុងជ្រោយនោះទេហើយក៏គ្មានការចូលរួមពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានដែរ។<br>- សូមមេត្តាបើកអោយមានការចូលរួមពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋានក៏ដូចជាភាគីពាក់ព័ន្ធទាំងអស់ និងធ្វើការសិក្សាអំពីហេតុប៉ះពាល់បរិស្ថានអោយបានលំអិតនិងផ្សព្វផ្សាយជាសាធារណៈមុននឹងសំរេចផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់ណាមួយ។ |

| | | | |
|---|---|---|---|
| | | • ពិនិត្យឡើងវិញនូវការផ្តល់ដីសម្បទានសេដ្ឋកិច្ចដោយពង្រឹងយន្តការត្រួតពិនិត្យការអនុវត្តកិច្ចសន្យាពិនិត្យ ទំហំដី ដើម្បីដកហូតយកមកវិញនូវដីដែលមិនបានប្រើប្រាស់ និងទំហំលើស ពីកិច្ចសន្យា ដោយអនុវត្តច្បាប់ដីធ្លី ឆ្នាំ ២០០១ និងដកហូតមកវិញនូវ "តំបន់បម្រុងទុក " និង ដីដែលប្រជាជនបានគ្រប់គ្រងពីមុនហើយត្រូវបានដាក់បញ្ចូលទៅក្នុងដីសម្បទាននិងត្រូវដាក់ បញ្ចូលទៅក្នុងដី "តំបន់បំរុងទុក" វិញ ឬ បែងចែកជូនប្រជាជន ដែលធ្លាប់បានគ្រប់គ្រង ។<br>• ពង្រឹងការវាយតម្លៃផលប៉ះពាល់លើសង្គម និងបរិស្ថាន ដោយមានការចូលរួម និងតម្លាភាព សម្រាប់តំបន់ដែលនឹងត្រូវផ្តល់ដីសម្បទាន ។<br>• ស្វែងរកនិងធានាការចុះបញ្ជីដីរដ្ឋដោយផ្អែកលើនីតិវិធី ដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋនិងការចុះបញ្ជីដីជនជាតិភាគតិច ដែលហាគមនប្រជាជនកំពុងរស់នៅ ។<br>• អនុវត្តឱ្យបានម៉ឺងម៉ាត់នូវសារាចរណែនាំស្តីពីការកាន់កាប់ដីរដ្ឋខុសច្បាប់ ដើម្បីកំណត់ និងដកហូតយកមកវិញ សម្រាប់ធ្វើការអភិវឌ្ឍ និងអភិរក្សបរិស្ថាន ។<br>• យកពន្ធដីដែលមិនប្រើប្រាស់បញ្ចប់កិច្ចសន្យាដីសម្បទានដែលមិនបានអនុវត្តតាមច្បាប់ និងបញ្ញតិដែលបានចែង បង្កើតប្រព័ន្ធព័តិមានដីធ្លី ប្រព័ន្ធវាយតម្លៃដីនិងរៀបចំផែនការអភិវឌ្ឍន៍ខេត្តក្រុងដើម្បីកំណត់តំបន់មានសក្តានុពលសម្រាប់ការគ្រប់គ្រង និងការ ការពារ ។<br>• អនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល | |

| | | | |
|---|---|---|---|
| | | ស្តីពីការបែងចែកដីសម្បទានសង្គមកិច្ច ឱ្យដល់ប្រជាជនចំនួន៤១៦គ្រួសារនៅក្នុងខេត្តនីមួយៗ ដើម្បីសម្រេចបានចំណុចដៅចំនួន ១០.០០០គ្រួសារ នៅឆ្នាំ២០១០ ។<br>• បង្កើនល្បឿនផ្តល់កម្មសិទ្ធិដី និង ចុះបញ្ជីដីដល់តំបន់ជនជាតិភាគតិច (ប្រមាណ ១៧ ក្រុម)និងផ្តល់ដីដល់ពួកគេវិញ ដែលបណ្តាលមកពីការទិញ-លក់ ដោយខុសច្បាប់កន្លងមក ដែល គម្រោងចំនួនពីរបាននិងកំពុងដំណើរការនៅខេត្តរតនគីរី និង គម្រោងចំនួនមួយទៀត នៅ ខេត្តមណ្ឌលគីរី ក្នុងការចុះបញ្ជីដី ដែលកាប់កាប់ដោយជនជាតិភាគតិច ។<br>• ផ្តល់ដីឱ្យដល់ប្រជាជនដែលគ្មានឬខ្វះដីទៅតាមលទ្ធភាព ។<br>• អប់រំនិងជូនដំណឹងដល់ប្រជាជនតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ឱ្យយល់ដឹងពីចាកចេញនិងទីតាំងលំនៅដ្ឋានដែលផ្តល់ឱកាសដល់ជនមួយចំនួនទិញនិងកាន់កាប់ដីរបស់ប្រជាជនក្រីក្រដែលករណីដូចនេះបណ្តាលឱ្យប្រជាជនបាត់បង់ទីតាំងលំនៅដ្ឋាន ។<br>• ជម្រុញល្បឿនដោះស្រាយវិវាទដីធ្លី ពិសេសវិវាទពហុភាគីដោយប្រើប្រាស់កម្លាំងសរុបវិធានការសរុបពិសេសការបង្កើតក្រុមដោះស្រាយវិវាទដីធ្លីចល័តក្នុងក្របខ័ណ្ឌជាទីភ្នាក់ងារប្រតិបត្តិការពិសេសនៅក្រុង ស្រុក ខណ្ឌដែលមានវិវាទកកស្ទះច្រើន ។ | |
| ១៩៧ | ៤០០ | កំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតទៅលើវិធានការដើម្បីពង្រឹងការគ្រប់គ្រងដីធ្លីការបែងចែកដីធ្លីនិងការប្រើប្រាស់ដីធ្លីសំដៅធានាសុវត្ថិភាពនៃ | - ស្នើសូមបន្ថែមពាក្យនៅក្នុងប្រយោគទី២:" កំណែទម្រង់ដីធ្លី ានសារៈសំខាន់ណាស់ សម្រាប់បង្កើនការបែងចែកដី**សង្គមកិច្ច**សម្រាប់កសិកម្ម |

| | | | |
|---|---|---|---|
| | | ការកាន់កាប់ដីធ្លីលុបបំបាត់ការកាន់កាប់ដីដោយខុសច្បាប់និងទប់ស្កាត់លើការគ្រប់គ្រងដីធ្លីមិនប្រើប្រាស់ដោយមនុស្សមួយក្រុមតូច ។ កំណែទម្រង់ដីធ្លីមានសារៈសំខាន់ណាស់សម្រាប់បង្កើនការបែងចែកដីសម្រាប់កសិកម្មដោយការផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋជាពិសេសជូនដល់ប្រជាកសិករដើម្បីបង្កើនផលិតផល និងពិពិធកម្មកសិកម្ម ។ការចុះបញ្ជីដីធ្លីមានការកើនឡើងគួរឱ្យកត់សំគាល់ដោយការចុះបញ្ជីជាលក្ខណៈប្រព័ន្ធសម្រេចបាននៅក្នុង១៧៥ឃុំ/សង្កាត់នៅក្នុងទូទាំង១១រាជធានី-ខេត្ត ។លើសពីនេះដីច្រើនជាង១លានក្បាលដី ត្រូវបានចុះបញ្ជី ។ | ជាលក្ខណៈគ្រួសារដោយការផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ជាពិសេសជូនដល់ប្រជាកសិករដើម្បីបង្កើនផលិតផល និងពិពិធកម្មកសិកម្ម ។"<br>- ស្នើសូមសំរាយពាក្យ **ពិពិធកម្មកសិកម្ម**<br>- ស្នើសូមធ្វើការកំណត់ចំនួនក្បាលដីសំរាប់ផែនការចុះបញ្ជីទៅតាមឆ្នាំនីមួយៗអោយបានច្បាស់លាស់ ។ |
| ១៩៨ | ៤០១ | រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភានឹងបន្តការអនុវត្តកំណែទម្រង់ដីធ្លី នៅក្នុង ក្របខ័ណ្ឌនៃច្បាប់ដីធ្លី និងគោលនយោបាយដីធ្លីដែលមានស្រាប់ដោយបង្កើតបន្ថែមនូវក្របខ័ណ្ឌ នៃ បញ្ញត្តិច្បាប់ដូចជាច្បាប់ស្តីពីសិទ្ធិបុព្វក្រៃ ច្បាប់អស្សាមិករណ៍ ច្បាប់អនុបយោគនិងច្បាប់ស្តីពីដី អភិវឌ្ឍន៍ ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ | -សូមអោយមានការចូលរួមប្រឹក្សាយោបល់ពីសំណាក់សង្គមស៊ីវិលនៅពេលដែលច្បាប់ទាំងនោះត្រូវបានពង្រាងឡើង ។ |
| ១៩៨ | ៤០២ | រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការពិនិត្យឡើងវិញ និងចាត់វិធានការចាំបាច់នានាដើម្បីបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ដីកម្មសិទ្ធិរបស់រដ្ឋដែលមិនបានប្រើប្រាស់និងវិធានការច្បាប់ទប់ស្កាត់និងការកាន់កាប់ដីរដ្ឋដោយឯកជនមួយចំនួន ។ ជាមួយគ្នានោះដែររាជរដ្ឋាភិបាលកម្ពុជានឹងបញ្ចប់នូវការធ្វើសារពើពន្ធអចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រដ្ឋ និងបង្កើនល្បឿននៃការចុះបញ្ជី ដីធ្លីជាប្រព័ន្ធដោយបង្កើតសេវាកម្មច្រកចេញចូលតែមួយ ដើម្បីធានាបាននូវតម្លាភាព។ កិច្ចព្រម ព្រៀងជាអាទិភាព ដើម្បីចៀសវាងជីទំនេរមានវិវាទនិងដីដែលមានសហគមនជនជាតិភាគតិចរស់ នៅ | - ស្នើរសូមធ្វើសំរាយពាក្យ **ច្រកចេញចូលតែមួយ**<br>- សូមបញ្ជាក់អោយបានច្បាស់ អំពីកិច្ចព្រមព្រៀងជាអាទិភាពថាតើជាកិច្ចព្រមព្រៀងរវាងភាគីណា ជាមួយនឹងភាគីណា<br>- ស្នើរសូមបន្ថែមប្រយោគ"...លុបបំបាត់ឱ្យបានការកាន់កាប់ដីដោយខុសច្បាប់ ។**ត្រូវចាត់វិធានការណ៏ដើម្បីការពារដីរបស់ជនជាតិដើភាគតិចដោយបញ្ឈប់រាល់ការធ្វើសម្បទាន ដីសេដ្ឋកិច្ចនៅកន្លែងដែលមានជនជាតិដើមរស់នៅ**។ រាជរដ្ឋាភិបាលកម្ពុជា**បន្តពង្រឹងយន្តការដោះស្រាយវិវាទដីធ្លីដែលមានស្រាប់(គណៈកម្មការសូរិយោ** |

| | | | |
|---|---|---|---|
| | | នឹងត្រូវបង្កើតឡើង ដើម្បីកាត់បន្ថយបាននូវវិវាទដីធ្លី ធានាបាននូវសន្តិសុខនៃកម្មសិទ្ធិដីធ្លី និង លុបបំបាត់ឱ្យបាន ការកាន់កាប់ដីដោយខុសច្បាប់។ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តដោះស្រាយវិវាទ ដីធ្លីដោយប្រើប្រាស់យន្តការច្បាប់ ដើម្បីធានាបាននូវយុត្តិធម៌ជូនភាគីទាំងពីរ នៅក្រៅប្រព័ន្ធតុលាការតាមរូបភាពនៃការផ្លាស់ប្តូរទីលំនៅ។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពខ្ពស់ដល់ការផ្តល់កម្មសិទ្ធិដីធ្លីដល់គ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ សម្រាប់សង់លំនៅដ្ឋាន ធ្វើកសិកម្ម និងអាជីវកម្មធុនតូចៗ ។ | **ដី និងអង្វាធរជាតិ ដោះស្រាយវិវាទដីធ្លី) ដើម្បីធ្វើអោយការដោះស្រាយវិវាទដីធ្លីមានប្រសិទ្ធិភាព** នឹងបន្តដោះស្រាយវិវាទ...”<br>= នៅក្នុងប្រយោគទី៤ សូមបន្ថែមពាក្យ និងលប់ឃ្លា”...ដោយប្រើប្រាស់យន្តការច្បាប់ដើម្បីធានាបាននូវយុត្តិធម៌ ជូនភាគី ទាំងពីរ**ទាំងនៅក្នុង** និងក្រៅប្រព័ន្ធតុលាការ~~តាមរូបភាពនៃការផ្លាស់ប្តូរទីលំនៅ~~។<br>- រាជរដ្ឋាភិបាលកម្ពុជា **បាននឹងកំពុងបង្កើនល្បឿន** និង ផ្តល់ អាទិភាពខ្ពស់ដល់ការផ្តល់កម្មសិទ្ធិដីធ្លីដល់គ្រួសារក្រីក្រ និង ក្រុមជនងាយរងគ្រោះ សម្រាប់សង់លំនៅដ្ឋានធ្វើកសិកម្មនិងអាជីវកម្មធុនតូចៗ ។ |
| ១៩៨ | ៤០៣ | ដើម្បីធានាបាននូវការប្រើប្រាស់ដីធ្លីមានប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជា នឹងជំរុញការរៀបចំផែនទី ប្រើប្រាស់ដីក្នុងគោលបំណងបែងចែកដីសម្រាប់ ធ្វើកសិកម្ម ធ្វើឧស្សាហកម្ម ធ្វើទេសចរណ៍ តំបន់ ជនបទតំបន់ទីប្រជុំជន ធ្វើលំនៅដ្ឋាន និង តំបន់បម្រុងទុក ក្នុងការទប់ស្កាត់ការ ប្រើប្រាស់មិនសម ស្រប និងដីអភិរក្ស។ ជាមួយនោះដែរ រាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើការពិនិត្យឡើងវិញ នូវដីសម្បទាន សេដ្ឋកិច្ច ដើម្បីប្រើប្រាស់ឱ្យបានសមស្របតាមកិច្ចសន្យានិងប្រើប្រាស់ដីទាំងនោះឱ្យអស់លទ្ធភាពចៀសវាងការកាន់កាប់ដីដោយគ្មានការប្រើប្រាស់ ។ | - សូមបន្ថែមពាក្យនៅក្នុងប្រយោគទី១”...ក្នុងការទប់ស្កាត់ការប្រើប្រាស់មិនសមស្របនិងដីអភិរក្ស **ដោយមានការ ចូលរួម ពីគ្រប់ភាគីពាក់ព័ន្ធ**។ ជាមួយនោះដែរ...” |
| ១៩៩ | ៤០៥ | ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤នៃរដ្ឋសភាក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់នឹងរៀបចំផែនការសកម្មភាព ដូចខាងក្រោម :<br>• បន្តចុះបញ្ជីកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀត លើ | - ស្នើសូមបន្ថែមពាក្យនៅក្នុងត្រេទី១ ” **ជម្រុញ** និង បន្តចុះ បញ្ជីកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀត ....និងប្រសិទ្ធភាពនៃ ទីផ្សារដី។ **ដំណើរការនេះគួរតែអនុលោមតាមគោលការណ៍អភិបាលកិច្ចល្អ តម្លាភាព វិមជ្ឈការ និង វិសហមជ្ឈការ** |

| | | | |
|---|---|---|---|
| | | អចលនវត្ថុទាំងអស់ (រដ្ឋ និង ឯកជន) ឱ្យបានច្បាស់លាស់ធ្វើការផ្ទេរសិទ្ធិលើទ្រព្យទាំងនោះជាផ្លូវការទប់ស្កាត់ និងដោះស្រាយវិវាទដីធ្លី សំដៅពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ធានាឱ្យបាននូវទំនុកចិត្ត និង ប្រសិទ្ធភាពនៃទីផ្សារដី ។<br>• បង្កើនល្បឿននៃការកសាងផែនការកម្មរៀបចំដែនដីគ្រប់ខ្នាត គ្រប់កម្រិត និងផែនទីដីរដ្ឋគ្រប់ក្រុង-ស្រុក-ខណ្ឌស្របតាមគោលការណតម្លាភាព ការចូលរួម ការព្រមព្រៀង និងការគោរពឋានានុក្រមនៃ ការរៀបចំផែនការបទបញ្ជា និង នីតិវិធីពាក់ព័ន្ធ សំដៅធានាការគ្រប់គ្រងការការពារនិងការប្រើប្រាស់ដីនិងធនធានធម្មជាតិប្រកបដោយតម្លាភាព និងប្រសិទ្ធភាពតាមរយៈការរក្សានូវចីរភាពបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធមិនៅតំបន់ទីប្រជុំជននិងជនបទព្រមទាំងទប់ស្កាត់វិវាទលើការប្រើប្រាស់ដីដោយដាក់បញ្ញត្តិលើការអភិវឌ្ឍដីការប្តូររូបភាពនៃការប្រើប្រាស់ដី ការកែសម្រួលក្បាលដី ការសាងសង់ការតាំងលំនៅថ្មីលើមូលដ្ឋាននៃការជំរុញរៀបចំនិងដាក់ឱ្យអនុវត្តគោលនយោបាយរៀបចំដែនដីច្បាប់ស្តីពីការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់គោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការនិងអភិបាលកិច្ចល្អ គោលនយោបាយជាតិស្តីពីលំនៅឋាន គោលនយោបាយតាំងទីលំនៅថ្មី ច្បាប់ស្តីពីពន្ធលើដីធ្លីច្បាប់ស្តីពីសិទ្ធិបុព្វក្រៃច្បាប់អស្សា-មិករណ៍ ច្បាប់អនុបយោគ ច្បាប់ស្តីពីដីកសិកម្ម ។ល។<br>ធ្វើការបែងចែកនិងប្រើប្រាស់ដីរដ្ឋ សម្រាប់ | **សមភាពយេនឌ័រដើម្បីអភិវឌ្ឍន៍វប្បធម៌នៃការចុះបញ្ជីដីធ្លីនិងដើម្បីបង្កើនភាពត្រឹមត្រូវនៅក្នុងប្រព័ន្ធចុះបញ្ជីដីធ្លី** ។<br>- សូមបន្ថែមពាក្យនៅក្នុងទ្រទីវ២ "បង្កើនល្បឿននៃការកសាងផែនការកម្មរៀបចំដែនដីគ្រប់ខ្នាត គ្រប់កម្រិត និង ផែនទីដីរដ្ឋគ្រប់ក្រុង- ស្រុក-ខណ្ឌស្របតាមគោលការណ៍តម្លាភាពការចូលរួម **ពីគ្រប់ភាគីពាក់ព័ន្ធ** ការព្រមព្រៀង..."<br>- សូមធ្វើការបន្ថែម និងលប់ពាក្យ នៅក្នុងទ្រទីវ៣ "ធ្វើការបែងចែកនិងប្រើប្រាស់ដីរដ្ឋសម្រាប់គោលបំណង**សម្បទានដីសង្គមកិច្ច**និងសាធារណៈប្រកបដោយតម្លាភាពភាពត្រឹមត្រូវសមធមិស្ថិរភាពសង្គមសន្តិសុខស្បៀង........របស់សហគមន៍ជនជាតិដើមភាគតិច" ~~នៅក្នុងតំបន់ដែលមានសហគមន៍ជនជាតិដើមភាគតិចច្បាស់លាស់កម្មវិធីតាំងលំនៅថ្មីការត្រួតពិនិត្យឡើងវិញដីសម្បទានសេដ្ឋកិច្ចដែលលើសពីចំនួនកំណត់នៃច្បាប់ភូមិបាល និង ដែលមិនអនុវត្តកិច្ចសន្យានិងឬមិនបានវាយតម្លៃផលប៉ះពាល់សង្គមបរិស្ថានតាមនីតិវិធីច្បាស់លាស់ឬគ្មានផែនការប្រើប្រាស់និងអភិវឌ្ឍដីត្រឹមត្រូវតាមរយៈការអនុវត្តសារាចរណែនាំលេខ ០៦សណន ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ដើម្បីប្រមូលយកមកវិញនូវដីដែលប្រមូលទិញបង្កកទុកមិនប្រើប្រាស់និងដីរដ្ឋដែលទទួលរងការរានទន្ទ្រានកាន់កាប់ដោយខុសច្បាប់~~ ។ការអភិវឌ្ឍន៍ប្លង់គោលរបស់ទីក្រុង គួរធ្វើឡើងដោយមានការចូលរួម ពីសហគមន៍ក៏ដូចជាអង្គការសង្គមស៊ីវិលដើម្បីធានាលើភាពជាម្ចាស់សិទ្ធិ នៅក្នុង តំបន់រៀងៗខ្លួន ។ |

| | | | |
|---|---|---|---|
| | | គោលបំណង ឯកជន និងសាធារណៈ ប្រកប ដោយតម្លាភាព សមធម៌ ស្ថិរភាពសង្គម សន្តិសុខស្បៀង និងសម្រួលដល់ការវិនិយោគ ដោយផ្អែកលើប្រភេទ និងគុណភាព អំណោយផលពីធម្មជាតិនៃដី និងដោយឆ្លើយតបទៅនឹងតម្រូវការជីវភាពរបស់ប្រជាពលរដ្ឋទូទៅ ជា ពិសេស ប្រជាពលរដ្ឋក្រីក្រ យុទ្ធជនពិការ និង គ្រួសារយុទ្ធជនពលី គ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ និង ក្រុមជនជាតិដើមភាគតិច ដែលងាយរងគ្រោះគ្មានដី និងខ្វះដី និងក្រុមគ្រួសារកងទ័ព ដែលកំពុងបំពេញបេសកកម្មក្នុងសមរភូមិមុខតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច និងការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច នៅក្នុងតំបន់ដែលមានសហគមនជនជាតិដើមភាគតិចច្បាស់លាស់ កម្មវិធីតាំងលំនៅថ្មី ការត្រួតពិនិត្យឡើងវិញដីសម្បទានសេដ្ឋកិច្ច ដែលលើសពីចំនួនកំណត់នៃច្បាប់ភូមិបាល និង ដែលមិនអនុវត្តកិច្ចសន្យានិងឬមិនបានវាយតម្លៃផលប៉ះពាល់សង្គមបរិស្ថានតាមនីតិវិធីច្បាស់លាស់ ឬគ្មានផែនការប្រើប្រាស់ និង អភិវឌ្ឍដីត្រឹមត្រូវតាមរយៈការអនុវត្តសារាចរណែនាំលេខ ០៦ សណន ស្តីពីការកាន់ កាប់ដីរដ្ឋ ដោយខុសច្បាប់ ដើម្បីប្រមូលយក មកវិញនូវដី ដែលប្រមូលទិញបង្កកទុកមិន ប្រើប្រាស់ និងដីរដ្ឋដែលទទួល រងការរាន ទន្ទ្រានកាន់កាប់ដោយខុសច្បាប់ ។ | |
| ២០០ | ៤០៦ | ផែនការសកម្មភាពជាក់ស្តែងរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ មានដូចខាងក្រោម:<br>• បន្តជំរុញបង្កើត គោលនយោបាយនិងក្រប | - ស្នើសូមបន្ថែមឃ្លានៅក្នុងត្រែទី៣"...ដើម្បីពង្រឹងប្រសិទ្ធិភាពនៃការគ្រប់គ្រងអចលនវត្ថុរបស់រដ្ឋ**និងត្រូវបិទផ្សាយឯកសារទាំងនោះជា** |

| | | | |
|---|---|---|---|
| | | ខណ្ឌ គតិយុត្ត ដែលទាក់ទងទៅនឹងការ ពង្រឹងការអនុវត្តច្បាប់ភូមិបាលនិងច្បាប់ពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងការងាររដ្ឋបាលដីធ្លី ការរៀបចំដែនដីនិងសំណង់ និងការងារបែង ចែកដីធ្លី ។ សកម្មភាពអាទិភាពចំពោះមុខ ត្រូវយកចិត្ត ទុកដាក់រួមមាន :<br>➢ អភិវឌ្ឍឯកសារបឋមស្តីពីក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី ទៅជា គោលនយោបាយដីធ្លីទូលំទូលាយ (សៀវភៅស) ។<br>➢ បង្កើតនិងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត រួមមាន ច្បាប់អស្សាមិករណ៍ ច្បាប់ស្តីពីការវាស់វែងនិងផែនទីច្បាប់សំណង់ក្រមនគរូបនីយកម្ម ច្បាប់ស្តីពីសិទ្ធិបុព្វក្រៃ ច្បាប់ស្តីពីអនុយោគ ច្បាប់ស្តីពីដីកសិកម្ម និង ក្របខណ្ឌ គតិយុត្តមួយចំនួនទៀតទាក់ទងនឹងការផ្ទេរដីការបង្រួមក្បាលដី ការបំបែក ក្បាលដីការវាយតម្លៃថ្លៃដីទីផ្សារដី ស្តង់ដារសំណង់ជាដើមព្រមទាំងធ្វើវិសោធនកម្មមាត្រាច្បាប់ និងបទដ្ឋានគតិយុត្តមួយចំនួន<br>ដែលពាក់ព័ន្ធទៅនឹងច្បាប់ភូមិបាល ច្បាប់ពន្ធ ច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ស្របតាមការវិវត្ត របស់ប្រទេសជាតិ ។<br>➢ បង្កើត និងជំរុញការអនុវត្តគោលនយោបាយជាតិ ស្តីពីលំនៅឋាន ការរៀបចំដែនដី ការតាំងលំនៅថ្មី ក្រប | **សាធារណៈដើម្បីបង្ហាញពីតម្លាភាពនិងគណនេយ្យភាព** ។<br>- ស្នើសូមបន្ថែមឃ្លានៅក្នុងគ្រែទី៤"...ដោយធានាការពារសិទ្ធិនិងផលប្រយោជនស្របច្បាប់របស់ស្ត្រី **និងសហគមន៍ជន-ជាតិដើមភាគតិច** ឱ្យបានត្រឹមត្រូវ ។<br>- នៅក្នុងគ្រែទី៥ តើប្រព័ន្ធវាយតំលៃដីធ្លី ធ្វើឡើងដោយផ្អែក លើគោលការណ៍អ្វីខ្លះ?<br>- សូមបន្ថែមពាក្យនៅក្នុងគ្រែទី៥ ដដែល " ...មានការចូលរួម **ប្រឹក្សាយោបល់ពីសំណាក់អង្គការសង្គមស៊ីវិល និង ភាគីពាក់ ព័ន្ធ** ដោយមានតម្លាភាព...."<br>- សូមធ្វើការពន្យល់ពាក្យ ធ្វើចរន្តការលើព័តិមាននៅក្នុង គ្រែទី៦ និង<br>- នៅក្នុងគ្រែទី៦ ដដែល សូមធ្វើការបន្ថែមពាក្យ " ... ធ្វើចរន្តការលើព័តិមានសុរិយោដីឱ្យឆាប់រហ័ស **ទាំងនៅតំបន់ទីប្រជុំ ជន និង ជនបទ** ដោយជំរុញការ..."<br>- សូមធ្វើការកែប្រែពាក្យនៅក្នុងគ្រែទី ៧ " ...ដែលអាចផ្តល់ព័តិមានជាក់លាក់ជូន ~~អតិថិជន~~ ប្រជាពលរដ្ឋ និងជាមូល ដ្ឋាន..."<br>- ស្នើសូមធ្វើការកំណត់ឆ្នាំ ដែលគ្រោងនឹងបង្កើតប្រព័ន្ធធរណី<br>សាស្ត្រអោយបានច្បាស់លាស់នៅក្នុងគ្រែទី៨ ឧទាហរណ៍ បង្កើតប្រព័ន្ធធរណីសាស្ត្រនៅ ឆ្នាំ ២០១២ ។<br>- ស្នើសូមបន្ថែមឃ្លានៅក្នុងគ្រែទី១០ "....និងការទូរទាត់សំ-ណងជាដើម) **ដោយភ្នាក់ងារឯករាជ្យ** និងបង្កើតក្របខណ្ឌ |

| | | | |
|---|---|---|---|
| | | ខណ្ឌគតិយុត្ត និងនីតិវិធីសមស្រប សម្រាប់ការគ្រប់គ្រង ការ អភិវឌ្ឍដី នៅតំបន់ទី ប្រជុំជន និងតំបន់ជនបទ រួមទាំងដីបម្រើឱ្យផលិតកម្ម កសិកម្ម ការសាងសង់ និងការកំណត់កម្ពស់អគារក្នុងតំបន់ទីក្រុង ទីប្រជុំជនបានត្រឹមត្រូវ ។<br>• បង្កើនល្បឿននៃការកសាងបទប្បញ្ញត្តិ បទដ្ឋានបច្ចេកទេសសម្រាប់វិស័យសំណង់ ដែលកំពុង រីកចំរើន ជាពិសេសនាបច្ចុប្បន្ននេះ ការសាងសង់អគារខ្ពស់ៗដែលប្រើប្រាស់បច្ចេកវិទ្យា ទំនើបកំពុងកើនឡើងជាលំដាប់។ បង្កលទ្ធភាពគ្រប់គ្រាន់លើមធ្យោបាយ ដើម្បីឱ្យមន្ត្រីជំនាញអាចតាមដានស្រាវជ្រាវអំពីការរីកចំរើននៃបច្ចេកវិទ្យានិងការគ្រប់គ្រងប្រកបដោយ ប្រសិទ្ធិភាព ។<br>• បង្កើតបញ្ជីសារពើភ័ណ្ឌអចលនវត្ថុ (ដី និងអគារ) របស់រដ្ឋជាជំហានៗ នៅក្នុងប្រព័ន្ធទិន្នន័យ ឯកភាពតែមួយ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងអចលនវត្ថុរបស់រដ្ឋ ។<br>• ដំណើរការចុះបញ្ជីដីធ្លីទូទាំងប្រទេសដោយ តម្លាភាព និងប្រសិទ្ធភាពសម្រាប់អចលនវត្ថុទាំងអស់ ទាំងដីរដ្ឋ (ដីសាធារណៈ និងដីឯកជនរបស់រដ្ឋ) ទាំងដីនិងអគារសហកម្មសិទ្ធិដីឯកជនរបស់បុគ្គលឯកជន ជាពិសេសក្នុងតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច និងដីកម្មសិទ្ធិសមូហភាពសហគមនជនជាតិដើមភាគតិចនៅក្នុងតំបន់ដែលមានសហគមន៍ច្បាស់លាស់ | គតិយុត្តទាក់ទងនឹងការគ្រប់គ្រងវិជ្ជាជីវៈវាយតម្លៃថ្លៃអចលនវត្ថុ។<br>- នៅក្នុងត្រេទី១២ សូមបន្ថែមពាក្យ " បន្តដោះស្រាយវិវាទ ដីធ្លី **ទាំងក្នុង និងក្រៅប្រព័ន្ធតុលាការ** តាមរយៈ..."<br>- នៅក្នុងត្រេទី១៦ ចំនួនគ្រួសារដែលនឹងត្រូវទទួលបានដីសង្គម កិច្ចមានចំនួនតិចតួចណាស់រហូតដល់ឆ្នាំ២០១៣ (១០.០០០ គ្រួសារ) ស្នើសុំអោយបន្ថែមចំនួនគ្រួសាររហូតដល់ **២៥.០០០ គ្រួសារ**។<br>- នៅក្នុងត្រេទី១៦ដដែលសូមបន្ថែមឃ្លា"...ដើម្បីរួមចំណែកដោះស្រាយបញ្ហាសង្គមនិងកិច្ចការពារជាតិ**ដោយបង្កើតយន្តការជាក់លាក់ ដើម្បីធានាតម្លាភាព គណនេយ្យភាព និង សមធមិដល់ប្រជាពលរដ្ឋក្រីក្រនិង ផ្តោតការយកចិត្តទុកដាក់លើគំរោងស្នើសុំដីសម្បទានសង្គមកិច្ចសំរាប់ប្រជាពល- រដ្ឋក្រីក្រ ជាពិសេសនៅតាមទីជនបទដោយធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័នជាមូលដ្ឋានផងដែរ។**<br>- សូមធ្វើការកែសម្រួលប្រយោគទាំងមូលនៅក្នុងត្រេទី ១៧ ដូចតទៅ: **ត្រួតពិនិត្យឡើងវិញការអនុវត្តកិច្ចសន្យាផ្តល់សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ក៏ដូចជាសម្បទានដីសេដ្ឋកិច្ច ដែលលើស ពីការកំណត់នៃច្បាប់ភូមិបាល និងដែលមិនអនុវត្តតាមកិច្ចសន្យា និងសម្បទានដីសេដ្ឋកិច្ចថ្មីដែល គ្រោងនឹងបន្តផ្តល់លើមូលដ្ឋាននៃអនុ ក្រឹត្យស្តីពីសម្បទានដី សេដ្ឋកិច្ច និងក្របខណ្ឌ គតិយុត្ត ដែលមានជាធរមានឱ្យបាន ច្បាស់លាស់ ដោយមានការវាយតម្លៃពីផលប៉ះពាល់** |

| | | | |
|---|---|---|---|
| | | ទៅតាមនីតិវិធីទាំងពីរដែលមានជាធរមាន គឺនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងមាន លក្ខណៈដាច់ដោយដុំ សម្រេចឱ្យបាន ៣២ភាគរយ នៅឆ្នាំ២០១០ និង ប្រមាណ ៣៨-៣៩ ភាគរយនៅឆ្នាំ២០១៣ នៃក្បាលដីសរុបដែលត្រូវចុះបញ្ជីនិងសហគមន៍ជនជាតិដើមភាគតិច ចំនួន៤ ដោយធានាការពារសិទ្ធិ និងផលប្រយោជនស្របច្បាប់របស់ស្ត្រី ឱ្យបានត្រឹមត្រូវ ។<br>• ពង្រឹងការអនុវត្តការចុះបញ្ជីបន្ត តាមច្រកចេញចូលតែមួយ លើមូលដ្ឋាននៃប្រព័ន្ធវាយតម្លៃ ដីធ្លី ដែលត្រូវបានកសាងឡើងដោយមានការចូលរួម មានតម្លាភាព និងដែលសាធារណៈជនទូទៅអាចដឹងបានដោយងាយស្រួលដោយការផ្សារភ្ជាប់ជាមួយ ដំណើរការកសាងផែនទីចុះបញ្ជីនិងធ្វើបញ្ជីសារពើភ័ណ្ឌដីរដ្ឋ ជាពិសេស ដីរដ្ឋក្នុងតំបន់ទីក្រុង ទីប្រជុំជន និងការបោះ បង្គោលដីព្រៃ ដីតំបន់ការពារស្របតាមនីតិវិធីដែលមានជាធរមានជាពិសេសអនុក្រឹត្យ ស្តីពីការគ្រប់គ្រងដីរដ្ឋ ។<br>• ពង្រឹងការចុះបញ្ជីបន្ត និងធ្វើចរន្តការលើព័ត៌មានសុរិយោដីឱ្យបានឆាប់រហ័សដោយជំរុញការអនុវត្ត ច្រកចេញចូលតែមួយដើម្បី បង្កើនចំណូលរបស់រដ្ឋប្រកបដោយតម្លាភាព និងទទួល បានទំនុកចិត្តពីប្រជាពលរដ្ឋ។<br>• បង្កើតប្រព័ន្ធព័ត៌មានដីធ្លីដែលអាចផ្តល់ព័ត៌មានជាក់លាក់ជូនអតិថិជន និងជាមូលដ្ឋានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ និងសម្រាប់បម្រើដល់ពហុគោលបំណង ។<br>• បង្កើតប្រព័ន្ធព័ត៌មានធរណីសាស្ត្រ និងធ្វើចំ | **សង្គមនិងបរិស្ថានបានគ្រប់ជ្រុងជ្រោយនិងមានតម្លាភាពមានការចូលរួមពីគ្រប់អ្នកដែលមានចំណែកពាក់ព័ន្ធជាពិសេសប្រជាពលរដ្ឋក្នុងតំបន់នោះ។ ករណីដែលរកឃើញថាមានការផ្តល់សម្បទានដីសេដ្ឋកិច្ចលើសពីទំហំដែលបានកំណត់ក្នុងច្បាប់ភូមិបាលត្រូវធ្វើការកាត់តម្រឹមឱ្យបានត្រឹមត្រូវ និងលុបចោលកិច្ចសន្យាសម្បទានទាំងឡាយណាដែលបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសុខាមាលភាពសង្គម។**<br>- ស្នើសូមបន្ថែមត្រទី១៩ **ជុំរុញអោយប្រជាពលរដ្ឋធ្វើការអភិវឌ្ឍន៍ផលិតផលកសិកម្មរបស់ខ្លួនក្នុងគោលបំណងធ្វើ អោយប្រសើរឡើងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។** |

| | | | |
|---|---|---|---|
| | | ណាត់ថ្នាក់ប្រភេទដី តាមលក្ខណៈពីធម្មជាតិនៃដីនិងប្រព័ន្ធព័តិមានភូមិសាស្ត្រឱ្យ មានការឯកភាពនៅទូទាំងប្រទេស ។<br>• បន្តរៀបចំបណ្តាញប្រឹថពីរិភាគ និងបណ្តាញរយៈកំពស់នៅទូទាំងប្រទេស និងបង្កើតស្ថានីយ វាស់វែង អភិរក្សអចិន្ត្រៃយ៍ ។<br>• រៀបចំប្រព័ន្ធវាយតម្លៃថ្លៃដីដែលមានលក្ខណៈចូលរួម តម្លាភាព និងទទួលស្គាល់ជាផ្លូវការដោយផ្អែកលើគុណភាពអំណោយផលពីធម្មជាតិនៃដី រួមបញ្ចូលទាំងអចលនវត្ថុនៅលើដីទាំងអស់ដើម្បីផ្តល់ជាមូលដ្ឋាន សម្រាប់ការលក់-ទិញ ការជួល ការវិនិយោគ ការឱ្យខ្ចីប្រាក់ការយកពន្ធ (ពន្ធប្រចាំឆ្នាំពន្ធលើការផ្ទេរលើការជួលលើប្រាក់ចំណេញលើដីធ្លីមិនប្រើប្រាស់ការកំណត់សេវាសុរិយោ ដីនិងការទូរទាត់សំណងជាដើម) និងបង្កើតក្របខណ្ឌគតិយុត្តទាក់ទងនឹងការគ្រប់គ្រងវិជ្ជាជីវៈវាយតម្លៃថ្លៃអចលនវត្ថុ ។<br>• បន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ ដែលធ្វើការបង្កបង្កើនផលជាលក្ខណៈគ្រួសារ ។ទន្ទឹមនេះត្រូវផ្តួចផ្តើមសិក្សាការយកពន្ធប្រចាំឆ្នាំ លើអចលនវត្ថុក្រៅពីដីកសិកម្មជាលក្ខណៈគ្រួសារដើម្បីរៀបចំ ច្បាប់ស្តីពីពន្ធលើដីធ្លី ។<br>• បន្តដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការតាមរយៈគណៈកម្មការរដ្ឋបាល គណៈកម្មការសុរិយោដីគ្រប់ លំដាប់ថ្នាក់ (ថ្នាក់ជាតិ ថ្នាក់រាជធានី-ខេត្តក្រុង-ស្រុក-ខណ្ឌ និងក្រុមចល័ត)និងអាជ្ញាធរជាតិ ដោះ ស្រាយវិវាទដីធ្លីជាពិសេស ចំពោះករណីវិវាទពហុភាគី ។ | |

| | | | |
|---|---|---|---|
| | | • ជំរុញការប្រមូលនិងចងក្រងបញ្ជីសារពើភ័ណ្ឌដីរដ្ឋ សម្រាប់បំរុងទុកក្នុងគោលដៅបែងចែកនិងប្រើប្រាស់ដីនាពេលបច្ចុប្បន្ននិងទៅអនាគត ប្រកបដោយសមធម៌តម្លាភាពនិងគណនេយ្យភាព ។<br>• បង្កើតប្រព័ន្ធផែនការរៀបចំដែនដី ដែលរួមមានប្លង់គោលឬផែនការរៀបចំដែនដី ថ្នាក់ជាតិថ្នាក់ភូមិភាគថ្នាក់ខេត្តនិងផែនការប្រើប្រាស់ដីនៅថ្នាក់ក្រោមជាតិ (ឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ) ដោយមានការចូលរួមពីគ្រប់ជំនាញនិងអ្នកពាក់ព័ន្ធដោយមានការព្រមព្រៀងគ្នាស្របតាមលក្ខណៈពីធម្មជាតិនៃដីនិងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដើម្បីធ្វើ ជាឧបករណសម្រាប់ពង្រឹងការគ្រប់គ្រង និង ត្រួតពិនិត្យការប្រើប្រាស់ដីនិងធនធាន ធម្មជាតិ ប្រកបដោយតម្លាភាព សមធម៌ និង ធានាចីរភាពបរិស្ថាន និង ដើម្បីគាំទ្រដល់ វិមជ្ឈការនិងវិសហមជ្ឈការនៃការរៀបចំដែនដី។ ទន្ទឹមនឹងនេះត្រូវជំរុញការរៀបចំផែនការអភិវឌ្ឍនសម្រាប់តំបន់ទីប្រជុំជននិងតំបន់ជនបទ ការកំណត់តំបន់ប្រើប្រាស់ដីតំបន់ កំណត់កម្ពស់អគារដែលអាចឬមិនអាចសាងសង់បានការត្រួតពិនិត្យប្លង់ទីតាំងសំណង់ដោយរួមបញ្ចូលទាំងនីតិវិធី រៀបចំដីមិនទាន់អភិវឌ្ឍ ។<br>• បង្កើតនិងអនុវត្តយុទ្ធសាស្ត្រនិងក្របខណ្ឌនៃផែនការបែងចែកដីធ្លី រយៈពេលមធ្យម និងវែង ដើម្បីបែង ចែកនិងប្រើប្រាស់ដី សម្រាប់គោលដៅសង្គមកិច្ចនិងសេដ្ឋកិច្ច ស្របតាមផែនការ ថ្នាក់ជាតិ ថ្នាក់ភូមិភាគ ថ្នាក់រាជ | |

| | | | | |
|---|---|---|---|---|
| | | ធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងថ្នាក់ឃុំ-សង្កាត់ ដោយ ធានាតម្លាភាព និងប្រសិទ្ធភាព ចៀសវាង ការជះឥទ្ធិពលអវិជ្ជមាន ដល់សង្គម និងបរិស្ថាន ទប់ស្កាត់ការប្រមូលទិញដីបង្កក ទុកដោយមិនប្រើប្រាស់ ដកហូតមកវិញដីរដ្ឋ ដែលបានចូលកាន់កាប់ដោយខុសច្បាប់លើមូលដ្ឋាននៃការពង្រឹងប្រសិទ្ធភាពអនុវត្ត គោលនយោបាយ និង ក្របខណ្ឌគតិយុត្ត ដែលមានជាធរមាន ជាពិសេសសារាចរណែនាំលេខ ០៦ស្តីពីការកាន់កាប់ ដីរដ្ឋ ដោយខុសច្បាប់ រួមទាំង ការរឹតបន្តឹង ការអនុវត្តកាតព្វកិច្ចពន្ធលើដីមិនប្រើប្រាស់ ។<br>• ជំរុញការបែងចែកដីធ្លីសម្រាប់គោលដៅសង្គមកិច្ច ឱ្យបាន ១០.០០០គ្រួសារ នៅឆ្នាំ២០១៣ ដើម្បីរួមចំណែកដោះស្រាយបញ្ហាសង្គម និងកិច្ចការពារជាតិ ។<br>• ត្រួតពិនិត្យការអនុវត្តកិច្ចសន្យាផ្តល់សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ក៏ដូចជាសម្បទានដីសេដ្ឋកិច្ច ដែលលើសពីការកំណត់នៃច្បាប់ភូមិបាល និងសម្បទានដីសេដ្ឋកិច្ចថ្មីដែលគ្រោង នឹងបន្តផ្តល់លើមូលដ្ឋាននៃ អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និងក្របខណ្ឌគតិយុត្តដែល មានជាធរមានឱ្យបានច្បាស់លាស់ ដោយមានការវាយតម្លៃពីផលប៉ះពាល់សង្គម និងបរិស្ថាន បានគ្រប់ជ្រុងជ្រោយ និងមានតម្លាភាព មានការចូលរួមពីគ្រប់អ្នកដែលមានចំណែកពាក់ព័ន្ធ ជាពិសេស សហគមន៍ប្រជាពលរដ្ឋក្នុងតំបន់នោះ ។<br>• បន្តអនុវត្តភាពជាដៃគូរវាងម្ចាស់ចំការខ្នាតតូច និងកសិដ្ឋានដាំដុះ និងសាជីវកម្មនៅក្នុង ការ | |

| | | | |
|---|---|---|---|
| | | ងារកសិផលិត-កម្មនិងរវាង សម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីសង្គមកិច្ច ដើម្បីបង្កើត ការងារធ្វើ និងបង្កើតទីផ្សារ សម្រាប់អ្នករស់នៅក្នុងមូលដ្ឋាន ។ | |

* លេខទំព័រសំដៅលើលេខទំព័រដែលមានប្រើនៅក្នុងផយអជបច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី១**ផយអជ**បច្ចុប្បន្នកម្ម ២០០៩-២០១៣

សម្រាប់ព័ត៌មានទំនាក់ទំនង:

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
**លោក ប៉ែន រង្សី ប្រធានកម្មវិធីដីធ្លី និងជីវភាព**
ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខ: (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល: ngoforum@ngoforum.org.kh
raingsey@ngoforum.org.kh
គេហទំព័រ: http://www.ngoforum.org.kh
អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ។

### កំណែទម្រង់ព្រៃឈើ

ក្នុងនាមបណ្តាញអង្គការសង្គមស៊ីវិលស្តីពីព្រៃឈើនិងចំការឈើដាំដែលមានសមាជិក ៣៤ អង្គការដែលធ្វើការទាក់ទង និង វិស័យព្រៃឈើនៅទូទាំង ប្រទេស យើងបានសង្កេតឃើញថានៅ ក្នុងប្រទេសកម្ពុជា ជារួមមានបញ្ហាធំៗពីរ គឺ:

១. ការផ្តល់ដីសម្បទានសេដ្ឋកិច្ច:
   បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រើប្រាស់យន្តការផ្តល់ដីសម្បទានសេដ្ឋកិច្ចរាប់រយកន្លែងក្នុងប្រទេស ដើម្បីរកចំណូលសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងចូលរួមកាត់បន្ថយភាពក្រីក្រ ។ប៉ុន្តែការផ្តល់ដីសម្បទានសេដ្ឋកិច្ចដ៏ច្រើនមហិមានេះបាននឹងកំពុងជះឥទ្ធិពលអវិជ្ជមានយ៉ាងច្រើនដល់សហគមន៍ តែផ្ទុយទៅវិញផ្តល់ផលប្រយោជន៍តិចតួចប៉ុណ្ណោះសំរាប់ប្រជាជនកម្ពុជា។ ម្យ៉ាងវិញទៀតតាមរយៈការអង្កេតកន្លងមកយើងកត់សំគាល់ ឃើញថាការសិក្សា ក៏ដូចជារបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម មិនបានមានការចូលរួមអោយបានទូលំទូលាយពីសហគមន៍ដែលរស់នៅក្នុងឬក្បែតំបន់ផ្តល់សម្បទាននោះទេពោលគឺមិនមានការពិគ្រោះយោបល់អោយបានត្រឹមត្រូវទេមុនពេលផ្តល់ដីសម្បទានសេដ្ឋកិច្ច។ សម្បទានដីសេដ្ឋកិច្ចបានរួមចំនែកយ៉ាងក្លាំងក្លា ដល់ការកាប់បំផ្លាញព្រៃឈើនៅក្នុង ប្រទេសកម្ពុជា។ ដែលមាន

២. បញ្ហាមួយទៀតគឺថា ខ្វះខាតផែនការប្រើប្រាស់ដីធ្លីសំរាប់ប្រទេសទាំងមូល ដោយមិនមានបែងចែកតំបន់ណាសំរាប់សម្បទានសេដ្ឋកិច្ចសំរាប់សម្បទានរ៉ែ តំបន់ការពារតំបន់សក្តានុពលសំរាប់សហគមន៍ព្រៃឈើដីសាធារណៈ របស់រដ្ឋជាដើម។ល។ បច្ចុប្បន្ននេះមានជំលោះព្រំប្រទល់ដោយមានការទាមទារជាន់គ្នាសំរាប់តំបន់ដីតែមួយកន្លែង ដោយសារការសហការណ៍របស់ក្រសួងពាក់ព័ន្ធនៅមានភាពខ្វះចន្លោះ។

បណ្តាញអង្គការសង្គមស៊ីវិលយើងធ្លាប់បានដាក់ជូនរួចហើយនូវសេចក្តីថ្លែងការណ៍ទាក់ទងនិងកម្មវិធីព្រៃឈើជាតិ ដែលបង្ហាញអំពី គោលជំហរ ការព្រួយបារម្ភ និង អនុសាសន៍ របស់សង្គមស៊ីវិល ដល់រាជរដ្ឋាភិបាលតាមរយៈ អ្នកសំរបសំរួលកម្មវិធីព្រៃឈើជាតិនៅខេត្តកំពង់ចាម កាលពីខែ មិថុនា ឆ្នាំ ២០០៩។

ក្រៅពីនោះបណ្តាញក៏ធ្លាប់បានដាក់ជូន នូវ អនុសាសន៍ របស់អង្គការសង្គមស៊ីវិលជូនរាជរដ្ឋាភិបាលតាមរយៈរដ្ឋបាលព្រៃឈើខណៈពេលដែល រាជរដ្ឋា- ភិបាលផ្សព្វផ្សាយរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០០៨ ស្តីពី *ផយអជ* ២០០៦-២០១០ ដើម្បីចូលរួមជាធាតុចូល ក្នុង *ផយអជ* បច្ចុប្បន្នកម្ម ២០០៩-២០១៣ ប៉ុន្តែមិនមានការមិនទាន់មានការឆ្លើយតបនៅឡើយទេ។

តាមរយៈសេចក្តីព្រាងទី១នៃ *ផយអជ* បច្ចុប្បន្នកម្ម ២០០៩-២០១៣ យើងខ្ញុំសូមកោតសរសើររាជរដ្ឋាភិបាលកម្ពុជាដែលបានខិតខំប្រឹងប្រែងគ្រប់ មធ្យោបាយដើម្បីធានាបាននូវនិរន្តរភាពព្រៃឈើ និងធនធានធម្មជាតិ និងទទួលស្គាល់នូវបញ្ហាប្រឈមដែលបានលើកឡើងក្នុងឯកសារនេះ។ ប៉ុន្តែសំរាប់ ពេលនេះបណ្តាញអង្គការសង្គមស៊ីវិលយើងខ្ញុំសូមដាក់ជូននូវ អនុសាសន៍មួយចំនួនដើម្បីជាធាតុចូលម្តងទៀត សំរាប់ *ផយអជ* បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ដូចខាងក្រោម:

| លេខទំព័រ* | លេខកថាខ័ណ្ឌ** | អត្ថបទដើមដកស្រង់ពីសេចក្តីព្រាងលើកទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ | យោបល់អង្គការមិនមែនរដ្ឋាភិបាល ឬការស្នើឱ្យមានការកែប្រែ |
|---|---|---|---|
| ៦០ | ១១៦ | ការអនុវត្ត ច្បាប់ និងបទប្បញ្ញត្តិគ្រប់គ្រងព្រៃឈើ ដោយមានកិច្ចសហការណ៍ល្អជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធធនធានព្រៃឈើត្រូវបានគ្រប់គ្រងដោយហ្មត់ចត់ ការការពារត្រូវបានបង្កើន និងទប់ស្កាត់បានការទន្ទ្រានកាន់កាប់ដីព្រៃដោយខុសច្បាប់ ។នៅឆ្នាំ២០០៨ | - សូមស្នើអោយរាជរដ្ឋាភិបាលផ្សព្វផ្សាយទូលំទូលាយនូវ ផែនការប្រើប្រាស់ ឬកាប់ឈើនៅទូទាំងប្រទេស។<br>- ស្នើអោយ រដ្ឋាភិបាល មានការកំនត់ភាគរយ |

| | | | |
|---|---|---|---|
| | | រដ្ឋបាលព្រៃឈើ បានធ្វើការបែងចែកតំបន់ព្រៃគប់ចំនួន ៩កន្លែង ដែល នៅក្រៅតំបន់ព្រៃសម្បទាន សម្រាប់ប្រជាជនប្រើប្រាស់ មាន ចំនួនប្រមាណ ២៦១.២៧០មក ។ ការដាំព្រៃឈើឡើងវិញ សហគមន៍ព្រៃឈើ ការកំណត់ព្រំប្រទល់ព្រៃឈើ ការស្រាវជ្រាវ សត្វព្រៃនិងអភិរក្សព្រៃឈើ បានដំណើរការតាម ផែនការកំណត់ ។ ក៏ប៉ុន្តែ ការកាប់បំផ្លាញព្រៃដើម្បីកាន់កាប់ដីដោយខុសច្បាប់នៅ បន្តកើតមាន ។ កសួងមហាផ្ទៃ បានដើតួនាទីដ៏សំខាន់ក្នុងការណែនាំ ដល់អាជ្ញាធរមូលដ្ឋានគ្រប់កម្រិត ដើម្បីពង្រឹងស្ថិតិ ការផ្លាស់ប្តូរ ទីលំនិងការតាំងទីលំនៅថ្មី និង កណត់ មិន ឱ្យបែងចែកដីព្រៃ សម្រាប់ គាលបណំ ងណាផ្សេង ។ ការអនុវតអ្ត នុក្រឹត្យស្តីពី តួនាទីសម្រាប់ប្រើប្រាស់ដីព្រៃរបស់រដ្ឋក្នុងការដាំដុះព្រៃឡើងវិញ នឹងរួមចំណែកដើម្បីឈានទៅ សម្រេចបានគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍កម្ពុជា ដែលដីគ្របដណ្តប់ដោយព្រៃឈើមានទំហំ ៦០ភាគរយ នៅឆ្នាំ ២០១៥ ។ | ព្រៃឈើដែលត្រូវរក្សាទុកតែលើ ***<u>ព្រៃឈើ ធម្មជាតិ</u>*** សុទ្ធសាធ ដោយមិនរាប់ ចំការ ឈើដាំ ថាជា **ព្រៃឈើ** ទេ។ យើងយល់ថាចំការឈើដាំ មិនមែនជាព្រៃឈើទេ។ សូចនាករនៃ គោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍កម្ពុជា ចាំបាច់ត្រូវកែសំរួលឡើងវិញដើម្បីកំណត់កិច្ចព្រមព្រៀង លើភាគរយនៃ **<u>ព្រៃឈើ</u>** ដែលត្រូវរក្សាទុកពោល គឺអាចតិចជាង ៦០% ប៉ុន្តែត្រូវគិតតែលើព្រៃឈើ ធម្មជាតិសុទ្ធ។ ព្រោះថាព្រៃឈើធម្មជាតិ សំខាន់ក្រៃលែងចំពោះ ស្ថេរភាព បរិស្ថានរបស់ ប្រទេស។ ដោយសារ ប្រជាជនភាគច្រើនគឺពឹង អាស្រ័យ លើធនធាន ធម្មជាតិដូច្នេះប្រសិនបើ មាន អស្ថេរភាព នៅក្នុងបរិស្ថាន នឹងនាំទៅដល់ ផលប៉ះពាល់ អវិជ្ជមានកាន់តែច្រើនឡើងលើ ប្រជាជនកម្ពុជា ទាំងមូលតែម្តង។ |
| ៦១ | ១១៧ | ទទ្ធិមនឹងវឌ្ឍនភាព ដែលរដ្ឋបាលព្រៃឈើ សម្រេចបាន នៅមានបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម :<br>- ខ្វះខាតធនធានមនុស្ស និងការលើកទឹកចិត្តដល់មន្ត្រីបម្រើការនៅតំបន់ដាច់ស្រយាល ។<br>- ខ្វះខាតនូវថវិកាសម្រាប់ដំណើរការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ ។<br>- ខ្វះខាតទីស្នាក់ការ និងមធ្យោបាយសម្រាប់បម្រើការងារ ។<br>- ទទួលរងការគម្រាមកំហែងពីជនល្មើសអ្នកមានអំណាច ។<br>- ការងារបង្ក្រាបបទល្មើស មានការលំបាកពីព្រោះជនប្រព្រឹត្ត បទល្មើសតែងតែផ្លាស់ប្តូរវិធីសាស្ត្រក្នុងការដឹកជញ្ជូន និងបំផ្លាញព្រៃឈើក្រោមរូបភាពផ្សេងៗ ។<br>- ការកំណត់ព្រំប្រទល់ និងការបោះបង្គោលតែងជួបប្រទះការ លំបាកនិងមានវិវាទជាមួយជនល្មើសព្រមទាំងលួចវាយបំផ្លាញ បង្គោលព្រំដែលបានបោះរួច ។ល។ | មានបញ្ហាប្រឈមមួយទៀតដែលរដ្ឋបាលព្រៃឈើ បាន និងកំពុងជួបប្រទះក្នុងពេល បច្ចុប្បន្ន គឺ មាន ***អជ្ញាធរពាក់ព័ន្ធ ខ្លះ កំពុង ចូលរួមឃុប ឃិតជាមួយជនល្មើស ក្នុងការ កាប់ឈើ និង ដឹកជញ្ជូនឈើ ខុសច្បាប់***។ ដែលនេះជាកត្តារាំងស្ទះ ដ៏ធំសំរាប់ការអនុវត្តន៍ច្បាប់របស់រដ្ឋបាលព្រៃឈើខ្លួនឯង និង នាំអោយការគ្រប់គ្រងព្រៃឈើប្រកបដោយ ចីរភាព មិនបានជោគជ័យ។ |
| ២០៦ និង ២០៧ | ៤១៦-៤១៧-៤១៨- | **គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤** | ស្នើសុំអោយរាជរដ្ឋាភិបាលកម្ពុជាបង្ហាញអំពីឆន្ទៈ ក្នុងការអនុវត្តន៍កម្មវិធីព្រៃឈើជាតិនៅក្នុង ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣។ |

| | | | |
|---|---|---|---|
| | និង ៤១៩ | | |
| ២០៧ និង ២០៨ | ៤២០ | **ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់ រាជរដ្ឋាភិបាល កម្ពុជា សម្រាប់ នីតិកាលទី៤ នៃរដ្ឋសភា រដ្ឋបាលព្រៃឈើនឹងរៀបចំ ផែនការសកម្មភាពសម្រាប់អនុវត្ត ដូចខាងក្រោម ៖** | ផែនការសកម្មភាពសំរាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សំរាប់កំនែទំរង់ព្រៃឈើមិនទាន់មានលក្ខណៈលំអិតដែលអាច វាស់វែងបានប៉ុន្តែហាក់ដូចជាចំលងពីគោលនយោបាយ ទៅវិញ ។ស្នើសុំអោយរាជរដ្ឋាភិបាលកម្ពុជាបង្ហាញពីផែនការលំអិតដែលអាចវាស់វែងបាននៅក្នុងផែនការ ។ |
| | | - បន្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ នៃកម្មវិធីលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើ ឱ្យបានកាន់តែទូលំទូលាយ ។ | ស្នើអោយមានការពិនិត្យឡើងវិញអោយបាន ច្បាស់លាស់និងឯករាជ្យលើប្រសិទ្ធិភាពនៃ សហគមន៍ព្រៃឈើនៅក្នុងស្ថានភាពបច្ចុប្បន្ននេះ៖ សហគមន៍ព្រៃឈើពេលខ្លះមានការលំបាកក្នុង ការអនុវត្តន៍ការងាររបស់ខ្លួនដោយសារតែមានការប៉ះពាល់ជាមួយនិង ក្រុមហ៊ុនសម្បទាន ។បញ្ហា សំខាន់គឺការអនុវត្តន៍ជាក់ស្តែងរបស់ក្រុមហ៊ុនសម្បទានដី និងរ៉ែ មិនសមស្រប និង ច្រើនតែរំលោភច្បាប់ ។ ក្នុងស្ថានភាពទាំងនេះ ដី និងព្រៃដែលមិនស្ថិតនៅក្រោម សហគមន៍ព្រៃឈើ ច្រើនតែត្រូវបានគេបំផ្លាញ ឬ ទាញ យកថាជាដីសម្បទាន ។ សហគមន៍ព្រៃឈើគឺគ្មានប្រសិទ្ធិភាពនៅក្នុងស្ថានភាពទាំងនេះ ឬ នៅក្នុងស្ថានភាពដែលនៅក្នុងនោះមានតែដីមួយដុំតូច នៃផ្ទៃដីផ្សេងត្រូវបានទទួល ស្គាល់ថាជាព្រៃឈើសហគមន៍ ។ |
| | | - ផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជន ក្នុងការដាំដុះព្រៃឯកជនដែលមានលក្ខណៈសេដ្ឋកិច្ច ដោយមានបទដ្ឋានបច្ចេកទេសច្បាស់លាស់ នៅក្នុងតំបន់ព្រៃឈើរិចរិល ។ | ស្នើសុំអោយមានការកំនត់និយមន័យនិងវិសាលភាពនៃពាក្យ ***ព្រៃឯកជន*** ។តើការដាំដុះព្រៃឯកជនដែលមានលក្ខណៈសេដ្ឋកិច្ចសំដៅទៅលើ ចំការឈើដាំនៅលើដីសម្បទាន សេដ្ឋកិច្ច ឬយ៉ាងណា? |
| | | - បន្តយកចិត្តទុកដាក់តាមដានត្រួតពិនិត្យ ការធ្វើអាជីវកម្មព្រៃឈើសម្បទាន ឱ្យសមស្របតាមបទដ្ឋានអន្តរជាតិ តាមរយៈការស្វែងរកជំនួយពីក្រៅប្រទេស ផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និងតាមរយៈការអនុញ្ញាតឱ្យសង្គមស៊ីវិលបានចូលរួមក្នុងការតាមដានត្រួតពិនិត្យនេះ ដោយសកម្មនិងសមស្រប ។ | នៅក្នុងកថាខ័ណ្ឌលេខ ៤១៦ បានលើកឡើងថារដ្ឋាភិបាលបានផ្អាកការធ្វើអាជីវកម្មព្រៃឈើ ប៉ុន្តែនៅក្នុង កថាខ័ណ្ឌលេខ ៤១៨ បែជាលើកឡើងថារដ្ឋាភិបាលនឹងបន្តតាមដានត្រួតពិនិត្យព្រៃសម្បទាន ។ តើនេះមានន័យថារាជរដ្ឋាភិបាលនឹងអនុញ្ញាតិ អោយក្រុមហ៊ុនសម្បទានព្រៃឈើដំនើរការសកម្មភាពឡើងវិញឬយ៉ាងណា? តើ សង្គមស៊ីវិលចូលរួមក្នុងការតាមដានត្រួតពិនិត្យតាមរបៀបណា? តើរដ្ឋាភិបាលនឹងជ្រើសរើសអង្គការសង្គមស៊ីវិលណាខ្លះចូលរួម? |

| | | | |
|---|---|---|---|
| | | - បន្តយកចិត្តទុកដាក់ក្នុងការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងចាត់វិធានការម៉ឹងម៉ាត់ចំពោះបទល្មើសព្រៃឈើព្រមទាំងបន្តអប់រំប្រជាជនឱ្យយល់ពីកាតព្វកិច្ចការពារព្រៃឈើនិងបញ្ឈប់ការកាប់រានព្រៃដោយខុសច្បាប់ ។ | ស្នើអោយមានការពិនិត្យ និង ដោះស្រាយតាមផ្លូវច្បាប់ អោយបានឆាប់ ចំពោះពាក្យ បណ្តឹងរបស់សហគមន៍ដែលពាក់ព័ន្ធនិងព្រៃឈើបានដាក់ជូនរាជរដ្ឋាភិបាលរួចហើយៈ ប្រការនេះគចាំបាច់ណាស់ចំពោះភាព អាចទុកចិត្ត បាននៃផែនការគ្រប់គ្រងព្រៃ ឈើ និងដីធ្លីនៅកម្ពុជា។ |
| | | -បង្កើនប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុងទុក និងធានាថាព្រៃបម្រុងនោះ ត្រូវបានទទួលការការពារ និងការអភិវឌ្ឍន៍សមស្រប រួមទាំងទេសចរណ៍ធម្មជាតិ ដើម្បី បង្កើតការងារ និងប្រភពចំណូលបន្ថែម ជូនប្រជាជន ។ ទន្ទឹមនឹងនេះ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ក៏ត្រូវបានបន្តការយកចិត្តទុកដាក់ខ្ពស់ផងដែរ ។ រាជរដ្ឋាភិបាលកម្ពុជា នឹងកៀរគរ ធនធាន ការគាំទ្រ និងហិរញ្ញប្បទាន នានា ដើម្បីចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពិភពលោក ក្នុងការដោះស្រាយ បញ្ហាបម្រែបម្រួលអាកាសធាតុ ។ | ស្នើអោយមាន ផែនការច្បាស់លាស់មួយ សម្រាប់ការពង្រីកការអភិរក្សព្រៃឈើសម្រាប់ ការរក្សាទុកនិងការដាក់ដោយឡែកនូវការបោននៅគ្រប់ខេត្តទាំងអស់នៅ ប្រទេសកម្ពុជា និង ស្នើអោយមានការពិនិត្យមើលដោយប្រយ័ត្នប្រយែងនូវយន្តការ កាត់បន្ថយការ បញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការ បាត់បង់និងរិចរិលព្រៃឈើ **(REDD)** ។ |

* លេខទំព័រសំដៅលើលេខទំព័រដែលមានប្រើនៅក្នុងផយអជបច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី១**ផយអជ**បច្ចុប្បន្នកម្ម ២០០៩-២០១៣

សម្រាប់ព័ត៌មានទំនាក់ទំនងៈ

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
**លោក ប៉ែន រង្សី ប្រធានកម្មវិធីដីធ្លី និងជីវភាព**
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែលៈ ngoforum@ngoforum.org.kh
raingsey@ngoforum.org.kh
គេហទំព័រៈ http://www.ngoforum.org.kh
អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ។

## វិស័យកសិកម្ម

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| បុព្វកថា | | - ស្ថិតិស្តីពីការកាត់បន្ថយភាពក្រីក្រ និងកំណើននៃការបែងចែកតាមទីក្រុង/ជនបទ /ខេត្ត គឺចាំបាច់ (សូមកត់សម្គាល់ថាចំណុចនេះត្រូវបានធ្វើនៅក្នុងស្ថិតិរបស់ប្រទេស និងក្រាហ្វិក សូចនាករភាពក្រីក្រ)<br>-លទ្ធផលនៅក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទតាមរយៈកំណើនផលិតភាព នឹងត្រូវសម្រេចបានតាមរយៈការវិនិយោគលើវិស័យគាំទ្រនានា ក៏ដូចជាការធានា ឱ្យបាន ថាកិច្ចប្រឹងប្រែងលើកកម្ពស់ផលិតភាពយកចិត្តទុកដាក់លើនិរន្តរភាពបរិស្ថានការរៀបចំគ្រោងការណ៍តាមបែបចូលរួម និងប្រកបដោយសមធម៌ យេនឌ័រ។ |
| ២៩ | ៩៦ | កម្មវិធីទី ៣: "ពង្រឹងស្ថាប័ន ក្របខ័ណ្ឌគតិយុត្តិ និងការអភិវឌ្ឍធនធានមនុស្ស។" ការយកចិត្តទុកដាក់ជាពិសេសនិងអាទិភាព គប្បីត្រូវបានផ្តល់លើការអភិវឌ្ឍធនធាន មនុស្សនៅតាមតំបន់ជនបទ។ កម្មវិធីថ្មីមួយក៏គប្បីត្រូវបានពិចារណា និងបន្ថែម ផងដែរលើគោលដៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលផ្តោតលើ ការកែលម្អនិងការពង្រឹងការស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម។ |
| ២៩ | ៩៩ | សម្រាប់ការកែលម្អ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្មសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម គប្បីត្រូវបានផ្សព្វផ្សាយជូន ជាសាធារណៈ រួមជាមួយនឹងការពិគ្រោះយោបល់សាធារណៈ ហើយគប្បីចាត់ អាទិភាពលើការបញ្ចប់សេចក្តីព្រាងច្បាប់នេះ។<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គប្បីផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធបានចូល រួមនៅក្នុងកិច្ចដំណើការ កិច្ចពិគ្រោះយោបល់ និងការអនុវត្ត។ |
| ៣០ | ១០០ | បញ្ហាប្រឈមមួយដែលរាជរដ្ឋាភិបាលកម្ពុជាគប្បីខិតខំដោះស្រាយ គឺការប្រើ ប្រាស់ថ្នាំកសិកម្មមិនស្របច្បាប់ ដែលភាគច្រើនត្រូវបាននាំចូលដោយមិនស្របច្បាប់ ពីប្រទេសវៀតណាម និងថៃ។ រាជរដ្ឋាភិបាលគប្បីព្យាយាមកាត់បន្ថយការប្រើ ប្រាស់ថ្នាំកសិកម្មមិនស្របច្បាប់ ដោយធានាឱ្យបានថាថ្នាំកសិកម្មទាំងអស់ត្រូវមាន ស្លាកសញ្ញាត្រឹមត្រូវជាភាសាខ្មែរ កសិករត្រូវបានទទួលការអប់រំអំពីហានិភ័យនានា ទាក់ទិននឹងការប្រើប្រាស់ថ្នាំកសិកម្ម ការគ្រប់គ្រងនិងត្រួតពិនិត្យតាមច្រកព្រំដែន លើការនាំចូលថ្នាំកសិកម្មក្នុងប្រទេសកម្ពុជា។ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលកម្ពុជា គប្បីលើកទឹកចិត្តដល់ការប្រើប្រាស់ថ្នាំផ្សំពីរុក្ខជាតិ និងជីធម្មជាតិ ដើម្បី |

| | | |
|---|---|---|
| | | កសិកម្ម ប្រកបដោយនិរន្តរភាព។ បញ្ហាប្រឈមមួយទៀត គឺការធ្វើឱ្យកខ្វក់ទឹកក្រោមដី និងការហូរច្រោះដីស្រទាប់លើ ដែលបណ្តាលមកពីការប្រើប្រាស់ជីគីមី និងថ្នាំ កសិកម្មមិន ស្រប។ |
| ៤៣ | ១៥២ | រាជរដ្ឋាភិបាលកម្ពុជាគប្បីអភិវឌ្ឍន៍ផែនការមេនៃហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រពដែលផ្អែកលើការផ្តល់អាទិភាពសម្រាប់តំបន់រាំងស្ងួត និងផ្អែកលើសេចក្តី ត្រូវការនៃកសិដ្ឋានជាលក្ខណៈគ្រួសារ ។រាជរដ្ឋាភិបាលគប្បីលើកទឹកចិត្តដល់ប្រព័ន្ធ ស្រោចស្រពខ្នាតតូចដោយផ្អែកលើបច្ចេកវិទ្យាស្រោចស្រពប្រើបរិមាណទឹកតិច ដើម្បីធានាបាននូវនិរន្តរភាពទឹកនៅក្នុងប្រទេសកម្ពុជា។ |
| ១១៦ | ៣៩៣ | ដោយសារគោលដៅមួយនៃគោលដៅសំខាន់ៗនៃវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការពន្លឿនការកាត់បន្ថយភាពក្រីក្រ យើងខ្ញុំសូមជម្រុញឱ្យរាជរដ្ឋាភិបាល លើកទឹកចិត្តដល់ការធ្វើកសិកម្មប្រកបដោយនិរន្តរភាព និងការកែលម្អសន្តិសុខ ស្បៀងរយៈពេលវែងសម្រាប់ប្រទេសកម្ពុជា ដែលលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកសិកម្ម កសិដ្ឋានលក្ខណៈគ្រួសារជាជាងកសិ-ឧស្សាហកម្ម។ |
| ១១៧ | ៣៩៨ | សកម្មភាពចំនួន ៣ ដែលស្នើរសុំបន្ថែមទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួមមាន:<br>១. ផ្តល់ការគាំទ្រ និងពង្រឹងសមាគមអ្នកផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្មដោយ កសិករ ដូចជា (ការបន្សុតគ្រាប់ពូជ ជីធម្មជាតិ ការទុកដាក់ក្រោយពេល ប្រមូលផល)<br>២. ផ្តល់គាំទ្រ និងពង្រឹងសហគ្រាសកសិករលើសេវាផ្តល់ឥណទាន ម៉ាស៊ីនកិន ស្រូវ និងការទុកដាក់ស្រូវ។<br>៣. ពង្រឹងសមត្ថភាពយុវជននៅតំបន់ជនបទឱ្យក្លាយទៅជាសហគ្រិនកសិកម្ម។ |
| ១១៨ | ៣៩៨ | នៅក្នុងលេខ ៤ គប្បីផ្លាស់ប្តូរពាក្យពីបច្ចេកវិទ្យាថ្មី ទៅជាបច្ចេកទេសសមស្រប (ជំនាញ វិធីសាស្ត្រ និងដំណើរការ) ដើម្បីកុំអោយមានការយល់ច្រឡំទៅដល់ ការណែនាំអោយប្រើប្រាស់សារធាតុគីមី និងគ្រាប់ពូជកែច្នៃហ្សែន។ វិនិយោគិនក្នុងស្រុកនិងបរទេស គប្បីពិចារណាអំពីកិច្ចការពារបរិស្ថាន ។គប្បីបង្កើតយន្តការសម្រាប់អនុវត្តនៅក្នុងអំឡុងពេលមានការប្រែប្រួលអាកាសធាតុ ដូចជាការបន្សាំ និងការបន្ថយផលប៉ះពាល់ក្នុងវិស័យកសិកម្ម តាមរយៈការស្វែងរកវិធីសាស្ត្រធ្វើកសិកម្មប្រកបដោយនិរន្តរភាពនិងលើកទឹកចិត្តដល់ពូជ ដំណាំដែលមានភាពធន់ទ្រាំទៅនឹងភាពរាំងស្ងួត។ ថវិកា និងជំនួយឥតសំណងសម្រាប់ការបន្សាំ និងការប្រែប្រួលអាកាសធាតុ គប្បីត្រូវបានកំណត់ជាអាទិភាពសម្រាប់កសាងប្រព័ន្ធ ស្រោចស្រពខ្នាតតូច។ |

* លេខទំព័រសំដៅលើលេខទំព័រដែលមានប្រើនៅក្នុងផយអជបច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី១**ផយអជ**បច្ចុប្បន្នកម្ម ២០០៩-២០១៣

**ព័ត៌មានសម្រាប់ទំនាក់ទំនង:**

សម្រាប់ព័ត៌មានបន្ថែមស្តីពីបញ្ហាកសិកម្ម ដែលបានលើកឡើងក្នុងឯកសារនេះ សូមទំនាក់ទំនង:


វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia)

លោកស្រី **ម៉ែន វណ្ណាវី**

គំរោងកាត់បន្ថយថ្នាំកសិកម្ម និងកសិកម្មនិរន្តរភាព

ទូរស័ព្ទលេខ: (៨៥៥)-១២ ៤៨ ៣៣ ៦៤

អ៊ីម៉ែល: vannavy@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh

អង្គការសេដាក CEDAC

លោក **ស៊ឹម សាមឿន**

នាយកកម្មវិធីជាន់ខ្ពស់

ទូរស័ព្ទលេខ: (៨៥៥)-១៦ ៦១ ៨៩ ៧៩

អ៊ីម៉ែល: simsm@online.com.kh

គេហទំព័រ: www.cedac.org.kh

## វិស័យនេសាទ

| ទំព័រ* | កថាខ័ណ្ឌ - លេខ** | អត្ថបទដើមស្រង់ពីសេចក្តីព្រាងទីមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ | យោបល់របស់អង្គការមិនមែនរដ្ឋាភិបាល |
|---|---|---|---|
| vi | | | ស្ថិតិជលផលមិនស្របគ្នាជាមួយនឹងទិន្នន័យរបស់ SPF |
| ២៩ | ៩៥ | កំណែទម្រង់វិស័យជលផលៈ លទ្ធភាពប្រើប្រាស់ប្រកបដោយនិរន្តរភាព (sustainable access) | តើរាជរដ្ឋាភិបាលកម្ពុជាចង់មានន័យដូចម្តេចចំពោះពាក្យ "លទ្ធភាពប្រើប្រាស់ប្រកបដោយនិរន្តរភាព (sustainable access) "សម្រាប់អ្នកណា? តើយន្តការអ្វីខ្លះត្រូវបានស្នើឡើងដើម្បីធានាធ្វើឱ្យសម្រេច ចំណុចនេះ? |
| | ៩៦ | កម្មវិធីទី iv: ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព | ចាំបាច់ត្រូវមានលក្ខណៈច្បាស់លាស់អំពីនិយមន័យនៃពាក្យ *ប្រកបដោយនិរន្តរភាព* ដែលកំពុងត្រូវបានប្រើ, ពាក្យ *ធំក្លៀវក្លា* (*resilient*) ប្រហែលជាល្អជាង ដោយសារពាក្យនេះពាក់ព័ន្ធនឹងភាពចាំបាច់នៃការឆ្លើយតបទៅនឹងការផ្លាស់ប្តូរ ជាពិសេសនៅពេលឆ្លើយតបទៅនឹងធនធានជលផល និងការប្រែប្រួលអាកាសធាតុ, តើវិស័យជលផលនិងអ្នកនេសាទកម្ពុជាត្រូវឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុយ៉ាងដូចម្តេច? |
| ៣៤ | ១១៤ | ៦៥០.០០០ តោន | ៤៧១.០០០ ដូចមានលើកឡើងនៅក្នុង SPF ១០ ឆ្នាំនៃរដ្ឋបាល ជលផល |
| | ១១៤ | សហគមន៍នេសាទចំនួន ៤៦៨ | ប្តូរទៅជា ៤៦៩ ដូចនៅក្នុង SPF |
| | ១១៤ | ៤៣៣ ទឹកសាប | ប្តូរទៅជា ៤៣៤ ដូចនៅក្នុង SPF |
| ៣៤ | ១១៥ | | ចាំបាច់ត្រូវមានការដាក់បញ្ចូលអន្តរវិស័យ នូវផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុរួមទាំងការលើកឡើងលម្អិតអំពីយុទ្ធសាស្ត្រនានាដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងគ្រោងដើម្បីដោះស្រាយផលប៉ះពាល់ ជាពិសេសលើមុខរបរនេសាទនៅក្នុងតំបន់បឹងទន្លេសាប និងតាមបណ្តោយដងទន្លេមេគង្គ ពីផលប៉ះពាល់ដែលអាចមានលើសហគមន៍នេសាទ នៅតំបន់ឆ្នេរសមុទ្រដែលបណ្តាលមកពីការឡើង |

| | | | |
|---|---|---|---|
| | | | កម្ពស់ទឹកសមុទ្រ ការហូរចូលទឹកប្រៃកង្វះការប្រតិបត្តិច្បាប់ ប្រកបដោយប្រសិទ្ធភាពកង្វះការផ្តល់អំណាចជូនដល់ការធ្វើនេសាទរបស់សហគមន៍ដើម្បីបញ្ឈប់ការប្រើប្រាស់ឧបករណ៍ខុសច្បាប់។ ចាំបាច់ត្រូវមានការទទួលស្គាល់ច្បាស់លាស់ដោយរាជរដ្ឋាភិបាលកម្ពុជា និងភាគីខណ្ឌជលផលខេត្ត លើការផ្លាស់ប្តូរដ៏ជ្រាលជ្រៅ ចំពោះស្ថានភាពជលផលតាមបណ្តោយដងទន្លេមេគង្គកម្ពុជា មកពីការអភិវឌ្ឍវារីអគ្គិសនីទាំងនៅតាមទំនប់ដៃទន្លេ និងពីការគ្រោងអភិវឌ្ឍវារីអគ្គិសនីលើទន្លេ។ ពុំមានការលើកឡើងអំពីរបៀបដែលរាជរដ្ឋាភិបាលកម្ពុជា គ្រោងដោះស្រាយលើផលប៉ះពាល់ដែលអាចកើតមានចំពោះប្រជានេសាទរាប់លាននាក់។ |
| ៣៥ | ១១៨ | | គប្បីដាក់បញ្ចូលការលើកឡើងជាក់លាក់ណាមួយ អំពីការអភិរក្ស និងការគ្រប់គ្រងជីវចម្រុះជលជាតិ និងសារៈ-សំខាន់នៃជលផល និងផលិតផលជលជាតិចំពោះសុខមាល-ភាពរបស់ប្រជាជនកម្ពុជារាប់លាននាក់ និង ប្រការដែលថាតើចំណុចនេះនឹងទទួលរងផលប៉ះពាល់ចម្រុះ និងអន្តរវិស័យយ៉ាងដូចម្តេច ពីការប្រែប្រួលអាកាសធាតុ និង ការកែប្រែទេសភាពផ្សេងទៀត។ |
| | ៤០៩<br><br>៤១១ | សហគមន៍នេសាទចំនួន ៥០៩ | មិនដូចតួលេខមុន ឬ ស្ថិតិរបស់ SPF (កថាខ័ណ្ឌ ៣៨, ទំព័រ ១១៤) តើរាជរដ្ឋាភិបាលកម្ពុជានឹងអភិវឌ្ឍ ព្រមទាំងជម្រុញលើការអភិរក្ស /ការបម្រុងទុកនៃផលស្តុក និងការអភិវឌ្ឍមុខរបរនេសាទក្នុងការចិញ្ចឹមជីវិត និងទីផ្សារយ៉ាងដូចម្តេច? ចំណុចនេះគឺជាការងារលំបាកណាស់ ជាពិសេសជាមួយនឹង សមត្ថភាពទន់ខ្សោយរបស់រដ្ឋ។<br><br>មានភាពចាំបាច់ត្រូវអភិវឌ្ឍរចនាសម្ព័ន្ធស្វែងរកទីផ្សារ/ដឹកជញ្ជូន ដើម្បីនាំយកត្រីប្រកបដោយគុណភាពល្អ ទៅកាន់ទីផ្សារក្នុងស្រុក និង ទីផ្សារសំរាប់នាំចេញ។ |

| | | | |
|---|---|---|---|
| | | | ចាំបាច់ត្រូវត្រូវមានការវាយតម្លៃឡើងវិញលើប្រព័ន្ធឡូត៍នេសាទ និង ផលប៉ះពាល់របស់វា លើភាពក្រីក្រនៃ សហគមន៍នេសាទនៅតំបន់បឹងទន្លេសាប។ ប្រព័ន្ធឡូត៍នេះគប្បីមានតម្លាភាពពេញលេញ ហើយការជួលត្រូវតែតម្រូវឱ្យទទួលខុសត្រូវលើការថែរក្សា និង ការកែលម្អប្រព័ន្ធអេកូឡូស៊ី និង សុខភាពមច្ឆាជាតិ, ប្រាក់ចំណូលមួយផ្នែកពីឡូត៍នេសាទគប្បីត្រូវ ផ្តល់ជូនដល់ថវិការបស់រដ្ឋបាល ជលផល។ |
| ១២៣ | ៤១២<br><br>៤១៣<br><br>៤១៤ | | ចាំបាច់ត្រូមានការវាយតម្លៃពេញលេញផ្នែកសង្គម និង សេដ្ឋកិច្ចនៃ "ទេសចរណ៍បរិស្ថាន"នៅកម្ពុជា។ ពុំមានការធានាទេថា ប្រសិនបើ អ្នក "ស្ថាបនាវា ពួកគេនឹងមក"។ តំបន់ខ្លះ ដូចជាក្រចេះ /សម្បូណ៌ជាដើម អាចត្រូវបានអភិវឌ្ឍច្រើនពេកទៅហើយ តែចំនួនភ្ញៀវទេសចរនៅទាប។សម្រាប់ទេសចរណ៍បរិស្ថាន គួរមានគំនិតផ្តួចផ្តើមពីក្រោមឡើងលើ តែត្រូវមានការដឹកនាំដោយរៀបចំផែនការសេដ្ឋកិច្ចល្អ ដោយមានការពិចារណាអំពីលទ្ធភាពនៃផលប៉ះពាល់អវិជ្ជមាន និងវិជ្ជមានលើជីវភាពរស់នៅរបស់ប្រជានេសាទ។<br><br>សមត្ថភាពអភិវឌ្ឍន៍ជលកសិកម្មគឺខ្សោយនៅកម្ពុជា។ រដ្ឋបាលជលផល ត្រូវតែអភិវឌ្ឍន៍លើការផ្សារភ្ជាប់ជាមួយអង្គការក្នុងតំបន់អាស៊ីនានា ដូចជាអង្គការ SeafDec, NACA, AIT និង អង្គការផ្សេងទៀត ដើម្បីអភិវឌ្ឍសមត្ថភាពជលកសិកម្មប្រកបដោយនិរន្តរភាព។ កម្មវិធីភ្ញាស់កូនត្រី (genetics) សមស្រប និងដែលអនុវត្តបានល្អសម្រាប់ ជលកសិកម្ម នឹងកាត់បន្ថយផលប៉ះពាល់ នៃជលកសិកម្មលើពូជ មច្ឆាជាតិជាលក្ខណៈធម្មជាតិ។ ប្រទេសកម្ពុជាគប្បីចាត់វិធានការ ច្នៃប្រឌិត ដើម្បីអភិវឌ្ឍជលកសិកម្មប្រកបដោយនិរន្តរភាព ដូចជាប្រព័ន្ធស្រែ-ត្រីប្រព័ន្ធកសិ-ជលកសិកម្មចម្រុះ ជលផលផ្អែកលើវប្បធម៌ និង មានអង្គភាពជលកសិកម្ម និងរកទីផ្សារ ដែលទទួល |

| | | | |
|---|---|---|---|
| ១២៤ | ៤១៥ | | បានការគាំទ្រល្អនៅក្នុងរដ្ឋបាលជលផល ជាមួយនិងការផ្សារភ្ជាប់ដ៏ ជិតស្និទ្ធជាមួយវិនិយោគិនផ្នែកឯកជន ដូច្នេះ រដ្ឋបាលជលផលគប្បី គាំទ្រនិងជួយសម្រួលដល់ការវិនិយោគឯកជនលើជលកសិកម្ម ទន្ទឹមគ្នានឹងការអភិវឌ្ឍន៍សមត្ថភាព ដើម្បីដាក់បញ្ចូលជលកសិកម្មទៅក្នុងកម្មវិធីសហគមន៍នេសាទ។<br><br>ចំណុចទាំងអស់នេះសុទ្ធសឹងជាគោលដៅចាំបាច់ដែលនឹងតម្រូវឱ្យមានការជួយគាំទ្ររឹងមាំ ផ្នែកហិរញ្ញវត្ថុនិងនីតិកម្ម និង អំណាចផ្តល់ជូនរដ្ឋបាលជលផល ដើម្បីអនុវត្ត SPF ១០ ឆ្នាំ របស់ខ្លួន។<br><br>អ្នកបំពេញរាល់សកម្មភាពទាំងអស់ក្នុងការអភិវឌ្ឍន៍លើវិស័យជលផល ការគ្រប់គ្រង ឬ ការអភិរក្ស គប្បីត្រូវធ្វើសុខដុមនីយកម្ម ១) ជាមួយ SPF ១០ ឆ្នាំ និង ២) អន្តរវិស័យ ជាមួយក្រសួងពាក់ព័ន្ធ រួមទាំងការទទួលស្គាល់ពេញលេញនូវសក្តានុពលពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុលើប្រព័ន្ធវារី-អេកូឡូស៊ី និងជលផលនៃប្រទេសកម្ពុជាព្រមទាំងសក្តានុពលពីផលប៉ះពាល់ ដែលអាចកើតចេញពីចំណុចនេះ លើប្រជាជនក្រីក្រនៅ ជនបទដែលពឹងអាស្រ័យដោយផ្ទាល់លើមច្ឆាជាតិ និង ធនធានជលជាតិ ផ្សេងទៀតសម្រាប់អាហារនិងប្រាក់ចំណូល។<br><br>ពុំមានសេចក្តីថ្លែងជាយុទ្ធសាស្ត្រច្បាស់លាស់អំពីរបៀបដែលរាជរដ្ឋាភិបាលកម្ពុជានឹងរក្សា ធនធានជលផលប្រកបដោយនិរន្តរភាព សម្រាប់ជាផលប្រយោជន៍របស់អ្នកនេសាទ គ្រួសារប្រជានេសាទក្រីក្រ និងសហគមន៍ទាំងឡាយដែលងាយរងគ្រោះបំផុត ដែលពឹងអាស្រ័យច្រើនបំផុតលើធនធានជលផលសម្រាប់ជីវិតរស់នៅរបស់ខ្លួន។ |

| | | | |
|---|---|---|---|
| | | | ចាំបាច់ត្រូវមាននិយមន័យច្បាស់លាស់នៃសិទ្ធិរបស់អ្នកនេសាទ ដែលទាក់ទិននឹងលទ្ធភាពប្រកបរបរ និង ការចែករំលែកផលប្រយោជន៍ពីផ្ទៃទឹកកម្ពុជា រួមទាំងឡូត៍នេសាទនៅក្នុងតំបន់បឹងទន្លេសាប និងតាមដងទន្លេបាសាក់ផង។<br><br>ពុំមានទិសដៅច្បាស់លាស់អំពីរបៀបដែលរដ្ឋបាលជលផលគ្រោងកែលម្អតួនាទីរបស់ស្ត្រី ក្នុងការស្វែងរកទីផ្សារឬបង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងកម្មវិធីជលផលសហគមន៍។ លទ្ធភាព គប្បីត្រូវបានផ្តល់ដោយរដ្ឋបាលជលផល ដើម្បីឱ្យមានការចូលរួមកាន់តែច្រើន ថែមទៀតដោយស្ត្រីទាំងអស់នៅក្នុងនេសាទសហគមន៍ និងទាំងនៅក្នុងរដ្ឋបាលជលផលខ្លួនឯង រួមទាំងថ្នាក់គ្រប់គ្រងនិងតំណែងស្រាវជ្រាវ នាពេលអនាគត។ |

**ព័ត៌មានទំនាក់ទំនង**

សម្រាប់ពត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង:


**ក្រុមសម្ព័ន្ធសកម្មភាពនេសាទ (FACT)**

លោក រ៉ុន ចន ទីប្រឹក្សាបច្ចេកទេស

អ៊ីម៉ែល: jonesr@fact.org.kh

| ទំព័រ | កថាខ័ណ្ឌ | សំណូមពរ និងអនុសាសន៍សម្រាប់ការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ បច្ចុប្បន្នកម្ម |
|---|---|---|
| ៣៥ | ១២០ | កថាខ័ណ្ឌ ១២០:<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>-បន្ថែមពីលើក្រសួង និងភាគីពាក់ព័ន្ធដទៃទៀត នាយកដ្ឋានសម្រាប់វាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថានរបស់ក្រសួងបរិស្ថាន ក៏ត្រូវធ្វើការប្រឹងប្រែងក្នុងការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋនានា ដែលមានបំណងចូលរួមក្នុងដំណើរការធ្វើផែនការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ ប្រការនេះ នាំមកនូវការបង្កើតវេទិកាពិភាក្សាពីសហគមន៍ និងតំណាងអង្គការក្រៅរដ្ឋាភិបាលដូចជា បណ្តាញផលប៉ះពាល់សង្គម និងបរិស្ថាន ពីឧស្សាហកម្មនិស្សារណកម្មដែលអាចចែករំលែកគំនិតយោបល់និងភស្តុតាងពីការខូចខាតបរិស្ថានដែលបណ្តាលមកពីគម្រោងក្រុមហ៊ុនផ្សេងៗ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងបរិស្ថាន។ យន្តការនេះ អាចជាផ្នែកមួយដែលមានប្រសិទ្ធភាពតម្លៃ និងចូលរួមចំណែកក្នុងការបង្កើនការចូលរួមជាសាធារណៈ និងទំនាក់ទំនងរវាងរដ្ឋនិងប្រជាពលរដ្ឋ។ |
| ៣៦ | ១២៣ | កថាខ័ណ្ឌ ១២៣ :<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>-ក្រសួងបរិស្ថាន ធ្វើសហប្រតិបត្តិការជាមួយក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តការពិសោធន៍គុណភាពទឹក លើតំបន់ដែលមានសក្តានុពលរងនូវផលប៉ះពាល់ពីការពង្រីកផ្នែកឧស្សាហកម្មដូចជា ការសាងសង់ និស្សារណកម្ម វារីអគ្គិសនី និងរោងចក្រនានា។ កិច្ចសហការនេះ អាចបង្កើនទំនាក់ទំនងរវាងក្រសួង ផ្សេងៗ និងអាចទប់ស្កាត់នូវផលខូចខាតធ្ងន់ធ្ងរទៅលើជីវចម្រុះ ការនេសាទ កសិកម្ម និងទឹក សម្រាប់បរិភោគ។<br>-ក្រសួងបរិស្ថានបង្កើត និងប្រកាសឱ្យប្រើប្រាស់បទដ្ឋាន និងការកំណត់ផ្សេងៗជាអប្បបរមា ដែលច្បាស់លាស់សម្រាប់ពិសោធន៍លើគុណភាពទឹក។ ការកំណត់ទាំងនោះរួមមាន លោហធាតុធន់ធ្ងន់ ទឹកសម្រាប់រំលាយគ្រឿងឧស្សាហកម្ម ជីគីមី សារជាតិរំលាយអុកហ្ស៊ីហ្សែន សារធាតុតម្រូវ ការជីវអុកហ្ស៊ីហ្សែន។ល។ |
| ៤៤ | ១៩៨ | កថាខ័ណ្ឌ ១៩៨: តំបន់ដែលមានឧស្ម័ន និងប្រេងស្ថិតនៅក្រោមសមុទ្រគឺជាសម្បត្តិរួមរបស់ ប្រជាជនកម្ពុជាក្នុងពេលបច្ចុប្បន្ន និងអនាគត...<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ: |

| | | |
|---|---|---|
| | | - រាជរដ្ឋាភិបាលកម្ពុជា គប្បីរៀបចំ និងអនុវត្តគោលនយោបាយជាតិមួយ សម្រាប់ទទួលខុសត្រូវ ផ្នែកសង្គម និងបរិស្ថាននៅក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម ។<br>- រាជរដ្ឋាភិបាលកម្ពុជា គប្បីបង្កើតស្ថាប័នសាធារណៈឯករាជ្យមួយ (ដោយមានការចូលរួមពីអន្តរក្រសួងដូចជា ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងបរិស្ថាន និងក្រសួងសុខាភិបាល) ដែលមានអណត្តិ ធនធាន និងជំនាញដើម្បីត្រួតពិនិត្យជាប់ជាប្រចាំលើគ្រប់ទិដ្ឋភាពទាំងអស់នៃការផ្តល់សិទ្ធិរួមទាំងការតាមដានសុខភាព និងផលប៉ះពាល់សង្គម-វប្បធម៌ផងដែរ ។ លើសពីនេះទៅ ទៀត អ្នកត្រួតពិនិត្យ ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរតំបន់ការពារ/ព្រៃការពារគប្បីតាមដានគ្រប់ សកម្មភាពរុករកទាំងអស់នៅក្នុងតំបន់ការពារ និងព្រៃការពារ ។<br>-រាល់ស្ថាប័នដែលទទួលខុសត្រូវទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជាប្រតិបត្តិអនុស្សរណៈលើការផ្តល់អាជ្ញាប័ណ្ណរុករក និងអាជ្ញាប័ណ្ណការទាញយកផល នៅក្នុងតំបន់ជនជាតិដើមភាគតិចរហូតទាល់តែមានការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពជនជាតិដើមភាគតិចត្រូវបានបញ្ចប់ ។<br>- រាល់ស្ថាប័ន ដែលទទួលខុសត្រូវទាំងអស់របស់រាជរដ្ឋាភិបាល ប្រតិបិត្តអនុស្សរណៈលើការផ្តល់អាជ្ញាប័ណ្ណរុករក និងអាជ្ញាប័ណ្ណការទាញយកផល នៅក្នុងតំបន់ព្រៃឈើ និងជីវចម្រុះនានាបាន លុះត្រាតែមានការកំណត់ព្រំដែនដែលបានត្រួតពិនិត្យ និងរៀបចំដើម្បីការពារកាកសំណល់ដែលមានតម្លៃពីបរិស្ថានវិទ្យាដែលជារបស់ដើមកំណើតប្រទេសកម្ពុជា ។<br>- រាជរដ្ឋាភិបាលកម្ពុជាគប្បីរៀបចំផែនការ និងអនុវត្តការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងប្រទេស និងទៅលើវិស័យឧស្សាហកម្មនិស្សារណកម្ម ។ ប្រការនេះ អាចធានាបាននូវការអភិវឌ្ឍន៍ធនធានមនុស្សគ្រប់គ្រាន់សម្រាប់វិស័យឧស្សាហកម្ម និស្សារណកម្ម ។<br>- ការអភិវឌ្ឍន៍នៃវិស័យឧស្សាហកម្មនិស្សារណកម្ម (រួមមានការរុករកឧស្ម័ន ប្រេង និងរ៉ែ) នៅប្រទេសកម្ពុជាមានការកត់ត្រាទុកជាឯកសារ ប៉ុន្តែឯកសារទាំងនោះពុំត្រូវបានចែកចាយជូន សាធារណជនឱ្យបានដឹងទេ ។ ព័ត៌មានស្តីពីការផ្តល់សម្បទានផ្សេងៗ គប្បីទទួលបានតាមរយៈ គេហទំព័ររបស់ក្រសួងដែលទទួលខុសត្រូវ ហើយព័ត៌មានទាំងនោះរួមមាន : កិច្ចសន្យា កិច្ចព្រម ព្រៀង គោលនយោបាយ និងច្បាប់នានា ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជា គប្បីមានការពិគ្រោះយោបល់ជាសាធារណៈនៅពេលបង្កើតគោលនយោបាយលក្ខខណ្ឌចាំបាច់ដែលត្រូវមាន និង ដំណើរការនៃការតាក់តែងច្បាប់ ។<br>- រាជរដ្ឋាភិបាលកម្ពុជា គប្បីរៀបចំបទបញ្ញត្តិនានាដែលនឹងអនុញ្ញាតឱ្យក្រុមសង្គមស៊ីវិល និង សាធារណជនទូទៅអាចមានលទ្ធភាពពេញលេញក្នុងការទទួលបានព័ត៌មានទាក់ទិន |

| | | |
|---|---|---|
| | | នឹងវិស័យឧស្សាហកម្មនិស្សារណកម្ម។ ឧទាហរណ៍ ការបើកចំហព័ត៌មានស្ដីពីការផ្ដល់សម្បទានកិច្ចសន្យាដល់ក្រុមហ៊ុនរុករករ៉ែ ការចំណាយ សំណងលើការខូចខាត និងការរីកចំរើននៃការអភិវឌ្ឍន៍លើវិស័យ<br>ឧស្សាហកម្ម។<br>- រាជរដ្ឋាភិបាលកម្ពុជា ក្រសួងព័ត៌មាន ជាពិសេសវិទ្យុជាតិកម្ពុជា គប្បីបង្កើតនិងផ្សព្វផ្សាយកម្មវិធីស្ដីពីការរុករក និងការទាញយកផលពីរ៉ែ។<br>- រាជរដ្ឋាភិបាលកម្ពុជាគប្បីបន្តការចូលរួមយ៉ាងសកម្មជាមួយសង្គមស៊ីវិលសម្រាប់គ្រប់ទិដ្ឋភាពទាំងអស់នៃការធ្វើផែនការនិងសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការចូលរួមរបស់សង្គមស៊ីវិល ក្នុងការពិភាក្សាជាសាធារណៈអាចឱ្យពួកគេផ្ដល់គំនិតយោបល់ដល់រាជរដ្ឋាភិបាលក្នុងការដឹកនាំ ប្រទេសកម្ពុជាឈានទៅមុខទៀត។ |
| ៤៤ | ១៥៨ | កថាខ័ណ្ឌ ១៥៨: ចំណុចទី ២: បង្កើតយន្តការ និងស្ថាប័នផ្សេងៗដើម្បីចង្អុលបង្ហាញសម្រាប់វិស័យ នេះ និងត្រួតពិនិត្យលើដំណើរការ...<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>- រាជរដ្ឋាភិបាលកម្ពុជាគប្បីបង្កើតស្ថាប័នសាធារណៈឯករាជ្យមួយ (ដោយមានការចូលរួមពីអន្តរក្រសួងរួមមាន ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងបរិស្ថាន និងក្រសួងសុខាភិបាល) ដែលមានអណត្តិ ធនធាន និងជំនាញដើម្បីត្រួតពិនិត្យជាប់ជាប្រចាំលើគ្រប់ទិដ្ឋភាពទាំងអស់នៃការ ផ្ដល់សិទ្ធិរួមទាំងការតាមដានសុខភាព និងផលប៉ះពាល់សង្គម-វប្បធម៌ផងដែរ។ លើសពីនេះទៅ ទៀត អ្នកត្រួតពិនិត្យក្រោមការគ្រប់គ្រងរបស់អាជ្ញាធរតំបន់ការពារ / ព្រៃការពារគប្បីតាមដាន គ្រប់សកម្មភាពរុករកទាំងនៅក្នុងតំបន់ការពារ / ព្រៃការពារ និងតំបន់ជីវសាស្ត្រដែលសំខាន់សម្រាប់សេវាបរិស្ថានវិទ្យា និងការរស់នៅក្នុងស្រុក។<br>- នាយកដ្ឋានវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថានរបស់ក្រសួងបរិស្ថានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសាធារណជននានាដែលមានបំណងចូលរួមចំណែកក្នុងដំណើរការធ្វើផែនការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ ប្រការនេះនាំមកនូវការបង្កើតវេទិកាពិភាក្សាពីសហគមន៍ និង តំណាងអង្គការមិនមែនរដ្ឋាភិបាលដូចជាបណ្ដាញផលប៉ះពាល់សង្គម និងបរិស្ថានពីឧស្សាហកម្ម និស្សារណកម្ម ដែលអាចចែករំលែកគំនិតយោបល់ និងភស្តុតាងពីការខូចខាតបរិស្ថានដែលបណ្ដាល មកពីគម្រោងក្រុមហ៊ុនផ្សេងៗដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងបរិស្ថាន។ យន្តការនេះ អាចជាផ្នែកមួយដែលមានប្រសិទ្ធភាពតម្លៃ និងចូលរួមចំណែកក្នុងការបង្កើននូវចំណងទាក់ទងរវាងរដ្ឋ និងប្រជាពលរដ្ឋ។ |

| | | |
|---|---|---|
| ៥០ | ១៨១ | កថាខ័ណ្ឌ ១៨១: ការរុករកប្រេង ឧស្ម័ន និងរ៉ែ<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>- ពាកសុំសម្បទានថ្មីៗដែលត្រួតស៊ីគ្នាលើតំបន់ការពារ និងព្រៃការពារនឹងត្រូវបានត្រួតពិនិត្យឡើងវិញដោយស្ថាប័នបច្ចេកទេស ដែលទទួលបន្ទុកលើការគ្រប់គ្រង ដូចជាក្រសួងបរិស្ថាន/រដ្ឋបាល អភិរក្ស និងការពារធម្មជាតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/រដ្ឋបាលព្រៃឈើ រួមទាំងភាគីពាក់ព័ន្ធសមស្របផ្សេងៗទៀតដូចដែលបានចែងក្នុងមាត្រា១០ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន មាត្រា៤ និងមាត្រា៣៥នៃច្បាប់ព្រៃឈើ ។<br>- រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស នាយកដ្ឋានវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថានរបស់ក្រសួង បរិស្ថាននឹងធ្វើការកែសំរួលគោលការណ៍ស្តីពីការវាយតម្លៃ ផលប៉ះពាល់ បរិស្ថានដោយមានការចូលរួមពីពហុភាគីពាក់ព័ន្ធ និងបំពេញគោលដៅនៃការវាយតម្លៃផលប៉ះពាល់បរិស្ថានប្រកបដោយ អត្ថន័យ ។<br>- ពិនិត្យ និងកែសំរួលឡើងវិញនូវច្បាប់ និងបទបញ្ញត្តិផ្សេងៗ ដែលមានជាធរមាស្តីពីការទាញយកផលឧស្សាហកម្មរ៉ែ ឧស្ម័ន និងប្រេង ដែលមានការឆ្លុះបញ្ចាំងគ្រប់គ្រាន់ពីបទដ្ឋានអន្តរជាតិ ដើម្បីធានាបាននូវប្រព័ន្ធសុវត្ថិភាពសម្រាប់សង្គម និងបរិស្ថាននៅក្នុងវិស័យនេះ រួមទាំងការអនុវត្តន៍ ដ៏ប្រសើរដែលទាក់ទិននឹងសុខភាព សុវត្ថិភាព និងការការពារបរិស្ថាន អង្គការបទដ្ឋានអន្តរជាតិ ការអភិរក្សជីវចម្រុះ និងនិរន្តភាពនៃការគ្រប់គ្រងធនធានធម្មជាតិ ។ |
| ១២៥<br>-<br>១២៦ | ៤២១ | កថាខ័ណ្ឌ ៤២១: ចំណុច i-iv<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>-ពង្រឹងការអនុវត្តន៍ច្បាប់បរិស្ថាន ដើម្បីធានាឱ្យបាននូវការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលសមរម្យត្រូវបានបញ្ចប់មុនពេលគម្រោងក្រុមហ៊ុនចាប់ផ្តើម ។ ការធ្វើបែបនេះ ជម្រុញឱ្យក្រសួង បរិស្ថាន ពិនិត្យឡើងវិញនូវរយៈពេលសម្រាប់ប្រើក្នុងការវិភាគគ្រប់គ្រាន់ដែលធានាបាននូវសិទ្ធិជា សាធារណៈក្នុងការផ្តល់មតិយោបល់ និងតាមដានការអនុវត្តវិធានការនានា ដែលជួយសម្រាលផល ប៉ះពាល់អវិជ្ជមាន ។<br>- រៀបចំ និងអនុវត្តគោលនយោបាយជាតិមួយដែលមានលក្ខណៈច្បាស់លាស់ និងស្ថេរភាពទៅលើការបំពុល ខ្យល់ ទឹក និងសម្លេងរំខាន ។<br>- សហការជាមួយក្រសួងផ្សេងៗ (ដូចជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ល ។) ដើម្បីបង្កើតផែនការគ្រប់គ្រងមួយច្បាស់លាស់ និងទទួលស្គាល់ជាសកលស្តីពីតំបន់ |

| | | |
|---|---|---|
| | | ដែលមានការអភិរក្សរួចហើយ និងព្រៃឈើសំខាន់ៗដែលត្រូវបានហាមឃាត់សម្រាប់ការអភិវឌ្ឍន៍ដែលមិនសមស្របនឹងការពារវប្បធម៌ និងធនធានធម្មជាតិ ដូចដែលបានចែងក្នុងកម្មវិធីព្រៃឈើជាតិនាពេលបច្ចុប្បន្ន។ |
| ១២៦ | ៤២៣ | កថាខ័ណ្ឌ ៤២៣: នៅក្នុងផ្នែកវាយតម្លៃផលប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថានគប្បីធានាឱ្យបាននិរន្តភាពនៃការប្រើប្រាស់ធនធានធម្មជាតិនិងសេដ្ឋកិច្ចពីវិស័យឧស្សាហកម្មនិស្សារណៈកម្ម តាម រយៈការវាយតម្លៃពីផលប៉ះបរិស្ថាន មុនពេលអនុវត្តគម្រោងអភិវឌ្ឍ:<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>- រាល់ការអនុវត្តន៍លើការវាយតម្លៃពីផលប៉ះពាល់បរិស្ថាន និងសង្គមដែលបានចូលជាធរមានគួរត្រូវ បានបង្ហាញដល់សាធារណជនសម្រាប់ការត្រួតពិនិត្យឡើងវិញ។ រាល់ច្បាប់ដែលផ្ទុយពីអ្វីដូចដែលបានចែងក្នុងច្បាប់ខាងលើស្តីពីនិស្សារណៈកម្មរ៉ែត្រូវធ្វើវិសោធនកម្មដើម្បីឆ្លុះបញ្ចាំងពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងបទបញ្ញត្តិរបស់ក្រសួងបរិស្ថាន។ |
| ១២៦ | ៤២៣ | កថាខ័ណ្ឌ ៤២៣ ចំណុច ១-៣:<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>- ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលដូចជា (ប្រជាពលរដ្ឋ ឬអង្គការ សង្គមស៊ីវិល ។ល។) និងរដ្ឋាភិបាល (ដូចជា ក្រសួង សាកលវិទ្យាល័យនានា ។ល។) នៅក្នុងការខិតខំប្រឹងប្រែងរបស់ ក្រសួងបរិស្ថានដើម្បីពង្រឹងសមត្ថភាពបច្ចេកទេសក្នុងការរៀបចំកែលំអនូវច្បាប់ និងគោលនយោបាយ និងការត្រួតពិនិត្យផែនការគ្រប់គ្រងបរិស្ថានផ្សេងៗ ។ ជាមួយប្រជាជន អង្គការនិង ស្ថាប័នរដ្ឋ បារម្ភពីបញ្ហាបរិស្ថានជាច្រើននៅកម្ពុជា ហើយក្រសួងបរិស្ថានអាចប្រើប្រាស់នូវបទពិសោធន៍ និងជំនាញនៃអង្គភាពសកម្មនានានៅគ្រប់កំរិតរបស់រដ្ឋាភិបាលកម្ពុជា និងអង្គការសង្គម ស៊ីវិលដើម្បីសម្រេចនូវគោលដៅទាំងនេះ។ |
| ១២៦ | ៤២៤ | កថាខ័ណ្ឌ ៤២៤ ចំណុច ១-៧:<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>- ដោយមានការចូលរួមពីអ្នកជំនាញថ្នាក់ជាតិជាច្រើនដែលមានស្រាប់ និងស្ថាប័នអន្តរជាតិនានា ក្នុងដំណើរការកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងបរិស្ថាន ដើម្បីពង្រឹងវិធានការផ្សេងៗ ក្នុងការត្រួត ពិនិត្យការបំពុលបរិស្ថាន។ ពង្រឹងការអនុវត្តច្បាប់ដែលមានស្រាប់ដើម្បីចម្រុះឱ្យស្ថាប័នរដ្ឋ និងស្ថាប័នឯកជនទទួលខុសត្រូវលើការបំពុលបរិយាកាសទឹកដែលនៅក្រោមដី សម្លេងរំខាន និងផ្ទៃទឹករាក់ៗ ដើម្បីធ្វើការជាមួយក្រសួងបរិស្ថានក្នុងការបង្កើតនូវដំណោះស្រាយមួយចំនួនដែលអាច ប្រើសម្រាប់ដោះស្រាយឬបន្ធូ |

| | | |
|---|---|---|
| | | បន្ថយនូវបញ្ហាដែលមាននាពេលអនាគត។ ជាចុងក្រោយក្រសួង បរិស្ថានគួរផ្សព្វផ្សាយជាសាធារណៈនូវបទដ្ឋាន និងបទ្ទបន្ថយបញ្ញត្តនៃវិធានការទាំងឡាយណាដែលពាក់ពន្ធ័ទៅនឹងការត្រួតពិនិត្យការបំពុលផ្សេងៗដែលចេញដោយក្រសួង។ |
| ១២៦<br>-<br>១២៧ | ៤២៥ | កថាខ័ណ្ឌ ៤២៥ ចំណុច ៣ និង ៧: (ការគ្រប់គ្រងទិន្នន័យ ការគ្រប់គ្រងការពង្រឹង និងអភិរក្ស)<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>- ក្រសួងបរិស្ថានគួរស្ថាបនាទិន្នន័យដែលមានលក្ខណៈជាផ្លូវការ សាធារណៈ និងថ្នាក់ជាតិមួយសម្រាប់តំបន់ការពារនិងតំបន់ដែលមិនទាន់បានការពារនានាដែលមានក្នុងផែនទីផ្សេងៗ ទិន្នន័យការប្រើប្រាស់អំពីដី និងការកែប្រែថ្មីចុងក្រោយបង្អស់ នៃការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលបានអនុម័តដោយក្រសួង។<br>- ក្រសួងបរិស្ថានគួរពង្រឹងការគ្រប់គ្រង និងការអភិរក្សលើដីភក់ការបំរុងទុកនូវតំបន់អភិរក្ស តំបន់ឆ្នេរសមុទ្រផ្សេងៗ។ល។ តាមរយៈការបង្កើតប្រពន្ធ័ ការប្រើប្រាស់ដីដែលអាចទទួលយកបានមួយដែលមានភាពជាប់លាប់ និងប្រតិបត្តិបានការទទួលបានដីប្រើប្រាស់សម្រាប់ទីកន្លែងផ្សេងៗ។ ដីដែលអាចទទួលយកបានទៅប្រើប្រាស់ លើកលែងតែការកាប់ព្រៃឈើឧស្សាហកម្មនិស្សារណកម្ម ឬការអភិវឌ្ឍដែលហួសពីប្រពន្ធ័បរិស្ថានដែលមានស្រាប់។ |
| ១២៧ | ៤២៦ | កថាខ័ណ្ឌ ៤២៦:<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>- មធ្យោបាយមួយក្នុងការទំនាក់ទំនងទៅដល់សហគមន៍ជាច្រើនក្រសួងបរិស្ថានគួរបញ្ចូលនូវកង្វល់របស់ក្រុមអង្គការសង្គមស៊ីវិលទៅក្នុងយុទ្ធនាការអប់រំ និងព័ត៌មានផ្សេងៗ។ ប្រការនេះក៏ចង់ផ្តល់នូវឱកាសដ៏មានតំម្លៃដើម្បីផ្លាស់ប្តូរព័ត៌មាន និងលើកស្ទួយកិច្ចសន្យារវាងរដ្ឋាភិបាល សហគមន៍ និង អង្គការសង្គមស៊ីវិល។ |
| ១៣៥ | ៤៥០ | កថាខ័ណ្ឌ ៤៥០: នៅក្នុងផ្នែកកម្មវិធីការព្រាង និងការអនុម័តច្បាប់ និងការកសាងភាពជាដៃគូ ជាមួយវិស័យឯកជនដើម្បីលើកកំពស់ការចូលរួម។<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>- រាល់ស្ថាប័នដែលទទួលខុសត្រូវទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជា ប្រតិបិត្តអនុស្ស-រណៈលើការផ្តល់អាជ្ញាប័ណ្ណរុករកនិងអាជ្ញាប័ណ្ណការទាញយកផល នៅក្នុងតំបន់ជនជាតិដើមភាគតិចរហូតទាល់តែមានការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពជនជាតិដើមភាគតិចត្រូវបានបញ្ចប់។<br>- រាជរដ្ឋាភិបាលកម្ពុជាផ្តល់ឱ្យក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងបរិស្ថាន |

| | | |
|---|---|---|
| | | រដ្ឋបាលព្រៃ ឈើ និងក្រសួងសុខាភិបាលនូវអាណត្តិ ធនធាន និងជំនាញការ ដើម្បីត្រួតពិនិត្យជាបន្តបន្ទាប់នូវរាល់ ទិដ្ឋភាពនៃការផ្តល់សិទ្ធិរួមបញ្ចូលទាំងការត្រួតពិនិត្យផលប៉ះពាល់លើសុខភាព និងវប្បធម៌-សង្គមផ្សេងៗ។ |
| ១៣៨ | ៤៥៨ | កថាខ័ណ្ឌ ៤៥៨: រាជរដ្ឋាភិបាលកម្ពុជាលើកទឹកចិត្តចំពោះការប្រើប្រាស់ថាមពលដែលមានប្រសិទ្ធិភាព ជាមួយនឹងផលប៉ះពាល់តិចបំផុតលើបរិស្ថាន។<br>•យើងខ្ញុំសូមស្នើរដោយស្មោះត្រង់ចំពោះ:<br>- រាជរដ្ឋាភិបាលកម្ពុជាបង្កើត និងអនុវត្តនូវគោលនយោបាយជាតិមួយ សម្រាប់ការទទួលខុសត្រូវសង្គម និងបរិស្ថាននៅក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម។<br>- រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសនាយកដ្ឋានវាយតម្លៃផលប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន ដែលមានការចូលរួមពីពហុភាគីពាក់ពន្ធ័ និងបំពេញគោលដៅនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន ប្រកបដោយអត្ថន័យ។ |

* លេខទំព័រសំដៅលើលេខទំព័រដែលមានប្រើនៅក្នុងផយអជបច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី**១ផយអជ**បច្ចុប្បន្នកម្ម ២០០៩-២០១៣

**ព័ត៌មានទំនាក់ទំនង**

សម្រាប់ពតិមានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង:

**អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព**
លោក ម៉ម សម្បត្តិ
គណកម្មាធិការប្រតិបត្តិ នៃបណ្តាញផលប៉ះពាល់សង្គមនិងបរិស្ថានដោយឧស្សាហកម្មនិស្សារណៈកម្ម
នាយកប្រតិបត្តិ នៃអង្គការ អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព
ទូរស័ព្ទ: ៨៥៥-២៣ ២១៦ ៤៩៥
អ៊ីម៉ែល: mam.sambath@citylink.com.kh

# ការគ្រប់គ្រងចំណូលឧស្សាហកម្មនិស្សារណកម្ម

| លេខទំព័រ* | លេខកឋាខ័ណ្ឌ** | ការចូលរួមមតិយោបល់របស់អង្គការមិនមែនរដ្ឋាភិបាល |
|---|---|---|
| ៧៧-៧៨ | ១៥៨ | យើងខ្ញុំសូមស្នើសុំចូលរួមយោបល់បន្ថែមទៀតនៅក្នុងកឋាខ័ណ្ឌ១៥៨:<br>• ប្រយោគដំបូងនៃកឋាខ័ណ្ឌ ១៥៨ សូមកែសម្រួលទៅជា " តំបន់ប្រេងកាត និងឧស្ម័នទាំងនៅក្នុងដែនសមុទ្រ ***និងដីគោក*** " គឺជាទ្រព្យសម្បត្តិរួមរបស់ប្រជាជនកម្ពុជាទាំងអស់ សម្រាប់ពេលបច្ចុប្បន្ននេះនិងក្នុងពេលអនាគត.........<br>• ចំណុចអាទិភាពចំនួនប្រាំដែលបានលើកឡើងនៅក្នុងកឋាខ័ណ្ឌ ១៥៨ សូមលើកយកទៅដាក់នៅក្នុងជំពូកទីបួននៃបច្ចុប្បន្នកម្ម NSDP ដែលជាជំពូកទាក់ទងនឹងគោលនយោបាយ និងសកម្មភាពសំខាន់ៗ ដែលក្រសួងសាម៉ីនឹងធ្វើការពិភាក្សា និងអនុវត្ត។<br>• ធ្វើបច្ចុប្បន្នភាពពីការវិភាគស្ថានការណ៍ជុំវិញការរំពឹងទុក នៅពេលដែលទទួលចំណូលបានពីប្រេង ឧស្ម័ន និងរ៉ែ<br><br>យើងខ្ញុំសូមស្នើសុំដាក់បញ្ចូលនូវសមិទ្ធិផលដែលរាជរដ្ឋាភិបានសម្រេចបានពីឆ្នាំ២០០៦-២០០៩ ដូចមានខាងក្រោម:<br>• បានបង្កើតនូវក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់រៀបចំផែនការសកម្មភាព និងតាមដាននូវការអនុវត្តន៍ការងារកៀរគរ និងគ្រប់គ្រងចំណូលមកពីប្រេង ឧស្ម័ន និងធនធានរ៉ែ ដទៃទៀត យោងតាមសេចក្តីសម្រេច (លេខ ១០ សសរ) និងចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩។<br><br>ក្រុមការងារបច្ចេកទេសនេះស្ថិតនៅក្រោមក្រុមការងារបច្ចេកទេសកំណែទម្រង់ការគ្រប់គ្រង់ហិរញ្ញវត្ថុសាធារណៈ និងបង្កើតផែនការសកម្មភាពស្តីពីការគ្រប់គ្រងចំណូលមកពីប្រេង ឧស្ម័ន និងធនធានរ៉ែផ្សេងៗ និងភារកិច្ចផ្សេងទៀត ដូចមានចែងក្នុងសេចក្តីសម្រេច។ ក្រុមការងារបច្ចេកទេសនេះមានតំណាងមកពី ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ ក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួងផែនការ អាជ្ញាធរប្រេងកាតជាតិកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។<br>• តារាងចំណូលបានពីក្រុមហ៊ុនប្រេង ឧស្ម័ន និងរ៉ែ ត្រូវបានដាក់បញ្ចូលនៅក្នុងតារាង TOFE ចាប់តាំងពីឆ្នាំ២០០៩ និងបានចេញផ្សាយយ៉ាងទៀងទាត់នៅក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច |

| | | |
|---|---|---|
| | | និងហិរញ្ញវត្ថុ។<br><br>យើងខ្ញុំសូមស្នើសុំដាក់បញ្ចូលនូវកត្តាប្រឈមក្នុងឆ្នាំ២០០៦-២០០៩ ខាងក្រោម:<br>• ចំណូលដែលទទួលបានពីកិច្ចសន្យាប្រេង ឧស្ម័ន និងរ៉ែ ដូចជា សួយសារធនធានរ៉ែ ថ្លៃចុះបញ្ជីធនធានរ៉ែ និងកម្រៃអជ្ញាប័ណ្ណត្រូវបានចាត់ទុកថាជា "ចំណូលមិនមែនសារពើពន្ធពីប្រេង និងឧស្ម័ន " នៅក្នុងតារាងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយសារតែចំណូលទាំងនេះមិនមែនសារពើពន្ធ វាមានការលំបាកក្នុងការធ្វើ សុខដុមរូបនីយកម្មរវាងច្បាប់ពន្ធ និងកិច្ចសន្យារវាងរដ្ឋាភិបាលនិងក្រុមហ៊ុនឯកជនដែល សុខដុមរូបនីយកម្មនេះអាចបង្កើតឱ្យមានបរិយាកាសរឹតតែល្អប្រសើរសម្រាប់ការវិនិយោគ។ |
| ១៣៦<br>-<br>១៣៧ | ២៧៦ | នៅកឋាខ័ណ្ឌ ២៧៦នេះ យើងខ្ញុំសូមស្នើសុំដាក់បន្ថែមនូវអត្ថន័យដូចខាងក្រោម:<br>រាជរដ្ឋាភិបាលបានថ្លែងថា ចំណូលសន្ទឹកសន្ធាប់ពីប្រេង ឧស្ម័ន និងរ៉ែផ្សេងៗទៀតដែលរំពឹងថា នឹងទទួលបាននៅដើម ឆ្នាំ២០១១ នោះ រាជរដ្ឋាភិបាល នឹងបង្កើតគោលនយោបាយត្រៀមទុកជាមុនរួមបញ្ចូលទាំងយុទ្ធសាស្ត្រសម្រាប់ធ្វើការវិនិយោគ (ឧ. ឧបត្ថម្ភធន និងបន្ធូរ បន្ថយពន្ធ) ដើម្បីធានាថាវិស័យសំខាន់នៃសេដ្ឋកិច្ច ដូចជា កសិកម្ម កាត់ដេរ សំណង់ ទេសចរណ៍ អាចរក្សានូវការប្រកួតប្រជែងបានទោះជាមានចំណូលថ្មីមកពីប្រេង និងឧស្ម័នក៏ដោយ។ |
| ១៦៥ | ៣២៥ | នៅក្នុងកឋាខ័ណ្ឌនេះយើងខ្ញុំស្នើសុំដាក់បន្ថែម:ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ចនឹងរៀបចំឱ្យមានច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។ |
| ១៨៥ | ៣៦៨ | គោលនយោបាយអាទិភាពមានអធិប្បាយយ៉ាងពិស្តារ ប៉ុន្តែការធ្វើ បច្ចុប្បន្នកម្ម NSDP ពុំបានបញ្ចូលនូវការពន្យល់ថាតើយុទ្ធ សាស្ត្រនេះនឹងត្រូវបានអនុវត្តន៏ដោយរបៀបណានោះទេ។ យើងខ្ញុំសូម សំណូមពរ នៅក្នុងផ្នែក ខ (សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្តគោលនយោបាយអាទិភាព) ដាក់បញ្ចូលនូវការអធិប្បាយថាតើរាជរដ្ឋាភិបាលនឹងធានានូវចំណូលដែលបានមកពីប្រេង ឧស្ម័ន និងរ៉ែ នឹងត្រូវគ្រប់គ្រងឱ្យមានប្រសិទ្ធិភាព និងតម្លាភាពបានយ៉ាងដូចម្តេច និងតើរាជរដ្ឋាភិបាលនឹងទទួលខុសត្រូវក្នុងការប្រើប្រាស់ចំណូលទាំងនេះយ៉ាងដូចម្តេច។ នៅក្នុងការអត្ថាធិប្បាយនេះគួរមានដាក់បញ្ចូលនូវផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានបង្ហាញនៅក្នុងសិក្ខាសាលាសភាជាតិ កាលពីខែវិច្ឆិកា ឆ្នាំ២០០៩ ដែលមានដូចជា:<br>• បញ្ចប់នូវការរៀបចំផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់រៀបចំផែនការសកម្មភាព និងតាមដាននូវការអនុវត្តន៏ការងារកៀរគរ និងគ្រប់គ្រងចំណូលមកពីប្រេង ឧស្ម័ន និងធនធានរ៉ែដទៃទៀត ព្រមទាំងរៀបចំឱ្យមានការពិគ្រោះយោបល់ជាសាធារណៈទៅលើខ្លឹមសារ ក៏ដូចជាយន្តការនៅដើមឆ្នាំ ២០១០។<br><br>• រៀបចំឱ្យមានការពិគ្រោះយោបល់ទូលំទូលាយជាមួយអង្គការសង្គមស៊ីវិលអំពីខ្លឹមសារនៃផែនការសកម្មភាព និង ពិភាក្សាឱ្យមានការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងការអនុវត្ត និងតាម |

ជាននូវការអនុវត្តន៍ផែននៅដើម ឆ្នាំ២០១០។

- បង្កើតឱ្យមានជាប្រព័ន្ធមួយដែលចំណូលបានមកពីឧស្សាហកម្មនិស្សារណកម្មត្រូវបានផ្សព្វផ្សាយនៅក្នុងតារាង TOFE ឱ្យរឹតតែមានលក្ខណៈពិស្តារ តាមរយៈការបែងចែកចំណូលពីប្រេង ឧស្ម័ន និងធនធានរ៉ែយ៉ាងលំអិត។ ចំណូលនេះនឹងដាក់បញ្ចូល នៅតារាង TOFE ប្រចាំខែដែលនឹងត្រូវផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងឆ្នាំ២០១០។ រាជរដ្ឋាភិបាលនឹងធ្វើសាមញ្ញកម្មនូវការប្រមូលចំណូល ក៏ដូចជាការចំណាយដើម្បីធ្វើឱ្យមានភាពងាយស្រួលក្នុងដំណើការធ្វើសវនកម្ម។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចែករំលែកព័ត៌មានដែលទាក់ទងនឹងកិច្ចសន្យា និងចំណូលពីក្រុមហ៊ុនឯកជន ជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ ដទៃទៀតដើម្បីលើកកម្ពស់តម្លាភាពចំណូលពីប្រេង ឧស្ម័ន និងធនធានរ៉ែ។

- ដៃគូអភិវឌ្ឍន៍នានាគាំទ្រដល់ការកសាងសមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បី ឱ្យបុគ្គលិកស្ថាប័នពាក់ព័ន្ធមានសមត្ថភាពក្នុងការគ្រប់គ្រង និងធានាឱ្យបានថាព័ត៌មាន ចំណូលដែលរាយការណ៍ពីសំណាក់ក្រុមហ៊ុននានាគឺពិតជាត្រឹមត្រូវ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់នូវការសិក្សាបច្ចេកទេសមួយស្តីអំពី " ការវាយតម្លៃតម្រូវការក្នុងការកសាងសមត្ថភាព " ដើម្បីពិនិត្យនូវក្របខ័ណ្ឌច្បាប់ និងតួនាទីរបស់ស្ថាប័នក្នុងន័យធ្វើ ឱ្យមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រង និងលើកកម្ពស់អត្ថប្រយោជន៍ក្នុងស្រុកពីវិស័យប្រេង ឧស្ម័ន និងរ៉ែ។ សកម្មភាពទាក់ទិននឹងការកំណត់តម្រូវការក្នុងការកសាងសមត្ថភាពនឹងត្រូវបង្កើតឱ្យមានឡើង និងអនុវត្ត។

- យើងខ្ញុំសំណូមពរយកចំណុចជាអត្ថិភាពទាំង៥ ដែលមាននៅក្នុងកថាខ័ណ្ឌ ១៥៨ មកដាក់ទីនេះ ដោយសារចំណុចទាំងនោះជាគោលនយោបាយអាទិភាពដែលទាក់ទិននឹងពេលវេលាឆ្នាំ២០០៩-២០១០ ច្រើនជាងសកម្មភាពដែលបានអនុវត្តហើយ។

ដើម្បីឱ្យប្រតិបត្តិការគ្រប់គ្រងវិស័យនេះប្រកបដោយតម្លាភាព ដូចដែលបានបង្ហាញនៅក្នុងកថាខ័ណ្ឌ ៣៦៧ និង ៣៦៨ នៃពង្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ យើងខ្ញុំស្នើសុំដាក់បន្ថែមនូវៈ

- រាជរដ្ឋាភិបាលកម្ពុជានឹងលើកកម្ពស់ការបង្កើតមានតម្លាភាពនៃកិច្ចសន្យា និងបើកចំហដំណើរការដេញថ្លៃ ដែលជួយដល់រាជរដ្ឋាភិបាលក្នុងការរៀបចំចលនាសាច់ប្រាក់រឹតតែមានភាពប្រត្យក្ស ក៏ដូចជាបង្កើននូវកំរិតប្រកួតប្រជែងនៅក្នុងចំណោមក្រុមហ៊ុននានា ដែល

| | | |
|---|---|---|
| | | មិនត្រឹមតែកាត់បន្ថយហានិភ័យពីបក្សពួកនិយមប៉ុណ្ណោះទេ ប៉ុន្តែលើកទឹកចិត្តឱ្យមានការវិនិយោគបរទេសផ្ទាល់ប្រកបដោយគុណភាព។<br>• អាជ្ញាធរប្រេងកាតជាតិកម្ពុជា និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងដាក់បង្ហាញជាសាធារណៈនូវឈ្មោះរបស់ក្រុមហ៊ុនទាំងអស់ដែលបានផ្តល់អាជ្ញាប័ណ្ណ និងក្នុងការរុករក/ទាញយកផលពីប្រេង ឧស្ម័ន រ៉ែនិង ធនធានធម្មជាតិផ្សេងៗ ទៀត។ បញ្ជីឈ្មោះក្រុមហ៊ុនទាំងនោះនឹងផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់ អាជ្ញាធរប្រេងកាតជាតិកម្ពុជា និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងផ្សព្វផ្សាយនូវផែនការសកម្មភាពរបស់ក្រុមការងារអន្តរក្រសួង នៅក្នុង គេហទំព័ររបស់ខ្លួន។ |
| ២២៩ | ៤៥៧ | គោលបំណងនៅក្នុងកថាខ័ណ្ឌ៤៥៧ គឺមានភាពច្បាស់លាស់ ហើយត្រូវអធិប្បាយពិស្តារនៅក្នុងផ្នែក ខ (សកម្មភាព កម្មវិធី និង គម្រោង ដើម្បីអនុវត្ត គោលនយោបាយអាទិភាព)។ យើងខ្ញុំសូមសំណូមពរឱ្យមានសកម្មភាពដូចខាងក្រោមដាក់បញ្ចូលនៅក្នុងដំណើការធ្វើច្បាប់៖<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរប្រេងកាតជាតិកម្ពុជា ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងរៀបចំឱ្យមានកិច្ចប្រជុំនៅក្នុងអំឡុងឆ្នាំ២០០៩ ដើម្បីបញ្ចប់នូវច្បាប់ និងបទបញ្ញត្តិទាក់ទងនឹងពន្ធ ក៏ដូចជាការគ្រប់គ្រងវិស័យប្រេងកាត និងរ៉ែឱ្យបានបំណាច់ឆ្នាំ២០០៩។ ក្រសួងក៏ដូចជាស្ថាប័នពាក់ព័ន្ធនឹងផ្តល់ព័ត៌មានទាក់ទិននឹងដំណើរការនេះទៅកាន់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។<br>• ច្បាប់ស្តីពីប្រេងកាតត្រូវបានដាក់បញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីយោបល់នៅក្នុងឆ្នាំ២០០៩ ហើយច្បាប់នេះនឹងរំពឹងថាបញ្ជូនទៅរដ្ឋសភាជាតិនៅក្នុងឆ្នាំ២០១០។ រដ្ឋាភិបាលនឹងធ្វើការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ក៏ដូចជាសង្គមស៊ីវិល មុនពេលច្បាប់នេះបញ្ជូនទៅរដ្ឋសភាជាតិ ដើម្បីធ្វើការអនុម័ត។ |

* លេខទំព័រគឺសំដៅលើលេខទំព័រនៃ សេចក្តីព្រាងដំបូងនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌគឺសំដៅលើលេខកថាខ័ណ្ឌនៃ សេចក្តីព្រាងដំបូងនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣

ទំនាក់ទំនងព័ត៌មាន


លោក ម៉ម សម្បត្តិ ប្រធាន សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន

ទូរស័ព្ទ៖ ៨៥៥-២៣ ២១៧ ៦០៧

អ៊ីម៉ែល៖ mam_sambath@citylink.com.kh

គេហទំព័រ៖ www.crrt_cambodia.org.kh

# សិទ្ធិទទួលព័ត៌មាន

| ទំព័រ | កថាខ័ណ្ឌ | អត្ថបទដើមក្នុងសេចក្តីព្រាងទីមួយ ឆ្នាំ ២០០៩-២០១៣ | មតិយោបល់របស់អង្គការក្រៅរដ្ឋាភិបាល |
|---|---|---|---|
| ៩៧ | ៣២១ | **ការចូលរួម និងគាំទ្រពីសាធារណជនៈ** ការគាំទ្រ និងចូលរួមពីសាធារណជន គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការការពារការកាត់បន្ថយនិងការប្រយុទ្ធប្រឆាំងនឹង អំពើ ពុករលួយ ប្រកបដោយប្រសិទ្ធភាព។ដើម្បី សម្រេចបានគោលបំណងនេះរាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញ និងការពារសិទ្ធិសេរីភាពក្នុងការស្វែងរក ការទទួល បាន និងការផ្សព្វផ្សាយព័ត៌មានស្តីពីករណីអំពើពុករលួយ ក្នុងប្រព័ន្ធផ្សព្វផ្សាយ ។ ទោះជាដូចនេះក្តី ការងារនេះត្រូវបានធ្វើឡើង ក្នុងរបៀបមួយដែលមានការទទួល ខុសត្រូវ និងមានទំនុកទុកចិត្ត ដោយគោរពនូវ សិទ្ធិ សេរីភាពភាពស្មោះត្រង់ និងសេចក្តីថ្លៃថ្នូរបស់ប្រជាជន ទាក់ទងនឹង ការការពារ សន្តិសុខជាតិ និង សណ្តាប់ធ្នាប់ សាធារណៈ ។ | សិទ្ធិទទួលព័ត៌មាន គឺជាផ្នែកមួយដ៏សំខាន់ក្នុងការជម្រុញឱ្យមានតម្លាភាព និងការចូលរួមពីសាធារណជន ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ នៅពេលទទួលបាន ព័ត៌មានគ្រប់គ្រាន់ធ្វើឱ្យទំនាក់ទំនងរវាងប្រជាពលរដ្ឋនិងរាជរដ្ឋាភិបាលកាន់តែប្រសើរឡើង ថែមទាំង កសាងនិងបង្កើននូវជំនឿ និងទំនុកចិត្តរបស់ប្រជាពលរដ្ឋទៅលើថ្នាក់ដឹកនាំរបស់ខ្លួន។ ហេតុដូចនេះហើយ អង្គការសង្គមស៊ីវិល សុំស្នើឱ្យការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ ដាក់បញ្ចូលនូវច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មានជាគោលនយោបាយអទិភាពនៅក្នុង អណ្តតិទី៤នេះដើម្បីធានា និងការពារសិទ្ធិសេរីភាព ក្នុងការស្វែងរកទទួលបាននិងផ្សព្វផ្សាយព័ត៌មាន។ |
| ១៦៥ | ៣២៥<br><br>ចំណុច ទី ៣ | ដើម្បីអនុវត្តគោលនយោបាយអាទិភាព របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងទំនាក់ ទំនងរដ្ឋ សភា ព្រឹទ្ធសភា និងអធិការកិច្ច នឹងផ្តោតសកម្មភាពលើៈ<br>• ការពង្រឹង ស្ថាប័ន និងការអភិវឌ្ឍធនធាន មនុស្សដើម្បីបង្កើនសមត្ថភាពស្ថាប័ន នៅ ថ្នាក់ជាតិ និងរាជធានី-ខេត្ត ដើម្បី : (១) បន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអធិការ កិច្ចនីតិវិធីអធិការកិច្ច និងគោលនយោបាយ អធិការកិច្ច (២) បើកវគ្គបណ្តុះបណ្តាលស្តីពីជំនាញគ្រូបង្គោលផ្នែកផ្សព្វផ្សាយច្បាប់ជំនាញស៊ើបអង្កេតស្រាវជ្រាវ | យើងខ្ញុំសូមជំរាបជូនថា រហូតមកទាល់ពេលនេះ ឯកសារគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មាន ដែលបានត្រឹមតែពង្រាង ដោយក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ហើយមិនទាន់បានអនុម័តដោយទីស្តីការ គណរដ្ឋមន្ត្រីឱ្យក្លាយទៅជាឯកសារផ្លូវច្បាប់សំរាប់ប្រើជាឯកសារគោលក្នុងការបង្កើតនូវច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅឡើយ។ យើងខ្ញុំសូមស្នើយ៉ាងទទូចសូមឱ្យសេចក្តីព្រាងដំបូងនៃ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដាក់បញ្ចូលនូវការចាត់តាំងអំណាច និងពេលវេលាឱ្យច្បាស់លាស់មួយក្នុង ការរៀបចំឱ្យមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ លើសពីនេះទៀត យើងខ្ញុំស្នើសុំឱ្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដាក់បញ្ចូល យុទ្ធសាស្ត្រនិតិវិធីនិងយន្តការដែលបង្កឱ្យការអនុវត្តច្បាប់ស្តីពីសិទ្ធិទទួល |

| | | | |
|---|---|---|---|
| | | ជំនាញធ្វើកោសល្យវិច្ឆ័យគណនេយ្យ ជំនាញគ្រប់គ្រងធនធានមនុស្ស ជំនាញរដ្ឋបាលទូទៅ ជំនាញពិធីការ និងជំនាញរៀបចំផែនការ (៣) បង្កើតគម្រោងកន្សោមអាទិភាព និង (៤) សាងសង់អាគារមន្ទីរទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច រាជធានី-ខេត្តក្រុង ។ | ព័ត៌មានមានប្រសិទ្ធភាពស្របពេលដែលច្បាប់នេះត្រូវបាន អនុម័ត ។ |
| | | | |

* លេខទំព័រសំដៅលើលេខទំព័រដែលមានប្រើនៅក្នុងផយអជបច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី១**ផយអជ**បច្ចុប្បន្នកម្ម ២០០៩-២០១៣

ព័ត៌មានបន្ថែមសូមទាក់ទង:

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
លោក ស៊ីនថៃ ណែប នាយក វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ តំណាងឱ្យក្រុមការងារដើម្បីសិទ្ធិទទួលព័ត៌មាន
ទូរស័ព្ទ (៨៥៥-២៣)២១៣ ៤៨៦ ឬ (៨៥៥-១២)៥២៧ ០០៤
អ៊ីម៉ែល apioffice@apiinstitute.org or sinthayneb@apiinstitute.org
គេហទំព័រ www.apiinstitute.org
អាស័យដ្ឋាន: មជ្ឈមណ្ឌលភ្នំពេញ អគារ F ជាន់ទី ៤ បន្ទប់លេខ ៤៨៤ កែងមហាវិថីសីហនុ និងសុធារស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រនៃកម្ពុជា

## សមាជិកក្រុមការងារដើម្បីសិទ្ធិទទួលព័ត៌មាន

១ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)

២ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

៣ សមាគមអាដហុក (ADHOC)

៤ អង្គការអភិវឌ្ឍន៍សហគ្រាសកម្ពុជា (CEDO)

៥ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)

៦ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (CHRAC)

៧ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)

៨ អង្គការ អភិរក្ស និងអភិវឌ្ឍន៍កម្ពុជា (CDcam)

៩ អេខ្វលអាសេស (Equal Access)

១០ វិទ្យាស្ថានខ្មែរដើម្បីលិទ្ធិប្រជាធិបតេយ្យ (KID)

១១ មជ្ឈមណ្ឌលសំលេងស្ត្រីខ្មែរ (KWVC)

១២ សមាគមយុវជនខ្មែរ(KYA)

១៣ គណៈកម្មាធិការអព្យាក្រឹតនិងយុត្តិធមិដើម្បីការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវនៅកម្ពុជា(NIFEC)

១៤ អង្គការវេទិកាទូទៅនៃកម្ពុជា (OFC)

១៥ ផេកកម្ពុជា (Pact Cambodia)

១៦ មជ្ឈមណ្ឌល ប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-centre)

១៧ ស្តារកម្ពុជា (Star Kampuchea)

១៨ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រពន្ធ័ផ្សព្វផ្សាយឯករាជ្យ វី សំលេងប្រជាធិបតេយ្យ (VOD/CCIM)

១៩ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)

# អភិបាលកិច្ចល្អ នៅក្នុងផ្នែកការប្រឆាំងអំពើពុករលួយ

| ទំព័រ | កថាខ័ណ្ឌ | អត្ថបទដើមក្នុងសេចក្តីព្រាងទីមួយ ឆ្នាំ ២០០៩-២០១៣ | មតិយោបល់របស់អង្គការក្រៅរដ្ឋាភិបាល |
|---|---|---|---|
| ក. គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤ | | | |
| ៩៧ | ៣២១<br>ចំនុចទី១ | ***វិធានការទប់ស្កាត់ជាមុន*** :<br>រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញសកម្មភាព លើកកម្ពស់ការយល់ដឹងរាល់ទិដ្ឋភាពនៃ អំពើពុករលួយ ដែលរួមមានមូលហេតុ ឥទ្ធិពល និងផលវិបាក ដ៏គ្រោះថ្នាក់នៃអំពើ ពុករលួយដើម្បីបន្តលើកទឹកចិត្តសាធារណ-ជនឱ្យចូលរួមក្នុងការទប់ស្កាត់ និងប្រយុទ្ធ ប្រឆាំងនឹងអំពើពុករលួយបន្តចាត់វិធានការ ជាក់ស្តែង ដើម្បីលើកទឹកចិត្តមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ ឱ្យប្រកាន់ខ្ជាប់នូវសេចក្តី ថ្លៃថ្នូរសីលធម៌ស្អាតស្អំ និងអនុវត្តការងារ ប្រកបដោយមនសិការមុខវិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ។ | ▪ យើងខ្ញុំចង់មើលឃើញផងដែរនៅក្នុង បច្ចុប្បន្នឆ្នាំ កម្មផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ នូវសកម្មភាពនានាដែលអនុម័តដោយរាជរដ្ឋាភិបាលប្រឆាំងនឹងអំពើពុករលួយដែលត្រូវបានអនុវត្ត និង ត្រូវបានរាយការណ៍ឱ្យបាន ទៀងទាត់ ដោយមានទិន្នន័យអាចរកបានដោយសាធារណៈជន ។<br>▪ ការអប់រំ/ការជម្រុញការយល់ដឹងសាធារណៈ គប្បីត្រូវបានបញ្ជ្រាបឱ្យបានពេញលេញទៅក្នុងវិស័យ សាធារណៈ និង គប្បី មានវិសាលភាពទូលាយ និង មានឧបករណ៍ផ្សេងៗជាច្រើន ។<br>**បន្ថែមលើនេះ** ដើម្បីការអប់រំសាធារណៈ យើងខ្ញុំសូមស្នើសូមឱ្យបញ្ជាក់ឱ្យបានច្បាស់ថាភាគីពាក់ព័ន្ធទាំងអស់ ទាំងតួអង្គ រដ្ឋនិងតួអង្គមិនមែនរដ្ឋ គប្បីត្រូវបានចូលរួម ។<br>ការយល់ដឹងគប្បីរាប់បញ្ចូលការពិភាក្សាសម្រាប់ការអនុវត្ត ។ កថាខ័ណ្ឌដែលបានស្នើឡើង គប្បីត្រូវបានកែដូចខាងក្រោម: ***វិធានការការពារ:*** រាជរដ្ឋាភិបាលនឹងបន្តជម្រុញការយល់ដឹងអំពីគ្រប់ទិដ្ឋភាពទាំងអស់នៃអំពើពុករលួយ រួមមានមូលហេតុ ផលប៉ះពាល់ និង ផលវិបាករបស់វា ដើម្បីលើកទឹកចិត្ត ឱ្យមានការចូលរួមសាធារណៈ ***<u>តាមរយៈការពិភាក្សា និង</u>*** ***<u>ការផ្តល់ឱកាសជូនដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់</u>*** ទាំងតួអង្គរដ្ឋនិងតួអង្គមិនមែនរដ្ឋ |

| | | | |
|---|---|---|---|
| | | | ដូចជាអង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន***ដែលចូលរួមយ៉ាងសកម្ម*** ក្នុងការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ វិធានការជាក់ស្តែងនឹងត្រូវបានអនុវត្តដើម្បីលើកទឹកចិត្ត ឱ្យមន្ត្រីរាជរដ្ឋាភិបាលនៅ គ្រប់កម្រិតទាំងប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ សីលធម៌ វិជ្ជាជីវៈនិយាម និង ការទទួលខុសត្រូវក្នុងការបំពេញភារកិច្ចរបស់ ខ្លួន។ |
| ៩៨ | ៣២១ ចំនុចទី២ | ***ការគាំទ្រ និងការចូលរួមពីសាធារណៈជន :*** ការគាំទ្រ និងចូលរួមពីសាធារណៈជន គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការការពារ ការកាត់បន្ថយ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព ។ ដើម្បីសម្រេចបានគោលបំណងនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញ និង ការពារសិទ្ធិសេរីភាពក្នុងការស្វែងរកការទទួលបាន និងការផ្សព្វផ្សាយព័ត៌មានស្តីពីករណីអំពើពុករលួយក្នុងប្រព័ន្ធផ្សព្វផ្សាយ ។ ទោះជាដូចនេះក្តី ការងារនេះត្រូវបានធ្វើឡើងក្នុងរបៀបមួយ ដែលមានការទទួលខុសត្រូវ និងមានទំនុកទុកចិត្ត ដោយគោរពនូវសិទ្ធិសេរីភាព ភាពស្មោះត្រង់ និងសេចក្តីថ្លៃថ្នូរបស់ប្រជាជន ទាក់ទងនឹងការការពារសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ។ | ចំពោះចំណុចនេះ យើងខ្ញុំសូមស្នើសូមដកប្រយោគដូចតទៅនេះចេញ: ***ប៉ុន្តែ កិច្ចការនេះគប្បីត្រូវបានធ្វើក្នុងលក្ខណៈ អាចទុកចិត្តបាននិងមានការទទួលខុសត្រូវ ដោយគោរពសិទ្ធិ កិត្តិយស និង សេចក្តីថ្លៃថ្នូរ របស់អ្នកពាក់ព័ន្ធ ទន្ទឹមគ្នា នឹងការការពារសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ។*** |
| ៩៧ | ចំណុច បន្ថែម | មិនមាននៅក្នុងសេចក្តីព្រាងទីមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ | ក្នុងចំណុច (ក-៣២១) យើងខ្ញុំសូមស្នើសូមឱ្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បន្ថែមមួយចំណុចទៀត (ចំណុចទី ៥) ផ្សព្វផ្សាយ ***"គ្រប់ស្ថាប័ន/ការបង្កើតអនុក្រឹត្យ/គោលនយោបាយ ដើម្បីគាំទ្រការអនុវត្តច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយដែលនឹងអនុញ្ញាតអោយសង្គមស៊ីវិល និង*** |

| | | | |
|---|---|---|---|
| | | | ***ភាគីពាក់ព័ន្ធចូលរួមនៅក្នុងកិច្ចដំណើរការតាក់តែងទាំងមូល"។*** |

ក. សកម្មភាពគ្រោងដើម្បីអនុវត្តគោលនយោបាយអាទិភាពនានា ( ទំព័រ ៩៨)

នៅក្នុងបច្ចុប្បន្នកម្មទីមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៩-២០១៣ គេមិនឃើញភាពច្បាស់លាស់ទេ អំពីប្រភេទបណ្តឹងដែលអង្គភាពប្រឆាំងអំពើពុករលួយនឹងចាត់ចែង និង ប្រភេទបណ្តឹងដែលក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ចនឹងចាត់ចែង ។ ដើម្បីជៀសវាងភាពច្របូកច្របល់ ឯកសារនេះគប្បីកំណត់ថាតើបណ្តឹងទាំងនេះគឺជាប្រភេទបណ្តឹងខុសគ្នាឬទេ ។ ប្រសិនបើវាមិនមែនគឺជាប្រភេទបណ្តឹងខុសគ្នាទេ ឯកសារនេះចាំបាច់ត្រូវផ្តល់ការបំភ្លឺអំពីតួនាទីរបស់អង្គភាពប្រឆាំងអំពើពុករលួយ និង ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច ទាក់ទិននឹងការចាត់ចែងបណ្តឹងអំពើពុករលួយ ។

សេចក្តីព្រាងបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៩-២០១៣ គប្បីផ្តល់ព័ត៌មានលម្អិតអំពីរបៀបដែលការិយាល័យទទួលបណ្តឹងដំណើរការ ដោយលើកឡើងឱ្យបានច្បាស់លាស់អំពីបណ្តឹងទាំងឡាយដែលបាន ដោះស្រាយ និង បណ្តឹងទាំងឡាយដែលមិនបានដោះស្រាយ និង មូលហេតុអ្វី ។ យើងខ្ញុំក៏សូមស្នើផងដែរថា នៅក្នុងបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យន្តការទទួលបណ្តឹងគប្បីត្រូវបានពង្រីកទៅដល់គ្រប់ការិយាល័យរាជរដ្ឋាភិបាល ហើយប្រព័ន្ធមួយគប្បីត្រូវបានបង្កើតឡើងដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីវឌ្ឍនភាពនៃការងាររបស់ខ្លួនឱ្យបានទៀងទាត់ជូនសាធារណជន ។

លើសពីនេះទៀត បច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិគប្បីលើកឡើងឱ្យបានច្បាស់អំពីប្រភេទសផ្សេងៗគ្នានៃសកម្មភាពដែលត្រូវបានចាត់ប្រឆាំងនឹងក្រុមមនុស្សផ្សេងៗគ្នាសម្រាប់អំពើពុករលួយខុសៗគ្នា ហើយព័ត៌មានគប្បីត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រព័ន្ធចាប់តាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់ ។

| | | | |
|---|---|---|---|
| ៩៨ | ៣២៣ | ការបង្ការទប់ស្កាត់ជាមុន :<br>➢ បន្តជំរុញសកម្មភាពលើកកម្ពស់ការយល់ដឹង រាល់ទិដ្ឋភាពនៃអំពើពុករលួយ រួមមានមូលហេតុឥទ្ធិពល និងផលវិបាកដ៏គ្រោះថ្នាក់នៃអំពើពុករលួយ ដើម្បីបន្តលើកទឹកចិត្តសាធារណៈជន ឱ្យចូលរួមក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។<br>➢ បន្តចាត់វិធានការជាក់ស្តែងដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការគ្រប់លំដាប់ | ការទប់ស្កាត់<br>គឺជាឧបករណ៍ដ៏សំខាន់មែនទែនមួយដើម្បីដោះស្រាយអំពើពុករលួយ ។ បើការទប់ស្កាត់មានលក្ខណៈរឹងមាំ និង/ឬមានប្រសិទ្ធភាពកាន់តែច្រើន<br>នោះគេត្រូវការសកម្មភាពប្រតិបត្តិ/សកម្មភាពផ្នែកច្បាប់កាន់តែតិច ។ ហេតុដូច្នេះ<br>យើងខ្ញុំសូមស្នើសូមឱ្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្មកំណត់ឱ្យបានច្បាស់នូវការបង្កើតនិងការអនុវត្ត យន្តការទប់ស្កាត់ ។<br>ចំណុចនេះអាចចាប់ផ្តើមជាមួយនឹងការគូសផែទីភាពងា |

| | | | |
|---|---|---|---|
| | | ថ្នាក់ឱ្យប្រកាន់ខ្ជាប់នូវសេចក្ដីថ្លៃថ្នូរ សីលធម៌ស្អាតស្អំ និង អនុវត្តការងារប្រកបដោយ មនសិការមុខវិជ្ជាជីវៈ និងមានស្មារតីទទួលខុសត្រូវខ្ពស់ ។ | យរងគ្រោះចំពោះអំពើពុករលួយ និង/ឬ ការវាយតម្លៃហានិភ័យនៃសុចរិតភាពនៅក្នុងប្រព័ន្ធរដ្ឋបាល ហើយបន្ទាប់មក បង្កើតយន្តការដើម្បីដោះស្រាយ និង អនុវត្តយន្តការទាំងនេះ។ |

ព័ត៌មានបន្ថែមសូមទាក់ទង:


មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព

លោក យង់ គិមអេង នាយក មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព

ទូរស័ព្ទ : (៨៥៥-១៦)៨២៨ ២១១

ទូរសារ : (៨៥៥-២៣)៨៨៣ ៣០៤

អ៊ីម៉ែល: kimeng_yong@yahoo.com

អាស័យដ្ឋាន: លេខ៣១បេ ផ្លូវ ២៥៩ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

## សិទ្ធិកុមារ

| លេខទំព័រ * | លេខកថាខ័ណ្ឌ ** | អត្ថបទដើមដកស្រង់ពីសេចក្តីព្រាងលើកទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ | យោបល់អង្គការមិនមែនរដ្ឋាភិបាល ឬការស្នើឱ្យមានការកែប្រែ |
|---|---|---|---|
| ១៦៨ | ៣២៩<br>ចំណុចទី៤ | ១. កំណែទម្រង់ច្បាប់:<br>• បន្តការរៀបចំសេចក្តីព្រាងច្បាប់ដូចខាងក្រោម :<br>-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។<br>- បទប្បញ្ញត្តិ ដើម្បីធានាឯករាជភាព នៃស្ថាប័នអយ្យការ ។<br>- សេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈក្រឡាបញ្ជី។<br>- សេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈសារការី ។<br>- សេចក្តីព្រាងច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ។<br>- សេចក្តីព្រាងច្បាប់ស្តីពី អាជ្ញាសាលា ។<br>- សេចក្តីព្រាងច្បាប់ស្តីពី ការការពារអនីតិជន ។<br>- សេចក្តីព្រាងច្បាប់ស្តីពី សហប្រតិបត្តិការអន្តរជាតិ ។<br>- សេចក្តីព្រាងច្បាប់ស្តីពី ការចុះបញ្ជីអចលនវត្ថុ ។<br>- សេចក្តីព្រាងច្បាប់ស្តីពី ការតម្កល់ ។ | សូមស្នើសុំអោយក្រុមប្រឹក្សាកំណែច្បាប់ និង ប្រព័ន្ធយុត្តិធម៌ និង ក្រសួងយុត្តិធម៌ ដាក់បញ្ចូលបន្ថែមនូវសេចក្តីព្រៀងច្បាប់មួយទៀតគឺ **សេចក្តីព្រាងស្តីពីយុត្តិធម៌អនីតិជន** ទៅក្នុងការរៀបចំ ផែនការសកម្មភាព ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល កម្ពុជា សម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា |
| ១៦៩ | ៣២៩<br>ចំណុចទី ៥ | ២ កំណែតុលាការ:<br>• ពង្រីកសេវាកម្មយុត្តិធម៌ ដោយបង្កើត :<br>- តុលាការពិសេស តាមតម្រូវការ ដូចជា តុលាការពាណិជ្ជកម្ម តុលាការការងារ តុលាការអនីតិជន និង តុលាការរដ្ឋបាល ។<br>-សាលាឧទ្ធរណ៍នៅកម្រិតថ្នាក់ក្រោមជាតិ ដើម្បីសម្រួលល ដល់ប្រជាពលរដ្ឋ ទទួលបានសេវាប្រព័ន្ធតុលាការ ជាពិសេស ប្រជាពលរដ្ឋដែលរស់នៅខេត្តឆ្ងាយៗ និងសម្រួលនូវការកកស្ទះសំណុំរឿង នៅសាលាឧទ្ធរណរាជធានីភ្នំពេញ។<br>- បង្កើតឱ្យមានសាលាដំបូងនៅខេត្តប៉ៃលិន និងឧត្តរមានជ័យ ។<br>- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យច្បាប់ និងយុត្តិធម៌ ជាពិសេស ការជួយគ្នា ទៅវិញទៅមកតាមផ្លូវតុលាការ ក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន ។ | ស្នើសុំអោយបញ្ចូលការរៀបចំ ឬ បង្កើតប្រព័ន្ធយុត្តិធម៌ កុមារ។ |
| ២៥៦ | ៥១១ | រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ក្នុងការអនុវត្តយុទ្ធសាស្រ្ត "អប់រំសម្រាប់ទាំងអស់គ្នា" តាមរយៈការធានាសមធម៌ ក្នុងការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ សម្រាប់កុមារគ្រប់រូប ។ សមិទ្ធផលសំខាន់ៗរួមមាន ចំនួនសាលារៀន និងគ្រូបង្រៀន ព្រមទាំងអត្រាចុះ ឈ្មោះចូលរៀន នៅគ្រប់កម្រិត សិក្សានៃចំណេះទូទៅ បានកើនឡើងជា លំដាប់ ពិសេស នៅតាមតំបន់ជនបទ ។ ដោយឡែក អនុវិទ្យាល័យ ត្រូវបានបង្កើតឡើងនៅ | ស្នើសុំអោយមានបង្ហាញនូវចំនួនសាលារៀន គ្រូបង្រៀន អត្រាចុះឈ្មោះចូលរៀន ចំនួនភាគរយនៃថវិកាជាតិដែល បានផ្តល់ដល់វិស័យអប់រំ (ក្រសួងអប់រំ) ក្នុងឆ្នាំកន្លងទៅ។ |

| | | | |
|---|---|---|---|
| | | ស្មើរគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស។ ចំនួនគ្រឹះ ស្ថាន មធ្យមសិក្សាបច្ចេកទេស និងគ្រឹះស្ថានឧត្តមសិក្សាព្រមទាំង ចំនួន បុគ្គលិកបង្រៀន ក៏បានកើនឡើងគួរឱ្យកត់សម្គាល់ដែរ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើនថវិកយ៉ាងច្រើន សម្រាប់វិស័យអប់រំ ។ ក្នុងនីតិកាលទី៣ កន្លងទៅនេះ ថវិកាចំណាយចរន្តសម្រាប់វិស័យអប់រំបានកើនឡើងទ្វេរដងក្នុងឆ្នាំ២០០៧ធៀបទៅនឹងឆ្នាំ២០០៣ បើគិតជាភាគរយនៃថវិកាចរន្តសរុប ថវិកាចរន្តសម្រាប់វិស័យអប់រំមាន ប្រមាណ ១៩,២ភាគរយ ។ រាជរដ្ឋាភិបាលសម្រេចបានជោគជ័យគួរជាទីមោទនៈ ក្នុងការលើកកម្ពស់ភាពជាដៃគូជាមួយដៃគូ អភិវឌ្ឍនទៅក្នុងវិស័យអប់រំនេះ រួមទាំង ដៃគូផ្លូវការ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល ។ | |
| ២៥៦ | ៥១២ | ក្នុងនីតិកាលទី ៤ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកមជ្ពា នឹងបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់ កុមារនិងយុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត និងឋានៈនៅក្នុងសង្គមឡើយ ។ ម៉្យាងវិញទៀត ការអនុវត្តផែនការយុទ្ធសាស្ត្រនេះត្រូវផ្សារភ្ជាប់ នឹងការអប់រំ វប្បធមិ សន្តិភាព ការគោរពសិទ្ធិនិង សេចក្តីថ្លៃថ្នូរ របស់មនុស្ស ការគោរពគោលការណសេរីភាពប្រជាធិបតេយ្យនិងយុត្តិធមិដោយប្រឆាំងនឹងអំពើហិង្សាប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន ការជួញដូរកុមារនិងស្ត្រី និងការរើសអើងគ្រប់ប្រភេទក្នុងសង្គម ។ | ស្នើសុំអោយមានការផ្សារភ្ជាប់ជាមួយនូវគោលនយោបាយក្នុងការលុបបំបាត់ពលកម្មកុមារ ជាពិសេស ការលុបបំបាត់រាល់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ក្នុងឆ្នាំ២០១៥ ។ |
| ២៥៦ | ៥១៣ | ៥១៣. រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តយកចិត្តទុកដាក់លើ ការកែលម្អគុណភាពអប់រំ តាមរយៈ ការលើកទឹកចិត្តគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា ការលើកទឹកចិត្តសិស្សពូកែ ការបណ្តុះបណ្តាលគ្រូបង្រៀននិងបំប៉នវិធីសាស្ត្របង្រៀន ព្រមទាំងការកែលម្អលក្ខខណ្ឌនៃការសិក្សានិងការផ្គត់ផ្គង់សម្ភារៈសិក្សា ការបង្កើតបណ្ណាល័យមន្ទីរពិសោធន៏ជាដើម ។ ក្នុងទិសដៅធានាកាលានុវត្តភាពប្រកប ដោយសមធមិ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តបង្កើតអន្តេវាសិកដ្ឋាន សម្រាប់សិស្ស-និស្សិតជាពិសេស សម្រាប់សិស្ស-និស្សិតជានារីភេទ និងបន្តសាងសង់សាលារៀនគ្រប់កម្រិតសិក្សា ជាពិសេស នៅតាមតំបន់ជនបទនិងតំបន់ដាច់ស្រយាលនិងការបង្កើនអាហារូបករណ៏សម្រាប់សិស្ស-និស្សិតក្រីក្រ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយ គុណភាព ឱ្យបានគ្រប់គ្រាន់ និង អនុវត្តគោលនយោបាយ ពង្រាយគ្រូឱ្យមានប្រសិទ្ធភាព ។ រាជរដ្ឋាភិបាលកម្ពុជានឹងលើកទឹកចិត្តឱ្យគ្រូបង្រៀន | ស្នើសុំអោយមានការពិនិត្យទៅលើការកែលំអរ គុណភាពអប់រំ សូមអោយមានវិធានការទៅការអំពើពុករលួយក្នុងថ្នាក់រៀន ការប្រើ អំពើហិង្សាក្នុងថ្នាក់រៀន ការបើកម៉ោង បង្រៀនគួរដែលជាការជំរិតទារប្រាក់ពី សិស្ស ដោយការចេញវិញ្ញាសារប្រឡង តែទៅលើមេរៀនបង្រៀនគួរដែលជាហេតុធ្វើអោយប៉ះពាល់ការផែនការរបស់រាជរដ្ឋាភិបាលចំពោះការបន្តការកែលម្អគុណភាពអប់រំ ។ |

| | | | |
|---|---|---|---|
| | | បឋមភូមិ និងគ្រូដែលបានបន្តរៀនចប់បរិញ្ញាប័ត្រ បានប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ដោយគ្មានកម្រិតអាយុ និងបង្កលក្ខណៈសម្បត្តិឱ្យគ្រូបង្រៀនបឋមសិក្សា ដែលមិនទាន់មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ មានលទ្ធភាពប្រឡងយកសញ្ញាប័ត្រសមមូលមធ្យមសិក្សាទុតិយភូមិ ដើម្បីផ្តល់ឱកាសឱ្យពួកគាត់មានលទ្ធភាពរៀននៅថ្នាក់ឧត្តមសិក្សា និងផ្លាស់ប្តូរនូវកាំប្រាក់បៀវត្សរ៍បាន ។ | |
| ២៦១ | ៥២០ | ដើម្បីដំណោះស្រាយ នូវបញ្ហាប្រឈមនានា ក្នុងអំឡុងពេលអនុវត្ត ផយអជ ឆ្នាំ២០០៦-២០១០ និងផ្អែកលើបទពិសោធន កន្លងមក ក្រសួងអប់រំយុវជននិងកីឡា នឹងជំរុញល្បឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងអាណត្តិនៃ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយ :<br>• គោលនយោបាយទី១ : ធានាការទទួលបានសេវាកម្មអប់រំ ប្រកបដោយសមធម៌<br>➢ ផ្តល់ឱកាសដល់កុមារក្នុងវ័យសិក្សាទាំងអស់ឱ្យបានចូលរៀនទាំងអស់គ្នា តាមរយៈការរៀបចំ ផែនការអភិវឌ្ឍសម្ភារូបវ័ន្ត ដោយសហការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ។<br>➢ បង្កើនតួលេខជ្រើសរើសគ្រូតាមមូលដ្ឋាន ពិសេសតំបន់ជួបការលំបាក ដើម្បីដោះស្រាយបញ្ហាគម្លាតក្នុងការពង្រាយគ្រូរវាងតំបន់ប្រជុំជន និងតំបន់ជនបទ និងអនុវត្តគោលការណពង្រាយគ្រូ ឱ្យមានប្រសិទ្ធភាព ជាពិសេស គ្រូទើបចេញថ្មី និងការគ្រប់គ្រងបុគ្គលិកធម្មតា ។<br>➢ កែលំអការរក្សាសិស្សឱ្យនៅក្នុងសាលារៀន តាមរយៈការលុបបំបាត់ឧបសគ្គចំណាយរបស់មាតាបិតាសិស្សដូចជាចំណាយក្រៅផ្លូវការនិងបង្កើនចំនួនអាហារូបករណសម្រាប់សិស្សមកពីគ្រួសារក្រីក្រជាពិសេសសិស្សស្រី ។ | ស្នើសុំអោយមានការធ្វើវិសោធនកម្មច្បាប់អប់រំ ឬ បញ្ចូលទៅក្នុងផែនការអប់រំ ដើម្បីធានាថាកុមារ នៅក្នុងពន្ធនាគារទទួលបាននូវការអប់រំ ។ |
| ២៦១ | ៥២០<br>ចំណុចទី ៣ | គោលនយោបាយទី៣ : អភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពដល់បុគ្គលិកអប់រំ<br>➢ ពង្រឹងអភិបាលកិច្ចល្អនៅគ្រប់កម្រិត រួមទាំង ការធ្វើសនិទានកម្មការគ្រប់គ្រងបុគ្គលិក ដូចជា ប្រាក់បៀវត្ស ការជ្រើសរើស ការតែងតាំង និងការផ្លាស់ប្តូរ ការរៀបចំលិខិតបទដ្ឋានស្តីពីការប្រើប្រាស់ថវិកាឱ្យស្របទៅនឹងកម្មវិធីបែងចែកថវិកាការពង្រឹងសវនកម្មផ្ទៃក្នុងនិងយន្តការតាមដានតាមដានពិនិត្យ ដោយរួមបញ្ចូលទាំងការកែលម្អសុក្រឹតភាព និងភាពទៀងទាត់ របស់ស្ថិតិ ។<br>➢ បន្តកែលម្អប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ តាមរយៈកសរពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល និងពង្រឹង | ស្នើសុំអោយមានការបញ្ជ្រាបក្នុងគោលនយោបាយសិក្សានិងការអនុវត្តន៍ការងារជាក់ស្តែង អំពីសិទ្ធិកុមារ ជាពិសេស សិទ្ធិទទួលបាននូវការអប់រំ ។ និងស្នើសុំអោយរដ្ឋាភិបាលតម្លើងប្រាក់បៀវត្ស ព្រមទាំងមានការរៀបចំប្រាក់បៀវត្សដើម្បីបើកដល់បុគ្គលិកសិក្សាទាន់ពេលវេលា ។ |

| | | | |
|---|---|---|---|
| | | ប្រព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ។<br>➢ ពង្រឹងការគ្រប់គ្រងកម្មវិធីអភិវឌ្ឍសមត្ថភាពតាមរយៈការកែលម្អកិច្ចសម្របសម្រួលសកម្មភាព និងបង្កើនការយកចិត្តទុកដាក់នៅថ្នាក់ក្រោមជាតិ ។<br>➢ ពន្លឿនការបញ្ជ្រាបយេនឌ័រ ដោយមានគោលនយោបាយយេនឌ័រច្បាស់លាស់នៅក្នុងវិស័យអប់រំយុវជន និងកីឡា និងផែនការយុទ្ធសាស្ត្រ ។ | |
| ២៦៧ | ៥២៧<br>ចំណុចទី ៤<br>កថាខ័ណ្ឌទី៤ | • ក្នុងផ្នែកប្រព័ន្ធមានសុខាភិបាល សកម្មភាពដែលនឹងត្រូវអនុវត្ត រួមមាន<br>➢ពង្រីកការចូលរួមរបស់វិស័យឯកជន<br>នៅក្នុងប្រព័ន្ធពតិមានសុខាភិបាល ជាតិ និងសម្រួលការប្រើប្រាស់ទិន្នន័យសម្រាប់ ការរៀបចំផែនការ ការ<br>បែងចែកធនធាន ការគ្រប់គ្រងធនធានមនុស្សហេដ្ឋារចនាសម្ព័ន្ធ និងការផ្គត់ផ្គង់ ។ | ស្នើសុំអោយបញ្ចូលរាល់វិធានការតាមផ្លូវច្បាប់ចំពោះមន្ទីរពេទ្យឯកជនដែលផ<br>្តល់ សេវា<br>ធ្វើអោយគ្រោះថ្នាក់ដល់អាយុជីវិតប្រជាពលរដ្ឋ និងដែលពុំបានអនុវត្ត ទៅតាមក្រមសីលធម៏វិជ្ជាជីវៈ។ |
| ២៧៣ | ៥៣៧ | វិស័យជាយុទ្ធសាស្ត្រទាំង៥ រួមមាន ៖<br>• ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។<br>• ការបង្កើនការអប់រំ និងការផ្លាស់ប្តូរអត្តចរិក ដល់ស្ត្រី និងក្មេងស្រី ។<br>• ការការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី ។<br>•ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភ និងការទប់ស្កាត់ការីករាលដាល ជម្ងឺអេដសដល់ស្ត្រី និងក្មេងស្រី។<br>• ការជំរុញការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុងវិស័យសាធារណៈ និងក្នុងវិស័យនយោបាយ ។ | ស្នើសុំឱ្យមាន៖<br>- ការលើកកំពស់ការយល់ ដឹងពីសិទ្ធិស្មើភាពគ្នារបស់ក្មេងស្រីក្នុងការ ចូលរៀននៅថ្នាក់មធ្យមសិក្សា និង ឧត្តមសិក្សា និងបង្កើនការចូលរៀនរបស់ក្មេង ស្រីតាមរយៈការផ្តល់ជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ និងដោះស្រាយឫសគល់វប្បធម៌ ដែល ជាការរើសអើងចំពោះក្មេងស្រី<br>-ធានាសុវត្ថិភាពដល់ក្មេងស្រីពេលទៅ និងមក ពីសាលារៀន។<br>-លើកកំពស់ការយល់ដឹងអំពីអត្ថប្រយោជន៍នៃការអប់រំសំរាប់ក្មេងស្រី ទាក់ទងនឹងការជួយរកប្រាក់ចំណូលបន្ថែម ក្នុងគ្រួសារទៅអនាគត។ |
| ២៧៤ | ៥៤០ | នៅក្នុងវិស័យជាយុទ្ធសាស្ត្រទី៣ ដែលផ្តោតការយកចិត្តទុកាដាក់លើការការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី ក្រសួងកិច្ចការនារី ដោយមានសហការយ៉ាងជិតស្និទ្ធជាមួយ ភាគីដែលមានចំណែកពាក់ពន្ធ័ទាំងអស់ | ស្នើសុំឱ្យមានការដាក់បញ្ចូលនូវខ្លឹមសារ និងការអនុវត្តន៏ច្បាប់ អន្តរជាតិមួយចំនួន ដូចជា អនុសញ្ញាស៊ីដ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ២៧៦ | ៥៤១ | នៅក្នុងវិស័យជាយុទ្ធសាស្ត្រទី៤ ដែលផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់សុខភាព អាហារូបត្ថម្ភនិងទប់ស្កាត់ការីករាលដាលជម្ងឺអេដស៍ដល់ស្ត្រីនិងក្មេស្រី ក្រសួងកិច្ចការនារី ដោយសហការយ៉ាងជិត | ស្នើសុំឱ្យមានការកាត់បន្ថយការដាក់បំរាមលើការអប់រំ ផ្លូវភេទតាមរយៈការលើកកំពស់ពីអត្ថប្រយោជន៏របស់វា លើផ្នែក |

| | | | |
|---|---|---|---|
| | | ស្និទ្ធជាមួយ ភាគីដែលមានចំណែកពាក់ពន្ធ័ទាំងអស់ នឹងផ្តោតការយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗ | សុខភាព និងសុវត្ថិភាពហើយសូមផ្តល់ព័តិមានសមស្របដល់ អាព្យាលកុមារឱ្យការអប់រំពីបញ្ហានេះថាមិនមានការលើកទឹកចិត្តអោយកុមារសាកល្បងការរួមភេទនោះទេ។ |

* លេខទំព័រសំដៅលើលេខទំព័រដែលមានប្រើនៅក្នុងផយអជបច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី១**ផយអជ**បច្ចុប្បន្នកម ២០០៩-២០១៣

សម្រាប់ព័តិមានទំនាក់ទំនង:

| |
|---|
| គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGO-CRC)<br>លោក មាស សំណាង អគ្គលេខាធិការ<br>លេខទូរស័ព្ទ: ០២៣ ៨៨២ ៤១២<br>អ៊ីម៉េល: info@ngocrc.org |

## កិច្ចអភិវឌ្ឍទំនប់វារីអគ្គិសនី និងវិស័យថាមពល

សំណើសម្រាប់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកិច្ចការនារី ក្រុមការងារបច្ចេកទេសផ្នែកសិកម្ម និងទឹក ក្រុមការងារបច្ចេកទេសផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងសមាហរណកម្មតំបន់ ក្រុមការងារបច្ចេកទេសផ្នែកជលផល ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន។

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| ៦០ | ១១៥ | ទោះបីជាមានការសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្តី ក៏វិស័យជលផលនៅតែជួបប្រទះបញ្ហាប្រឈមជាច្រើនៈ<br>• យើងខ្ញុំសូមផ្តល់អនុសាសន៍សូមនិយាយយោងដល់ការលំបាកក្នុងការទប់ស្កាត់ និង ការសម្រាលផលប៉ះពាល់អវិជ្ជមានលើជលផលដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍វារីអគ្គិសនី នៅប្រទេសកម្ពុជា និង នៅក្នុងតំបន់ទន្លេមេគង្គ។ ដោយសារជលផលផ្គត់ផ្គង់ប្រហែល ៨២% នៃប្រូតេអ៊ីនសត្វនៅកម្ពុជា វារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គ ក៏នឹងមានផលប៉ះពាល់ខ្លាំងផងដែរលើសន្តិសុខស្បៀងនៃប្រទេសកម្ពុជា។ ការយកចិត្តទុកដាក់ជាពិសេសចាំបាច់ត្រូវផ្តោតលើអនាគតដើម្បីធានាឱ្យបានថាការអភិវឌ្ឍថាមពលនៃប្រទេសកម្ពុជាមិនមានផលប៉ះពាល់អវិជ្ជមានលើជលផលកម្ពុជា ពាក់ព័ន្ធនឹងបរិមាណនិងពូជត្រី។ |
| ៦២ | ១២៣ | យោងតាមលិខិតចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៩ ពី សហគមន៍ទន្លេ ៣S (ទន្លេសេសាន ទន្លេស្រែពក ទន្លេសេកុង) ផ្ញើជូនគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC) សហគមន៍នេះ បានផ្ញើរបាយការណ៍មួយដែលមានបីទំព័រស្តីពីគុណភាពទឹកមិនល្អនៅក្នុងទន្លេសេសាន ស្រែពក និង សេកុង។ សហគមន៍ទាំងឡាយមានការបារម្ភថាគុណភាពទឹកមិនល្អនៃទន្លេទាំងនេះអាចបណ្តាលមកពីប្រតិបត្តិការនៃទំនប់វារីអគ្គិសនីនៅខ្សែទឹកខាងលើនៅប្រទេសវៀតណាម និង ការសាងសង់ទំនប់វារីអគ្គិសនីទន្លេសេសានក្រោម ២ ក្នុងខេត្តស្ទឹងត្រែង។ ម្យ៉ាងទៀត របាយការណ៍បច្ចេកទេស សង្ខេបឆ្នាំ ២០០៩ មួយ (ចេញផ្សាយលេខ ១២) ដោយគម្រោង STRIVER បាន បញ្ជាក់អះអាងអំពីវត្តមាននៃបាក់តេរី cyanobacteria, algae toxin microsystin, thermo-tolerant |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| | | coliform bacteria និង E. Coli នៅក្នុងទន្លេសេសាននៅកម្ពុជា។<br>គុណភាពទឹកមិនល្អ និង ផលប៉ះពាល់របស់វាលើសុខភាព ត្រូវបានផ្សារភ្ជាប់នឹងទៅនឹងទឹកកខ្វក់នៅក្នុងអាងទឹកដែលស្ថិតនៅខាងលើខ្សែទឹកនៅក្នុងប្រទេសវៀតណាម។<br>• យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យការតាមដានគុណភាពទឹកសម្រាប់អភិរក្សជីវចម្រុះ ដាក់បញ្ចូលតំបន់នានាដែលសម្បូណ៌ជីវចម្រុះ ដូចជាបឹងទន្លេសាប ទីកន្លែងនានានៅតាមដងទន្លេមេគង្គទាំងមូល និង នៅតាមដៃទន្លេ ៣ស (ទន្លេសេសាន ទន្លេស្រែពក ទន្លេសេកុង)។ រាជរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធត្រូវធានាឱ្យបានថាគុណភាពទឹកនៃទន្លេទាំងនេះគឺអាចទទួលយកបានសម្រាប់ទាំងជីវចម្រុះ និងប្រជាជន។ ការតាមដានគុណភាពទឹក គប្បីដាក់បញ្ចូលទិដ្ឋភាពបរិស្ថាននិងសុខភាព។ ម្យ៉ាងទៀត យើងខ្ញុំសូមស្នើសុំឱ្យរាជរដ្ឋាភិបាលអនុវត្តការស៊ើបអង្កេតលើរបាយការណ៍ទាំងនេះ និង ទាមទារសំណង និង ការសម្រាលផលប៉ះពាល់ពីប្រទេសវៀតណាម ពាក់ព័ន្ធនឹងជម្ងឺនិងមរណភាពទាក់ទិននឹងទឹកដែលទទួលរងដោយប្រជាជនកម្ពុជា ដោយសារការអភិវឌ្ឍវារីអគ្គិសនីនៅខ្សែទឹកខាងលើ។ |
| ៣៦ | ១២៨ | ការយកចិត្តទុកដាក់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីការសម្របសម្រួលទំនប់នៅតាមព្រំដែននៃប្រទេសកម្ពុជា វៀតណាម ឡាវ និង ថៃឡង់ដ៏ គប្បីផ្តោត លើបញ្ហាទឹកឡើងចុះមិនទៀងទាត់ ដែលត្រូវទទួលរងគ្រោះដោយសហគមន៍ទាំងឡាយ នៅតាមដងទន្លេសេសាន និងទន្លេស្រែពក ដោយសារការអភិវឌ្ឍវារីអគ្គិសនីនៅខ្សែទឹកខាងលើក្នុងប្រទេសវៀតណាម។<br>• យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យ ប្រទេសកម្ពុជាខិតខំធានាឱ្យបានថាប្រទេសវៀតណាមគោរពតាមការសន្យាកន្លងមករបស់ខ្លួនចំពោះកម្ពុជាអំពីការសាងសង់អាងគ្រប់គ្រងទឹកទន្លេសេសាន ៤អា និង ទន្លេស្រែពក ៤អា (ដែលបានធ្វើនៅក្នុងសិក្ខាសាលាស្តីពីកិច្ចប្រជុំភាគីពាក់ព័ន្ធដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧ ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ទន្លេស្រែពកនៅ ប៉ែកខាងកម្ពុជាដោយសារការអភិវឌ្ឍវារីអគ្គិសនីនៅប្រទេសវៀតណាម និង ការកែលម្អប្រព័ន្ធផ្តល់ព័ត៌មានអំពីការបញ្ចេញទឹក |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| | | (កិច្ចព្រមព្រៀង ៩ ចំណុច)។ |
| ៦០ | ១១៥ | • យើងខ្ញុំសូមស្នើសូមឱ្យដាក់បន្ថែមបញ្ហាប្រឈមនៃតម្រូវការទឹកដ៏ច្រើនសម្រាប់ការអភិវឌ្ឍថាមពល (រោងចក្រវារីអគ្គិសនី និង រោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម) និង គម្រោងស្រោចស្រព ទៅក្នុងបញ្ជីនៃបញ្ហាប្រឈមនានា ដោយសារគម្រោងទាំងនេះអាចបណ្តាលឱ្យមានវិវាទនាអនាគតលើការប្រើប្រាស់ទឹក និង អាចនាំទៅដល់ការខ្វះខាតទឹក ដែលជាហេតុផលប៉ះពាល់ដល់តម្រូវការទឹករបស់សាធារណជននៅតាមទីក្រុងនិងជនបទ។ |
| ៧៧ | ១៩៧ | • យើងខ្ញុំសូមស្នើសូមឱ្យលើកឡើងផងអំពីព័ត៌មានស្តីពីបញ្ហាប្រឈមនានាដែលគេជួបប្រទះក្នុងការអនុវត្តផែនការមេអគ្គិសនីកម្មជនបទ។ |
| ២០៥ | ៤១៥ | • យើងខ្ញុំសូមស្នើសូមឱ្យរដ្ឋបាលជលផលធ្វើការស្រាវជ្រាវ និង រៀបចំព្រឹត្តិការណ៍នៃកិច្ចពិភាក្សាសាធារណៈស្តីពីប្រធានបទបច្ចេកវិទ្យាសម្រាលផលប៉ះពាល់នៃទំនប់វារីអគ្គិសនី និង ជលផល។ រដ្ឋបាលជលផលគប្បីព្យាយាមធានាឱ្យបានថាយន្តការសមស្របសម្រាប់ សម្រាលផលប៉ះពាល់ផលប៉ះពាល់ជលផលបណ្តាលមកពីទំនប់វារីអគ្គិសនីត្រូវបានជម្រុញ ហើយក្នុងករណីពុំមានបច្ចេកវិទ្យាដើម្បីសម្រាលផលប៉ះពាល់ជលផល រដ្ឋបាលជលផលគប្បីធ្វើយុទ្ធនាការជម្រុញការយល់ដឹងជូនសាធារណជននិងរាជរដ្ឋាភិបាល ដើម្បីជួយដល់កិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើព័ត៌មានពេញលេញ។ |
| ២០៧ | ៤១៩ | • យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាល (រដ្ឋបាលព្រៃឈើ) គប្បីធានាឱ្យបានប្រាកដថាពុំមានការកាប់ឈើខុសច្បាប់នៅក្នុងតំបន់ការងារនៅក្នុងអំឡុងពេលឆ្ការព្រៃសម្រាប់ធ្វើទីតាំងអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនី។ ចំណុចនេះគប្បីត្រូវបានធ្វើតាមរយៈការឃ្លាំមើលឱ្យបានត្រឹមត្រូវ និង ការប្រតិបត្តិច្បាប់ដ៏មធ្យ័ត។ ការដាំដើមឈើឡើងវិញនូវព្រៃឈើដែលបាត់បង់ក៏ត្រូវបានលើកទឹកចិត្តផងដែរ ហើយការសន្យាជាមុនណាមួយដែលបានធ្វើដោយក្រុមហ៊ុនវារីអគ្គិសនី ថានឹងដាំដើមឈើឡើងវិញ ក៏គប្បីត្រូវបានអនុវត្តផងដែរ។ ព្រៃឈើជាជម្រកដ៏ចាំបាច់សម្រាប់សត្វព្រៃគ្រប់ប្រភេទ ដូចនេះ |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| | | យើងខ្ញុំសូមស្នើសូមឱ្យក្រសួងបរិស្ថានកំណត់នូវយន្តការសមស្របបំផុតក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ ជាពិសេសសត្វព្រៃកម្រ និងជិតផុតពូជអំឡុងពេលឆ្កាព្រៃសម្រាប់សាងសង់អាងស្តុកទឹករបស់ទំនប់វារីអគ្គិសនី ។ |
| ២០៩ | ៤២២ | ក្រសួងបរិស្ថាន នឹងរៀបចំច្បាប់និងឯកសារភាពយន្ត ដោយៈ រៀបចំគោលការណ៍ណែនាំស្តីពីរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន<br>• យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរៀបចំគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ដោយពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និង រួមមានគោលការណ៍ណែនាំលម្អិតស្តីពីរបៀបកំណត់ថាតើគេចាំបាច់ត្រូវមានការវាយតម្លៃចម្រុះលើផលប៉ះពាល់បរិស្ថាន (IEIA) ឬ  ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ឬទេ និង គោលការណ៍ណែនាំលម្អិតស្តីពីវិធីអនុវត្ត កិច្ចដំណើរការចូលរួមជាសាធារណប្រកបដោយអត្ថន័យនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ |
| ២១០ | ៤២៥ | អត្ថបទដើមៈ ពន្លឿនការអនុវត្តគម្រោងបំភាយឧស្ម័នផ្ទះកញ្ចក់<br>• យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាលកម្ពុជាពិចារណានិងអនុម័តលើគម្រោងផលិតអគ្គិសនីពីប្រភពថាមពលដែលមិនមានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) ទៅក្នុងបរិយាកាស ។<br>យើងខ្ញុំសូមជម្រុញឱ្យរាជរដ្ឋាភិបាលលើកទឹក ចិត្តដល់ការផលិតអគ្គិសនីដោយប្រើបច្ចេកវិទ្យាស្អាតនិងទំនើប ដូចជាជីវឧស្ម័ន ជីវម៉ាស់ ថាមពលព្រះអាទិត្យ និងថាមខ្យល់ ទន្ទឹមគ្នានឹងការជៀសវាង ការអភិវឌ្ឍរោងចក្រវារីអគ្គិសនី និងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម ដោយសារការបំភាយឧស្ម័នផ្ទះកញ្ចក់ចេញពីរោងចក្រទាំងនេះ ។<br>• យើងខ្ញុំក៏សូមផ្តល់អនុសាសន៍ផងដែរសូមឱ្យកែលម្អភាសាអង់គ្លេសដែលត្រូវបានប្រើនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីបញ្ជាក់ថាក្រសួងបរិស្ថាននឹងពន្លឿនការអនុវត្តគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ។ |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| ២១២ | ៤២៨ | • ដោយសារប្រជាជនដែលរស់នៅតាមដងទន្លេពឹងអាស្រ័យលើទឹកទន្លេសម្រាប់នេសាទត្រី ធ្វើដំណើរ និងការប្រើប្រាស់ទឹកប្រចាំថ្ងៃក្នុងគ្រួសារ ។ល។ យើងខ្ញុំសូមផ្តល់ អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាលកំណត់ជាអាទិភាពនៅក្នុងផែនការជាតិនូវ គម្រោងទាំងឡាយដែលកែលម្អលទ្ធភាពទទួលបានទឹកស្អាតសម្រាប់សហគមន៍ ដែលបានទទួលរងផលប៉ះពាល់អវិជ្ជមានពីគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី ទាំងនៅក្នុងប្រទេសវៀតណាម និង កម្ពុជា។ |
| ២២១ | ៤៤៣ | • យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យ ក្រសួងធនធានទឹកនិងឧតុនិយម ដាក់បញ្ចូលចំនុចមួយក្នុងការសិក្សា និងពិចារណាចំពោះផែនការអភិវឌ្ឍន៍អាងទន្លេ ដំណាក់កាលទី២ ដោយរួមបញ្ចូលការចូលរួមគ្រប់ភាគីពាក់ព័ន្ធ និងកំណត់ការចូលរួមឱ្យបានច្រើនលើសលប់ពីសំណាក់សហគមន៍ក្នុងមូលដ្ឋាន។<br>• យើងខ្ញុំក៏សូមផ្តល់អនុសាសន៍ផងដែរសូមឱ្យក្រសួងធនធានទឹកនិងឧតុនិយម បង្កើនសមត្ថភាពបុគ្គលិករបស់ក្រសួង និង ក្រសួងពាក់ព័ន្ធ ដើម្បីយល់ដឹងអំពីទស្សនាទាននៃការគ្រប់គ្រងធនធានទឹកបែបចម្រុះ (IWRM) និង ចាប់ផ្តើមអនុវត្តគោលការណ៍នេះនៅក្នុងការងាររបស់ខ្លួន (ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក) |
| ២២២ | ៤៤៥ | ii. ពង្រឹងនិងលើកទឹកចិត្តដល់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ដើម្បីឃ្លាំមើលនិងទប់ស្កាត់រាល់គម្រោងស្ថាបនីតិសម្បទា និងគម្រោងសាងសង់ទាំងឡាយណាដែលអាចមានផលប៉ះពាល់អវិជ្ជមានលើធនធានទឹក និងប្រព័ន្ធអេកូឡូស៊ី។<br>• ដោយសារការចូលរួមសាធារណៈ គឺជាទិដ្ឋភាពគន្លឹះមួយនៃការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយព័ត៌មានពេញលេញ យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាលកម្ពុជាដាក់បញ្ចូលព័ត៌មានអំពីវិធីដែលខ្លួននឹងធានាឱ្យបាននូវការចូលរួមសាធារណៈនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តទាក់ទិននឹងវារីអគ្គិសនី ដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើធនធានទឹក។ ការប្តេជ្ញារបស់ប្រទេសកម្ពុជាចំពោះការធានាឱ្យបាននូវការគ្រប់គ្រងលើការអភិវឌ្ឍធនធានទឹក យោងតាមការគ្រប់គ្រងចម្រុះលើធនធានទឹក (មាត្រា ៤ នៃច្បាប់ |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| | | ស្តីពីការគ្រប់គ្រងធនធានទឹកឆ្នាំ ២០០៧) ក៏គប្បីត្រូវបានលើកឡើងផងដែរ ។ ការវាយតម្លៃលើរបៀបដែលប្រទេសកម្ពុជាបានអនុវត្ត IWRM នៅក្នុងការអភិវឌ្ឍវារីអគ្គិសនីរបស់ខ្លួន ជាពិសេស ពាក់ព័ន្ធនឹងការធ្វើផែនការបែបចូលរួម និង ការចូលរួមរបស់ភាគីពាក់ព័ន្ធ គប្បីត្រូវបានធ្វើនៅក្នុងកិច្ចដំណើរការវាយតម្លៃរបស់ខ្លួន ។<br>• ធានាឱ្យបានថាគម្រោងអភិវឌ្ឍន៍នានា ដូចជា ទំនប់វារីអគ្គិសនី រោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម និង គម្រោងស្រោចស្រព ត្រូវបំពេញគ្រប់លក្ខខណ្ឌគតិយុត្តិចាំបាច់ទាំងអស់ ដូចជាការអនុវត្តច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុនពេលផ្តល់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតឱ្យប្រើទឹក ។ |
| ២២៨ | ៤៩៤ | • យើងខ្ញុំសូមស្នើសូមឱ្យក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រៀបចំផែនការមេថ្មីមួយ ដែលដាក់បញ្ចូលផែនការអគ្គិសនីកម្មជនបទនិងទីក្រុង និង ដាក់បញ្ចូលគ្រប់បច្ចេកវិទ្យាថាមពលទាំងអស់នៅក្នុងផែនការតែមួយ ។ ផែនការមេនេះគប្បីដាក់បញ្ចូលផែនការនានារបស់រាជរដ្ឋាភិបាលសម្រាប់ជម្រុញការវិនិយោគឯកជនលើជម្រើសផលិតថាមពលប្រកបដោយនិរន្តរភាពនានា (ដែលអាចទទួលយកបានទាំងខាងបរិស្ថាននិងសង្គម) រួមជាមួយនឹងផែនការនានារបស់រាជរដ្ឋាភិបាល រួមទាំងផែនការមេវារីអគ្គិសនីដែលបានរៀបចំដោយ JICA និង ផែនការអគ្គិសនីកម្មជនបទផង ។<br>• រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចំពោះការលើកទឹកចិត្តដល់ "ការរុករក និង ការអភិវឌ្ឍធនធានអាចទទួលយកបានទាំងខាងបរិស្ថាននិងសង្គម ដែលចាំបាច់សម្រាប់ផ្គត់ផ្គង់ជូនដល់គ្រប់វិស័យទាំងអស់នៅក្នុងសេដ្ឋកិច្ចកម្ពុជា" នៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យអគ្គិសនីរបស់ខ្លួន ។ យើងខ្ញុំសូមស្នើសូមឱ្យក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដាក់បញ្ចូលការប្តេជ្ញានេះទៅក្នុងបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៩-២០១៣ ។ |
| ២២៨ | ៤៩៥ | ដើម្បីកាត់បន្ថយភាពក្រីក្រ និង ធានាឱ្យបាននូវភាពសុខុដុមនៅក្នុងជីវិតរបស់ប្រជាជននៅតាមតំបន់ជនបទ រាជរដ្ឋាភិបាលនឹងបន្តផ្សារភ្ជាប់អាទិភាពទៅនឹងការពន្លឿនអគ្គិសនីកម្មជនបទ រួមទាំងការប្រើថាមពលកកើតឡើងវិញផង ។ |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| | | • យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាលកម្ពុជាផ្តល់អាទិភាពខ្ពស់ចំពោះការអភិវឌ្ឍការផលិតថាមពលកកើតឡើងវិញបែបវិមជ្ឈការ ផ្អែកលើទម្រង់មួយប្រកបដោយចីរភាពថាមពល ខណៈដែលរាជរដ្ឋាភិបាលខិតខំឆ្ពោះទៅកាន់ការពន្លឿនអគ្គិសនីកម្មជនបទ។ ដើម្បីធ្វើកិច្ចការនេះ យើងខ្ញុំសូមស្នើសូមឱ្យ រាជរដ្ឋាភិបាលកម្ពុជាមេត្តាពិចារណាអំពីការលើកទឹកចិត្ត និងការផ្តល់អាទិភាពដល់ការផលិតថាមពលបែបវិមជ្ឈការ តាមរយៈបច្ចេកវិទ្យាអាចទទួលយកបានទាំងខាងបរិស្ថាននិងសង្គម ទន្ទឹមគ្នានឹងការផ្លាស់ប្តូរគោលនយោបាយដែលលើកទឹកចិត្តដល់ការផលិតអគ្គិសនីបែបវិមជ្ឈការ។ យើងខ្ញុំសូមផ្តល់អនុសាសន៍ សូមឱ្យរាជរដ្ឋាភិបាលកម្ពុជាអនុវត្តគោលនយោបាយ និង គំនិតផ្តួចផ្តើមផ្អែក និយ័តកម្ម: <br>១. ដាក់ឱ្យអនុវត្តកម្មវិធីផ្តល់ហិរញ្ញប្បទានជូនអតិថិជន ដើម្បីជួយគ្រួសារអាជីវកម្ម និង សហគមន៍បង់ថ្លៃដើមទុនសម្រាប់បច្ចេកវិទ្យាផលិតអគ្គិសនីខ្នាតតូចនិងខ្នាតឧស្សាហកម្ម ក្នុងរយៈពេលពី ៥ ទៅ ១០ ឆ្នាំ។ <br>២. បើកទូលាយទីផ្សារសម្រាប់ការផលិតអគ្គិសនីបែបវិមជ្ឈការ ដោយប្រកាសគោលនយោបាយជាក់លាក់ទាក់ទិននឹងបច្ចេកវិទ្យាឈានមុខគេ និង មិនមានដាក់កំហិតលើបរិមាណនៃអគ្គិសនីដែលបច្ចេកវិទ្យានីមួយៗផលិតឡើយ។ <br>៣. ដាក់ឱ្យដេញថ្លៃក្នុងលក្ខណៈប្រកួតប្រជែងសម្រាប់ការបន្ថែមសមត្ថភាពផលិតអគ្គិសនីបែបវិមជ្ឈការ តាមដែនដីសេវាកម្ម និង ដោយបង្កើនពីរបីមេហ្គាវ៉ាត់ប្រកបដោយហានិភ័យទាប តាមតម្រូវការរបស់ទីផ្សារផ្សេងៗគ្នា។ <br>៤. ផ្តល់ជូនក្រុមហ៊ុនផលិតអគ្គិសនីទាំងអស់នូវលទ្ធភាពចូលដល់បណ្តាញចែកចាយក្នុងមូលដ្ឋានដោយគ្មានការរើសអើង និង ដាក់ឱ្យអនុវត្តនូវស្តង់ដារតភ្ជាប់គ្នាដែលបម្រើដល់ក្រុមហ៊ុនផលិតអគ្គិសនីទាំងអស់។ <br>៥. ផ្តល់ជូនវិនិយោគិននិងក្រុមហ៊ុនអភិវឌ្ឍគម្រោងនូវស្ថេរភាពនិងសញ្ញាតម្លៃដែលពួកគេត្រូវការ ដោយផ្តល់នូវយន្តការមានតម្លាភាពនិងច្បាស់លាស់ |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| | | សម្រាប់កំណត់តម្លៃនិងស្រង់ដើម ។<br>៦. បង្កើតនីតិវិធីមួយជំហានម្តងៗច្បាស់លាស់ និងប្រកបដោយតម្លាភាព សម្រាប់ទទួលបានលិខិតអនុញ្ញាតនិងការយល់ព្រមពីសាធារណៈ ។<br>៧. កំណត់លក្ខខណ្ឌឱ្យបង្ហាញភស្តុតាងជាមុននៃការយល់ព្រមរបស់សហគមន៍ និង អ្នកមានសិទ្ធិគ្រប់គ្រងដីសម្រាប់ទីតាំងគម្រោង ដើម្បីផ្តល់អាជ្ញាប័ណ្ណដោយអាជ្ញាធរនិយ័តកម្ម ។<br>អភិក្រមថាមពលកាន់តែទំនើបមួយ នឹងអនុញ្ញាតឱ្យប្រទេសផលិតថាមពលក្នុងលក្ខណៈប្រកបដោយប្រសិទ្ធភាពនិងចីរភាព ទន្ទឹមគ្នានឹងការជៀសវាងការវិនិយោគ ដែលចំណាយច្រើនមានហានិភ័យខ្ពស់និងមានលក្ខណៈធ្វើឱ្យខូចខាតបរិស្ថាន លើបច្ចេកវិទ្យាចាស់ ដូចជាទំនប់វ៉ារីអគ្គិសនី និង រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មជាដើម ខណៈដែលបំពេញបានកាន់តែប្រសើរឡើងនូវសេចក្តីត្រូវការថាមពលរបស់ប្រជាជននិងប្រទេស ។ |
| ២២៩ | ៤៥៨ | រាជរដ្ឋាភិបាល ជម្រុញឱ្យប្រើថាមពលប្រកបដោយប្រសិទ្ធភាពដែលមានផលប៉ះពាល់អប្បបរមាលើបរិស្ថាន ។<br>• យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាលកម្ពុជា បន្ថែមផងដែរនូវព័ត៌មានអំពីរបៀបដែលរាជរដ្ឋាភិបាលកម្ពុជានឹងសម្រាលផលប៉ះពាល់ និង ផ្តល់សំណងសម្រាប់ផលប៉ះពាល់ទាំងឡាយដែលបណ្តាលមកពីគម្រោងថាមពល ជូនដល់បុរសនិងស្ត្រីក្រីក្រនៃប្រទេសកម្ពុជា ជាពិសេស ជនជាតិដើមភាគតិច ដែលពឹងអាស្រ័យលើធនធានធម្មជាតិរបស់ប្រទេស ជាពិសេស ជលផលនិងដីកសិកម្ម ក៏ដូចជាប្រភពជីវភាព និង សន្តិសុខស្បៀងផងដែរ ។ ព័ត៌មានលម្អិតគប្បីត្រូវបានផ្តល់អំពីភាគីពាក់ព័ន្ធណាដែលទទួលខុសត្រូវលើការរៀបចំនិងការអនុវត្តវិធានការសម្រាលផលប៉ះពាល់ ។ |
| ២២៩ | ៤៥៩ | iii. រៀបចំគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិនិងនិយ័តកម្មសម្រាប់វិស័យថាមពល ដើម្បីធានាឱ្យបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និង ការប្រើប្រាស់ធនធានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និង កែលម្អជីវភាពរបស់ប្រជាជនកម្ពុជា ។ |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| | | • ដើម្បីរៀបចំគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិនិងនិយ័តកម្មសម្រាប់វិស័យថាមពលដែលកែលម្អជីវភាពរបស់ប្រជាជនកម្ពុជា យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាលកម្ពុជាខិតខំរៀបចំក្របខ័ណ្ឌគតិយុត្តិស្តីពីវារីអគ្គិសនី និងរៀបចំផងដែរនូវច្បាប់ស្តីពីការបែងចែកផលប្រយោជន៍ ដើម្បីធានាឱ្យបានថាសហគមន៍រងផលប៉ះពាល់ដោយផ្ទាល់និងដោយប្រយោលបានទទួលរងឥទ្ធិពលវិជ្ជមានពីការអភិវឌ្ឍទំនប់វារីអគ្គិសនី។ យើងខ្ញុំក៏សូមជម្រុញរាជរដ្ឋាភិបាលផងដែរសូមឱ្យប្តេជ្ញាចំពោះការអនុវត្តស្តង់ដារអនុវត្តអន្តរជាតិប្រសើរបំផុតដូចជាស្តង់ដារទាំងឡាយដែលត្រូវបានកំណត់ដោយគណៈកម្មការពិភពលោកស្តីពីទំនប់ នៅក្នុងដំណាក់កាលធ្វើផែនការ សាងសង់ និង ប្រតិបត្តិការនៃការអភិវឌ្ឍវារីអគ្គិសនី. |
| ២២៩ | ៤៦០ | ជម្រុញការប្រើប្រាស់ប្រភពថាមពលក្នុងមូលដ្ឋាន ដូចជា វារីអគ្គិសនី ឧស្ម័នធម្មជាតិ និងធ្យូងថ្ម។<br>• យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាផងដែរចំពោះការជម្រុញ និង ការ*ផ្តល់អាទិភាព*ដល់ការប្រើថាមពលកកើតថ្មីប្រកបដោយនិរន្តរភាព ដើម្បីបំពេញសេចក្តីត្រូវការអគ្គិសនីរបស់ប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលក៏គប្បីលើកទឹកចិត្តផងដែរដល់ការធ្វើបច្ចុប្បន្នកម្មកិច្ចដំណើរការធ្វើផែនការថាមពលរបស់ខ្លួន ដើម្បីដាក់បញ្ចូលការរិះរកប្រភពថាមពលទំនើបមាននិរន្តរភាពជាង ជាជាងរោងចក្រវារីអគ្គិសនី និង រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មដែលធ្វើឱ្យខូចខាតទាំងបរិស្ថាននិងសង្គម ។ |
| ២៣០ | ៤៦០ | ប្រឹងប្រែងបន្ថែមទៀតដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និង សង្គមក្នុងការអនុវត្តគម្រោងថាមពល ទន្ទឹមគ្នានឹងការការពារប្រសិទ្ធភាពសេដ្ឋកិច្ចនៃគម្រោងនីមួយៗ។<br>• យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាលកម្ពុជាលើកឡើងផងដែរអំពីការការពារសិទ្ធរបស់សហគមន៍ក្នុងមូលដ្ឋានដែលនឹងត្រូវរងផលប៉ះពាល់អវិជ្ជមានពីការអភិវឌ្ឍថាមពល ដើម្បីខិតខំឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ រាជរដ្ឋាភិបាលក៏គប្បីប្តេជ្ញាផងដែរចំពោះការចែករំលែក |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| | | រយៈពេលវែងនូវផលប្រយោជន៍នៃទំនប់វារីអគ្គិសនីជាមួយសហគមន៍នានាដែលរងផលប៉ះពាល់ពីគម្រោងទាំងនេះ ។ យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យផ្តល់ជូនសហគមន៍រងផលប៉ះពាល់នូវភាគរយជាក់លាក់មួយនៃប្រាក់ចំណូលរបស់គម្រោង ដោយផ្អែកលើបរិមាណគីឡូវ៉ាត់នៃអគ្គិសនីដែលបានផលិត ដើម្បីជួយធានាឱ្យបានថាសហគមន៍ទាំងនេះក៏បានទទួលអត្ថប្រយោជន៍ផងដែរពីការអភិវឌ្ឍទំនប់ ។ |
| ២៦៣ | ៤៧២ | I. ពង្រឹងផ្នែកឯកជន និង ទាក់ទាញការវិនិយោគ<br>ខ. ផែនការសកម្មភាពដើម្បីអនុវត្តគោលនយោបាយជាអាទិភាពនានា<br>• យើងខ្ញុំសូមស្នើសូមឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដាក់បញ្ចូលការលើកឡើងអំពីរបៀបដែលរាជរដ្ឋាភិបាលកម្ពុជានឹងលើកទឹកចិត្តដល់ការវិនិយោគលើជម្រើសថាមពលនានាដែលអាចទទួលយកបានទាំងខាងបរិស្ថាននិងសង្គម ។<br>• បច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៩-២០១៣ គប្បីរាយបញ្ជី ឬ ផ្តល់ការនិយាយយោងដល់ស្ថានភាពបច្ចុប្បន្ននៃគម្រោងក្នុងប្រទេសទាំងឡាយដែលកំពុងត្រូវបានអនុវត្ត ដើម្បីឱ្យសាធារណជនបានដឹងអំពីស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍថាមពលនៅកម្ពុជា ។ |
| ២៧៣ | ៥៣៧ | ស្ត្រីនិងកុមារ គឺងាយរងគ្រោះជាងគេពីផលប៉ះពាល់អវិជ្ជមាននៃការអភិវឌ្ឍទំនប់វារីអគ្គិសនី ។ ការអភិវឌ្ឍទំនប់វារីអគ្គិសនីមានផលប៉ះពាល់អវិជ្ជមានលើលទ្ធភាពរបស់ស្ត្រីនៅតាមសហគមន៍រងផលប៉ះពាល់ក្នុងការរកធនធានធម្មជាតិ ដើម្បីទ្រទ្រង់ជីវភាព និងតម្រូវការសន្តិសុខស្បៀងរបស់ខ្លួន រួមទាំងលទ្ធភាពទទួលបានជលផល ផលិតផលកសិកម្ម ចម្ការ អនាម័យទឹក និង សុខភាព ។ បញ្ហាខាងលើនេះនិងដំណោះស្រាយ គប្បីត្រូវបានដាក់បញ្ចូលទៅក្នុងបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ ។<br>• យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាល និង ភាគីពាក់ព័ន្ធនានា ដាក់បញ្ចូលយន្តការដោះស្រាយ និងផែនការដើម្បីកាត់បន្ថយបញ្ហាប្រឈមនានាដែលស្ត្រីជួបប្រទះនៅតាមសហគមន៍ដែលរងផលប៉ះពាល់ពីការអភិវឌ្ឍទំនប់ |

| ទំព័រ* | កថាខ័ណ្ឌ** | សំណើ/យោបល់សម្រាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ |
|---|---|---|
| | | វារីអគ្គិសនី ទៅក្នុងបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ ដើម្បីធានាឱ្យបាននូវការលើកកម្ពស់នូវស្ថានភាពរស់នៅឱ្យបានប្រសើរឡើងសម្រាប់ស្ត្រីនៅក្នុងសហគមន៍មូលដ្ឋាន។<br>• យើងខ្ញុំសូមជូនអនុសាសន៍ឱ្យយកចិត្តទុកដាក់ខ្លាំងសូមឱ្យបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុង កិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តសម្រាប់គ្រប់គម្រោងអភិវឌ្ឍន៍ទាំងអស់ និង ការអភិវឌ្ឍសហគមន៍។ យើងខ្ញុំសូមជម្រុញឱ្យស្ថាប័នរាជរដ្ឋាភិបាលនៅ គ្រប់កម្រិតទាំងអស់ពិចារណានិងទទួលយកការបារម្ភ សំណើ និង អនុសាសន៍ របស់ស្ត្រីដាក់ចូលទៅក្នុងផែនការជាតិ។ ម្យ៉ាងទៀត ស្ត្រីនៅ តាមសហគមន៍មូលដ្ឋានគប្បីត្រូវបានលើកទឹកចិត្ត និង ផ្តល់ អំណាចឱ្យក្លាយទៅ ជាអ្នកចូលរួមដ៏សកម្មនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការផ្តល់ ឱកាសកសាងសមត្ថភាព។ |

* លេខទំព័រសំដៅលើលេខទំព័រដែលមានប្រើនៅក្នុងផយអជបច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី១**ផយអជ**បច្ចុប្បន្នកម ២០០៩-២០១៣

**ព័ត៌មានសម្រាប់ទំនាក់ទំនង:**


វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

ជា ផល្លីកា មន្ត្រីគម្រោងសិទ្ធសហគមន៍ និងទំនប់វារីអគ្គិសនី

ទូរស័ព្ទលេខ: (+៨៥៥) ២៣ ២១៤ ៤២៩, លេខភ្ជាប់បន្ត ១០៦

ទូរសារ: (+៨៥៥) ២៣ ៩៩៤ ០៦៣

អ៊ីម៉ែល: phallika@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh

## ការការពារបរិស្ថាន អភិរក្ស និង ការប្រែប្រួលអាកាសធាតុ

សំណើសម្រាប់ក្រសួងបរិស្ថាន ក្រុមការងារបច្ចេកទេសផ្នែកព្រៃឈើនិងបរិស្ថាន និង ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។

| ទំព័រ* | គថាខ័ណ្ឌ** | យោបល់របស់អង្គការមិនមែនរដ្ឋាភិបាល |
|---|---|---|
| ៣៥ | ១១៨ | កិច្ចការពារតំបន់អភិរក្ស គឺសំខាន់ខ្លាំងណាស់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។ ដើម្បីអាចធានាឱ្យបាននូវការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ រាជរដ្ឋាភិបាលកម្ពុជាគប្បីធានាឱ្យបាននូវការប្រើប្រាស់ធនធានធម្មជាតិឱ្យបានគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការនាពេលបច្ចុប្បន្ន ទន្ទឹមគ្នានឹងការការពារវបនីយភណ្ឌសម្រាប់សេចក្តីត្រូវការអនាគត។<br><br>ជីវភាពរស់នៅជនបទរបស់សហគមន៍មូលដ្ឋាន គឺពឹងអាស្រ័យលើបរិស្ថាននិងធនធានធម្មជាតិជាពិសេស នៅតាមតំបន់ជលផល និង អនុផលព្រៃឈើ (NTFPs)។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ដែលគោរពតាមគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ច្បាប់ពាក់ព័ន្ធផ្សេងទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា) គឺចាំបាច់សម្រាប់គម្រោងអភិវឌ្ឍន៍ភាគច្រើន ដើម្បីធានាឱ្យបាននូវកិច្ចការពារបរិស្ថាន។ មកដល់ពេលនេះ របាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍នានា ត្រូវបានគេសង្កេតឃើញថាមានគុណភាពទាប ខ្វះការចូលរួមជាសាធារណៈ និងការពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ មានវិធានការកាត់បន្ថយផលប៉ះពាល់តិចតួច ដើម្បីការពារបរិស្ថាន ខណៈដែលផែនការគ្រប់គ្រងបរិស្ថានមិនច្បាស់លាស់ គ្មានការចែករំលែកអត្ថប្រយោជន៍ជាមួយសហគមន៍រងផលប៉ះពាល់ និង ខ្វះការតាមដានដើម្បីធានាឱ្យបានប្រាកដថាការប្តេជ្ញានានាត្រូវបានគេគោរពអនុវត្ត។ ទន្ទឹមនឹងនេះ សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅមិនទាន់ត្រូវបានអនុម័តនៅឡើយ ខណៈដែលរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានពិតជាមានអាត្ថិភាពត្រូវបានចែករំលែកជាមួយអង្គការសង្គមស៊ីវិល តែក្នុងរយៈពេលខ្លីមួយប៉ុណ្ណោះសម្រាប់ពិនិត្យមើលនិងផ្តល់យោបល់។ សហគមន៍រងផលប៉ះពាល់នៅមិនទាន់ត្រូវបានគេដាក់បញ្ចូលក្នុងកិច្ចដំណើរការពិគ្រោះយោបល់នៅឡើយ។<br><br>ស្របតាមយោបល់ខាងលើ យើងខ្ញុំសូមផ្តល់អនុសាសន៍ខាងក្រោមជូនក្រសួងបរិស្ថានៈ<br>- កែលម្អកិច្ចសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធនិងសង្គមស៊ីវិល ដើម្បីធ្វើការស៊ើបអង្កេតនិងការឃ្លាំមើលរួមគ្នាលើផែនការគ្រប់គ្រងបរិស្ថាន (EMP) នៃគម្រោងអភិវឌ្ឍន៍ ដើម្បីអនុវត្តច្បាប់ជាធរមាន និង ចាត់វិធានការតាមការ |

| | | |
|---|---|---|
| | | ចាំបាច់។<br>- កែលម្អសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយដាក់បញ្ចូលយោបល់ពីសង្គមស៊ីវិលនិងភាគីពាក់ព័ន្ធ ដើម្បីជួយដោះស្រាយកង្វល់សំខាន់ៗមួយចំនួនដែលបានលើកឡើងខាងលើ។ |
| ៣៥ | ១១៩ | ថ្វីបើក្រសួងបរិស្ថាន បាននិងកំពុងអនុវត្តកម្មវិធីសំខាន់ៗដើម្បីដោះស្រាយបញ្ហាបរិស្ថានក្តី ក៏យើងបានសង្កេតឃើញថានៅមានបញ្ហាបរិស្ថានមិនទាន់បានដោះស្រាយជាច្រើននៅកម្ពុជា ដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍នានាៈ ផលប៉ះពាល់ឆ្លងព្រំដែន (គុណភាពទឹក ប្រព័ន្ធអេកូឡូស៊ីនៃទន្លេសេសាន និង ផលប៉ះពាល់ចំពោះជីវភាព) នៃទំនប់យ៉ាលីរបស់វៀតណាមលើសហគមន៍សេសាននៅប្រទេសកម្ពុជា ការបូមដីខ្សាច់ អភិវឌ្ឍន៍តំបន់ឆ្នេរ ផលប៉ះពាល់លើសុខភាពមនុស្សនៃរោងចក្រក្រដាសនៅសង្កាត់ចាក់អង្រែ ការធ្វើឱ្យកខ្វក់ដោយជាតិគីមីនៅក្នុងទន្លេមេគង្គនិងបឹងទន្លេសាប ដោយសារការប្រើគីមីនិងថ្នាំសម្លាប់សត្វល្អិត ផលប៉ះពាល់នៃការយករ៉ែ កង្វះការគ្រប់គ្រងសំណល់រឹង និង ការវិនិយោគនៅក្នុងតំបន់ការពារ។<br><br>ថ្វីបើប្រទេសកម្ពុជាត្រូវការកិច្ចអភិវឌ្ឍន៍ក្តី ក៏រាជរដ្ឋាភិបាលកម្ពុជាគប្បីខិតខំកំណត់អាទិភាពលើគម្រោងទាំងឡាយ ដែលរួមចំណែកដល់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ទន្ទឹមគ្នានឹងការជៀសវាងគម្រោងដែលមានហានិភ័យបរិស្ថានខ្ពស់ដែរ។ យើងខ្ញុំសូមផ្តល់អនុសាសន៍សុំឱ្យក្រសួងបរិស្ថានផ្តល់អាទិភាពលើការដោះស្រាយបញ្ហាបរិស្ថានមានស្រាប់ ទន្ទឹមគ្នានឹងការសហការជាមួយក្រសួងពាក់ព័ន្ធ សង្គមស៊ីវិល និង សហគមន៍ ដើម្បីចាប់ផ្តើមដោះស្រាយបញ្ហាទាំងឡាយដែលបានលើកឡើងខាងលើ។ |
| ៣៥ | ១២០ | យើងខ្ញុំសូមស្នើរាជរដ្ឋាភិបាល ជាពិសេស ក្រសួងបរិស្ថាន សូមផ្តល់ព័ត៌មានស្តីពីចំនួនរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលត្រូវបានដាក់ជូនក្រសួង ប្រៀបធៀបនឹងចំនួនរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានពិនិត្យមើលដោយក្រសួងបរិស្ថាន។ យើងខ្ញុំក៏សូមស្នើផងដែរ សូមឱ្យក្រសួងបរិស្ថានផ្តល់ព័ត៌មាន អំពីកន្លែងណាដែលសាធារណជនអាចមើលរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង កិច្ចព្រមព្រៀងស្តីពីកិច្ចការពារបរិស្ថានដែលត្រូវបានចុះហត្ថលេខា។ ម្យ៉ាងទៀត ក្រសួងបរិស្ថានគប្បីធានាឱ្យបានថារាល់របាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាំងអស់ដែលកំពុងត្រូវបានពិនិត្យ ត្រូវបានបើកទូលាយជូនសាធារណៈ ដើម្បីឱ្យភាគីពាក់ព័ន្ធបានពិនិត្យមើលនិងផ្តល់យោបល់ ធានាឱ្យបាននូវភាពត្រឹមត្រូវនៃព័ត៌មាន និង ជួយធានាឱ្យបាននូវយន្តការសម្រាល ហេតុប៉ះពាល់សមស្របសម្រាប់កិច្ចការពារបរិស្ថាន។ |

| | | |
|---|---|---|
| ៣៥ | ១២១ | បរិមាណនៃសំណល់រឹង បានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ទិន្នន័យដែលត្រូវបានផ្តល់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គប្បីត្រូវបានពិនិត្យមើលឡើងវិញដើម្បីធានាភាពត្រឹមត្រូវ ដោយសារទិន្នន័យនេះមិនត្រូវគ្នាជាមួយនឹងការសិក្សានាពេលថ្មីៗដែលធ្វើដោយអង្គការ KOICA ដូចដែលបានលើកឡើងនៅក្នុងកាសែតរស្មីកម្ពុជា ដែលបានប៉ាន់ស្មានថាបរិមាណនៃសំណល់រឹងនៅរាជធានីភ្នំពេញបានឡើងដល់ ១.១០០ តោនក្នុងមួយថ្ងៃ។ (កាសែតរស្មីកម្ពុជា ឆ្នាំទី ១៧ លេខ ៥០៨៤ កាលបរិច្ឆេទ ថ្ងៃទី ២៧-២៨ ខែ ធ្នូ ឆ្នាំ ២០០៩) ។ បរិមាណនៃសំណល់រឹងនិងសំណល់ដែលគេប្រមូលបានកើនឡើងជាង ២០០ តោន ក្នុងរយៈពេល ៣ ឆ្នាំដែលបានរួមចំណែកដល់ការអភិវឌ្ឍទីកន្លែងចាក់សម្រាមបន្ថែមទៀត។ ទីកន្លែងចាក់សម្រាមទាំងនេះ អាចមានផលប៉ះពាល់លើសុខភាពរបស់សហគមន៍ទាំងឡាយដែលរស់នៅជុំវិញទីកន្លែងចាក់សម្រាម ក៏ដូចជាផលប៉ះពាល់លើគុណភាពទឹក និង អាចរួមចំណែកដល់ការឡើងកម្តៅផែនដីតាមរយៈបន្សាយឧស្ម័នផ្ទះកញ្ចក់ (GHG) ។<br><br>យើងខ្ញុំសូមស្នើសូមឱ្យក្រសួងបរិស្ថាន ធ្វើចំណុចខាងក្រោមនេះ<br><br>- ការគ្រប់គ្រងសំណល់រឹង ចាំបាច់ត្រូវកែលម្អ។ កែលម្អការគ្រប់គ្រងសំណល់រឹងដោយការបែងចែកសំរាមផ្សេងពីគ្នា (ឧទាហរណ៍ កញ្ចក់ អាលុយមីញ៉ូម ប្លាស្ទិក សរីរាង្គ និង ក្រដាស) និង តម្រូវដោយច្បាប់ឱ្យប្រើឡើងវិញ (recycle) នូវសំណល់ពីគ្រួសារនីមួយៗ អាគារ រោងចក្រ ។ល។<br><br>- គិតគូរដល់ហានិភ័យនៃសំណល់រឹង និង បញ្ចុះបញ្ចូលក្រសួងអប់រំ យុវជន និង កីឡា ឱ្យរៀបចំកម្មវិធីសិក្សាអំពីការគ្រប់គ្រងសំណល់ សម្រាប់អប់រំសិស្សតាំងពីបឋមសិក្សារហូតដល់មធ្យមសិក្សាទាំងនៅតាមសាលារៀនរដ្ឋនិងទាំងនៅតាមសាលារៀនឯកជន។<br><br>- រៀបចំផែនការមេមួយសម្រាប់ទីកន្លែងចាក់សម្រាមសំណល់រឹង និង អនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឱ្យបានសមស្របសម្រាប់ទីកន្លែងនីមួយៗ។<br><br>- ការជម្រុញការយល់ដឹងអំពីការគ្រប់គ្រងសំណល់រឹង គប្បីត្រូវបានដាក់បញ្ចូលទៅក្នុងផែនការរបស់រាជរដ្ឋាភិបាល និង ផ្សព្វផ្សាយឱ្យបានទូលាយតាមរយៈមធ្យោបាយផ្សេងៗ ដូចជា ទូរទស្សន៍ វិទ្យុ និង សម្ភារផ្សព្វផ្សាយអប់រំ (IEC) ផ្សេងទៀត។ ក្រសួងបរិស្ថាន គប្បីនាំមុខគេធ្វើជាគម្រូដើម្បីការពារបរិស្ថាន ដូចជាការប្រើឡើងវិញ (recycling) នូវសំណល់នៅក្នុងការិយាល័យ។<br><br>- ក្រសួងបរិស្ថាន បានរៀបចំជារៀងរាល់ឆ្នាំនូវទិវាពិភពលោកនិងជាតិសម្រាប់ការសម្អាត។ គប្បីមានការលើកឡើង ប្រសិនបើក្រសួងបរិស្ថានមានធ្លាប់បានតាមដាន និង |

| | | |
|---|---|---|
| | | វាយតម្លៃថាតើអប្បកិរិយារបស់ប្រជាជនមានផ្លាស់ប្តូរឬទេក្រោយពេលធ្វើយុទ្ធនាការ ។<br>- ក្រសួងបរិស្ថាន រួមជាមួយក្រសួងរាជរដ្ឋាភិបាលពាក់ព័ន្ធផ្សេងទៀត គប្បីខិតខំទាក់ទាញការវិនិយោគផ្នែកឯកជនដើម្បីអភិវឌ្ឍគម្រោងផលិតអគ្គិសនីពីសំរាមនៅតាមតំបន់ចោលសំណល់ ដើម្បីជួយផលិតអគ្គិសនីទន្ទឹមគ្នានឹងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG) នៅក្នុងបរិយាកាស ។ |
| F៣៦ | ១២២ | - វាគឺជាប្រការល្អដែលក្រសួងមានស្ថានីយគ្រប់គ្រងគុណភាពខ្យល់ ហើយយើងខ្ញុំសូមស្នើសុំឱ្យក្រសួងបរិស្ថានដាក់បញ្ចូលទិន្នន័យអំពីគុណភាពខ្យល់ពីកន្លែងចំនួនបី និង ប្រាប់ពីរបៀបដែលសាធារណជនអាចរកបានរបាយការណ៍ស្តីពីគុណភាពខ្យល់ ។ ក្រសួងបរិស្ថានគប្បីប្រមូលទិន្នន័យឱ្យបានទៀងទាត់ពីទីកន្លែងនីមួយៗ ។<br>- ក្រសួងបរិស្ថាន គប្បីកសាងស្ថានីយគ្រប់គ្រងគុណភាពខ្យល់បន្ថែមទៀតដែលមានទីតាំងនៅតាមតំបន់ទីប្រជុំជននិងនៅជុំវិញតំបន់ឧស្សាហកម្ម ដើម្បីធានាឱ្យបានថាសកម្មភាពអភិវឌ្ឍន៍នានាមិនបានធ្វើឱ្យកខ្វក់បរិស្ថាន ។ |
| ៣៦ | ១២៣ | យើងខ្ញុំសូមស្នើសូមឱ្យផ្តល់ឈ្មោះក្រសួងទទួលបន្ទុកលើការឃ្លាំមើលគុណភាពទឹក និង សុំឱ្យមានការធ្វើការសិក្សាបែបវិទ្យាសាស្ត្រទៀងទាត់លើគុណភាពទឹកនៃទន្លេសំខាន់ៗនៃប្រទេសកម្ពុជា (ទន្លេ សពាះស្រែពក សេកុង សេសាន, ទន្លេមេគង្គ បឹងទន្លេសាប) ដែលសម្បូណ៌ធនធានធម្មជាតិអេកូឡូស៊ី ។ រាជរដ្ឋាភិបាល គប្បីធានាឱ្យបានផងដែរថាហេតុប៉ះពាល់លើគុណភាពទឹកត្រូវបានសម្រាល ជាបន្ទាន់ ហើយព័ត៌មានទាក់ទិននឹងគុណភាពទឹកត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ |
| ៣៦ | ១២៤ | ក្រសួងបរិស្ថាន គប្បីផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតអំពីផែនការមេសម្រាប់តំបន់ការពារទាំង ១៨ ។ |
| ២៦ | ១២៥ | ក្រសួងបរិស្ថាន គប្បីផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតអំពីចំនួននៃសហគមន៍ដែលកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ និង ចម្លើយតបអ្វីខ្លះរបស់រាជរដ្ឋាភិបាលចំពោះកំណើននេះ ។ |
| ៣៦ | ១២៦ | របាយការណ៍គប្បីមានជាភាសាខ្មែរ និង ផ្សព្វផ្សាយជូនសាធារណជនតាមរយៈគេហទំព័រ ឬតាមរយៈទម្រង់ផ្សេងទៀតនៃការផ្សព្វផ្សាយ ។<br>ក្រសួងបរិស្ថាន គប្បីផ្តល់ចំណេះដឹងនៃរបាយការណ៍និងការស្រាវជ្រាវនានាដែលក្រសួងបរិស្ថានបានធ្វើដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ។ |

| | | |
|---|---|---|
| | | ក្រសួងបរិស្ថាន គប្បីបំពេញតួនាទីដ៏សំខាន់មួយក្នុងការសម្របសម្រួលស្ថាប័នរាជរដ្ឋាភិបាល ផ្នែកឯកជន និង សង្គមស៊ីវិលដើម្បីសហការគ្នាលើការរៀបចំព្រឹត្តិការណ៍យល់ដឹងអំពីការប្រែប្រួលអាកាសធាតុពិភពលោក ដូចជា COPs ដើម្បីលើកឡើងនូវកង្វល់បន្ថែមទៀតជូនប្រទេសអភិវឌ្ឍ។ វាក៏គឺជាប្រការមានប្រយោជន៍ផងដែរដែលក្រសួងបរិស្ថានពិចារណាលើការអនុវត្តគម្រោងស្រាវជ្រាវរួមជាមួយសង្គមស៊ីវិលអំពីការប្រែប្រួលអាកាសធាតុ។ |
| ៣៦ | ១២៧ | យើងខ្ញុំសូមស្នើសុំឱ្យក្រសួងបរិស្ថានសរសេរព័ត៌មានលម្អិតបន្ថែមទៀតទាក់ទិននឹងប្រភេទបញ្ហាបរិស្ថានដែលត្រូវបានផ្សព្វផ្សាយជូនសាធារណជន រួមជាមួយព័ត៌មានអំពីរបៀបដែលក្រសួងបរិស្ថានផ្សព្វផ្សាយព័ត៌មាន និង សមិទ្ធផលធំៗដែលសម្រេចបាន។<br>ដោយសារមានព្រឹត្តិការណ៍ជាច្រើនដែលត្រូវបានរៀបចំដោយក្រសួងបរិស្ថានក្នុងគោលបំណងចែករំលែកការអប់រំនិងព័ត៌មាន តាមរយៈសិក្ខាសាលា និង វេទិកាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ ព្រឹត្តិការណ៍សំខាន់ៗដែលរៀបចំដោយក្រសួងបរិស្ថាន រួមជាមួយនឹងសមិទ្ធផលធំៗ គប្បីត្រូវបានលើកឡើង។ |
| ៣៦ | ១២៨ | បញ្ហាប្រឈមនានាក៏គប្បីដាក់បញ្ចូលការលើកឡើងអំពីរបៀបដែល រាជរដ្ឋាភិបាលគ្រោងដោះស្រាយបញ្ហា។<br>យើងខ្ញុំសូមស្នើសូមឱ្យដាក់ឈ្មោះក្រសួងដែលត្រូវរក្សាការឃ្លាំមើលនិងការពិភាក្សាជាប្រចាំជាមួយគណៈកម្មការទន្លេមេគង្គ និង ផលិតក្របខ័ណ្ឌនិយ័តកម្មទ្បេងទាត់ដើម្បីគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីរបស់ប្រទេសកម្ពុជា នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ |
| ៣៥-៣៦ | ១១៨-១២៨ | យើងខ្ញុំសូមស្នើសូមឱ្យក្រសួងបរិស្ថានបែងចែកសកម្មភាពនានាផ្អែកលើភារកិច្ច និង តាមនាយកដ្ឋាន ដើម្បីឱ្យមានភាពងាយស្រួលក្នុងការយល់ដឹងអំពីសកម្មភាពទាំងនេះ និងអនុញ្ញាតសាធារណជនស្គាល់នាយកដ្ឋានទទួលខុសត្រូវលើការអនុវត្តគម្រោង។ |
| ១២៥ | ៤២១ | អាទិភាពគោលនយោបាយដែលបានលើកឡើងខ្លះ ហាក់បីដូចជាត្រួតគ្នា ឧទាហរណ៍ចំណុច ii និង iii។<br>ចំពោះចំណុច i. ក្រសួងបរិស្ថានគប្បីលើកឡើងឱ្យបានច្បាស់លាស់អំពីរបៀបធានាឱ្យបាននូវការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិ និង ធានាឱ្យមានវិធានការសម្រាលផលប៉ះពាល់ ដែលអាចទទួលយកបានចំពោះបរិស្ថាននិងប្រជាជន ដើម្បីកុំឱ្យគម្រោងអភិវឌ្ឍន៍ធ្វើឱ្យខូចខាតដល់បរិស្ថាន ធនធានធម្មជាតិ និង ប្រជាជន។ |

| | | |
|---|---|---|
| ១២៦ | ៤២២ | យើងខ្ញុំសូមស្នើសូមឱ្យក្រសួងបរិស្ថានផ្ដល់នូវតារាងដែលគូសបង្ហាញព័ត៌មានជាក់លាក់អំពីប្រភេទច្បាប់នីមួយៗ រួមទាំងកាលបរិច្ឆេទដែលក្រសួងបរិស្ថាន រំពឹងថាទទួលបានការអនុម័តលើច្បាប់នោះ។ សេចក្ដីពន្យល់ខ្លីៗអំពីច្បាប់នីមួយៗនឹងធ្វើឱ្យអ្នកអាន មានភាពងាយស្រួលក្នុងការយល់។<br>ផែនការនីតិកម្មខ្លះមានលក្ខណៈមិនច្បាស់លាស់ និង ហាក់បីដូចជាត្រួតគ្នា ឧទាហរណ៍ ចំណុចទ ៩, ១០, និង ១៤។ សូមបញ្ជាក់ឱ្យបានច្បាស់នូវភាពខុសគ្នារវាងតំបន់ការពារ និង តំបន់ការពារធម្មជាតិ។ |
| ១២៦ | ៤២៣ | ដើម្បីធានាឱ្យបាននូវការប្រើប្រាស់ប្រកបដោយចីរភាពនូវការគ្រប់គ្រងធនធានធម្មជាតិ តាមរយៈការពិនិត្យមើលនិងយោបល់លើរបាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានជាមួយអន្តរក្រសួង និង ដើម្បីធានាឱ្យបានថាគម្រោងអភិវឌ្ឍន៍នឹងមិនត្រូវបានអនុវត្តដោយគ្មានរបាយការណ៍ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ការយល់ព្រមដោយក្រសួងបរិស្ថាន យើងខ្ញុំសូមស្នើសុំឱ្យក្រសួងបរិស្ថានពិចារណាអនុវត្តសកម្មភាពខាងក្រោមនៅក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិខាងមុខនេះ:<br>- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីប្រមូលទិន្នន័យអំពីគម្រោងអភិវឌ្ឍន៍នានា ដើម្បីកំណត់គម្រោងទាំងឡាយដែលចាំបាច់ត្រូវធ្វើរបាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន។<br>- ពិនិត្យមើលឡើងវិញនូវគម្រោងមានស្រាប់ ដែលបាននឹងកំពុងអនុវត្តដោយគ្មានរបាយការណ៍ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ផ្អាកគម្រោងទាំងនោះរហូតដល់ពេលដែលរបាយការណ៍ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានរៀបចំ និង អនុម័តរួច ដើម្បីធានាឱ្យបាននូវអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។<br>- ពិនិត្យមើលឡើងវិញ និង កែសម្រួលគោលការណ៍ណែនាំស្ដីពីរបាយការណ៍ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានការពិគ្រោះយោបល់ និង ការចូលរួមរបស់ភាគីពាក់ព័ន្ធនានា ដូចជាក្រសួងពាក់ព័ន្ធ និង អង្គការមិនមែនរដ្ឋាភិបាលស្របពេលជាមួយហ្នឹង<br>ព័ត៌មានផ្សេងៗដែលគួរគប្បីត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ ដូចជា គោលការណ៍វាយតម្លៃពីតម្លៃ និងប្រយោជន៍របស់គម្រោង នីតិវិធីលម្អិតនៃការចូលរួមសាធារណៈ និង ច្បាប់និងគោលនយោបាយនានាទាក់ទិន នឹងគោលការណ៍ណែនាំ ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ |

| | | |
|---|---|---|
| | | - បង្កើតឧបករណ៍តាមដានដើម្បីវាយតម្លៃអនុលោមភាព របស់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយគម្រោងអភិវឌ្ឍន៍។ គោលការណ៍តាមដាន គប្បីត្រូវបានចងក្រងជាឯកសារ និង មានលក្ខណៈងាយស្រួលយល់ និង ងាយរកបានសម្រាប់បុគ្គលិកទាំងអស់នៃក្រសួងបរិស្ថាននិងមន្ទីរបរិស្ថានខេត្ត។ ថ្លៃចំណាយនៃការតាមដាន និងបរិក្ខារចាំបាច់ទាំងអស់ ក៏គប្បីត្រូវបានដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងបរិស្ថាន (EMP) របស់គម្រោងផងដែរ។<br>- ពង្រឹងសមត្ថភាពបច្ចេកទេសរបស់បុគ្គលិកបច្ចេកទេសនៅថ្នាក់ជាតិ រាជធានី និង ខេត្ត លើគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង គោលការណ៍តាមដានលើការអនុវត្តរបាយការណ៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ |
| ១២៦ | ៤២៤ | យោបល់ទូទៅ: អត្ថបទជាភាសាអង់គ្លេសមិនដូចគ្នានឹងអត្ថបទជាភាសាខ្មែរ។ អត្ថបទជាភាសាអង់គ្លេសគប្បីត្រូវកែលម្អ។<br>ចំណុចទីមួយនិងទីបី មានលក្ខណៈត្រួតគ្នា និង មានន័យមិនច្បាស់លាស់។<br>ចំណុចទីប្រាំហាក់បីដូចជាមិនសូវសមស្របចំពោះផ្នែកនេះ ដោយសារវាផ្តោតជាសំខាន់លើការធ្វើឱ្យកខ្វក់ទឹក។ ចំណុចនេះគប្បីត្រូវបានលុបចេញ ឬ យកទៅដាក់នៅក្នុងផ្នែកណាផ្សេងទៀតនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។<br>ជារួម ក្រសួងបរិស្ថាន គប្បីបង្ហាញឱ្យបានច្បាស់នូវមធ្យោបាយឬយុទ្ធសាស្ត្រនានា ដើម្បីធានាឱ្យបានថាប្រព័ន្ធអេកូឡូស៊ី ទឹក និង បរិស្ថានមិនត្រូវបានគេធ្វើឱ្យកខ្វក់ និង ត្រូវបានគេថែរក្សា។ សូចនាករនិងឧបករណ៍តាមដានច្បាស់លាស់ នឹងជួយឱ្យក្រសួងបរិស្ថានវាយតម្លៃបាន ដោយងាយស្រួល លើសមិទ្ធិផលនានាដែលសម្រេចបាន។<br>ចំណុចនានាដែលស្នើសុំអោយពិចារណាដោយក្រសួងបរិស្ថាន រួមមាន:<br>• លើកកម្ពស់ស្តង់ដារតាមដាន ទៅលើស្តង់ដារគុណភាពទឹកសំណល់ចេញពីឧស្សាហកម្ម និង មជ្ឈមណ្ឌលអាជីវកម្មផ្សេងទៀត។<br>• រិះរកបច្ចេកវិទ្យាសមស្រប ឬ ការគ្រប់គ្រងល្អនៃការប្រើទឹកសំណល់ឡើងវិញ សម្រាប់គោលបំណងនានា ដូចជា ការស្រោចទឹកសួនច្បារសាធារណៈ សម្រាប់កសិកម្មនៅតំបន់ទីក្រុងនិងតំបន់ជុំវិញទីក្រុង ។ល។<br>• ធានាឱ្យបានថាប្រភពទឹកដែលត្រូវបានប្រើសម្រាប់ការប្រើប្រាស់ក្នុងមូលដ្ឋាន មិនត្រូវបានគេធ្វើឱ្យកខ្វក់។ |

| | | |
|---|---|---|
| ១២៦ | ៤២៥ | ក្រសួងបរិស្ថានគប្បីសរសេរឱ្យបានកាន់តែលម្អិតលើចំណុចនីមួយៗអំពីរបៀបដែលក្រសួងគ្រោងសម្រេចបានចំណុចនីមួយៗ។ ឧទាហរណ៍:<br>• ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ: កាត់បន្ថយហេតុប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយធានាឱ្យបាននូវធនធានគ្រប់គ្រាន់សម្រាប់អនុវត្តកម្មវិធីសកម្មភាពជាតិសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) ដោយមានការជួយគាំទ្រពីក្រសួងផ្សេងទៀត អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និង ដៃគូអភិវឌ្ឍន៍។ យ៉ាងហោចណាស់ គម្រោងចំនួន ២០ នៃ NAPA នឹងត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០១០ (ឬ ២០១១)។ (*សូមកត់សម្គាល់ តួលេខនេះគ្រាន់តែគឺជាឧទាហរណ៍មួយប៉ុណ្ណោះ*)។<br>យើងខ្ញុំសូមស្នើសូមឱ្យក្រសួងបរិស្ថានបកស្រាយបំភ្លឺអំពីការងាររបស់ខ្លួនលើកម្មវិធីជាតិ "បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ" ឬ កម្មវិធីសកម្មភាពជាតិសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA)។ យើងខ្ញុំសូមផ្តល់អនុសាសន៍ សូមឱ្យក្រសួងបរិស្ថានរួមជាមួយក្រសួងនានា របស់រាជរដ្ឋាភិបាលផ្សេងទៀត ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិល តាមដាន វឌ្ឍនភាពនៃការអនុវត្តកម្មវិធីសកម្មភាពជាតិ សម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) និង វាយតម្លៃសមិទ្ធិផលនៃ NAPA ដោយប្រើអភិក្រមបែបចូលរួម។<br>ដោយសារ NAPA កម្ពុជាគឺស្របគ្នាជាមួយនឹងគោលបំណងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ដូចមានចែងនៅក្នុង "យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព" គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ NAPA គប្បីត្រូវបានកែសម្រួលផ្អែកលើលទ្ធផលវាយតម្លៃ និង អនុសាសន៍នានាពីកិច្ចដំណើរការពិគ្រោះយោបល់សាធារណៈ និង ត្រូវបានធ្វើបច្ចុប្បន្នកម្មនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៩-២០១៣ ដែលដើរតាមអាណត្តិទីបួនរបស់រាជរដ្ឋាភិបាល។<br>យើងខ្ញុំសូមស្នើសូមឱ្យក្រសួងបរិស្ថានពិចារណាដាក់បន្ថែមចំណុចខាងក្រោម:<br>• ជម្រុញការបញ្ជ្រាបយេនឌ័រនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ<br>• វាយតម្លៃជារៀងរាល់ឆ្នាំលើប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារនៅកម្ពុជា<br>• បន្តវាយតម្លៃធនធាន/ជង្រុកជីវសាស្ត្រនៅក្នុងតំបន់ការពារ<br>• ព្រាងគោលការណ៍ឬផែនការមេបែបចូលរួមសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព |

| | | |
|---|---|---|
| | | នៅក្នុងតំបន់ការពារ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា<br>• ដាក់ឡើងវិញនូវសំណើសុំចុះបញ្ជីជួរភ្នំក្រវាញជាទីកន្លែងបេតិកភណ្ឌពិភពលោកជាថ្មី |
| ១២៧ | ៤២៦ | ការយល់ដឹងជាសាធារណៈ គឺជាផ្នែកដ៏សំខាន់មួយនៃតួនាទីរបស់ក្រសួងបរិស្ថាន ប៉ុន្តែប្រសិនបើក្រសួងបរិស្ថានអាចលើកទឹកចិត្តឱ្យក្រសួងអប់រំ យុវជន និង កីឡា និង អង្គការមិនមែនរដ្ឋាភិបាល ជួយជម្រុញការយល់ដឹងជាសាធារណៈអំពីបញ្ហាបរិស្ថាន វានឹងគឺជាវិធីដ៏មានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិបំផុតដើម្បីថែរក្សានិងការពារធនធានធម្មជាតិ និង បរិស្ថានរបស់ប្រទេសកម្ពុជាសម្រាប់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និង ការកាត់បន្ថយភាពក្រីក្រ ។<br>យើងខ្ញុំសូមស្នើសូមឱ្យផ្តល់ផែនការជម្រុញការយល់ដឹងមួយដែលរួមមានព័ត៌មានរបស់នាយកដ្ឋានទទួលបន្ទុកនីមួយៗ និង ព័ត៌មានលម្អិតអំពីរបៀបដែលក្រសួងបរិស្ថាននឹងសម្រេចសកម្មភាពនីមួយៗ។ នឹងគួរតប្បីលើកឡើងផងដែរអំពីនាយកដ្ឋាន នៅក្នុងក្រសួងបរិស្ថានដែលទទួលបន្ទុកលើការសម្របសម្រួលការងារអប់រំខាងបរិស្ថាន និង ថាតើផែនការតាមដាននិងវាយតម្លៃមួយ ត្រូវបានរៀបចំសម្រាប់គម្រោងឬទេ ។ |
| ១២៧ | ៤២៧ | • គណៈកម្មាធិការជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NCCC) គប្បីពិនិត្យមើល NAPA ឡើងវិញ និង បញ្ជាក់សុពលភាពនៃអាទិភាពគម្រោង។ លើសពីនេះទៀត គេគប្បីមានការពាក់ព័ន្ធផ្ទាល់ជាមួយផ្នែកឯកជន ក្រសួងពាក់ព័ន្ធ និង សង្គមស៊ីវិល ដើម្បីពិនិត្យមើលឡើងវិញនិងកែសម្រួល NAPA តាមការចាំបាច់ ដើម្បីធានាឱ្យបានថា NAPA ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ឱ្យបានប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា និង ធានាឱ្យបានថាវាមានប្រយោជន៍ចំពោះប្រជាជនងាយរងគ្រោះបំផុត ។<br>• NCCC គប្បីបន្តស្វែងរកការជួយឧបត្ថម្ភពីម្ចាស់ជំនួយដែលមានចំណាប់អារម្មណ៍សម្រាប់ការអនុវត្ត NAPA<br>• NCCC គប្បីជម្រុញនិងលើកទឹកចិត្តដល់គំនិតផ្តួចផ្តើមនានាស្តីពីការប្រែប្រួលអាកាសធាតុ ដូចជាការសម្រាលផលប៉ះពាល់ ការបន្សាំ ។ល។និង ។ល។<br>• NCCC គប្បីបន្តសហការជាមួយដៃគូនិងភាគីពាក់ព័ន្ធនានា ដើម្បីរៀបចំរួមគ្នា និង សម្របសម្រួលវេទិកាជាតិប្រចាំឆ្នាំស្តីពីការប្រែប្រួលអាកាសធាតុ ។<br>• NCCC គប្បីចូលរួមក្នុងរបៀបវារៈតំបន់និងពិភពលោកស្តីពីការប្រែប្រួលអាកាសធាតុ ។ |

| | | |
|---|---|---|
| | | • ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ គប្បីត្រូវបានធ្វើលើគ្រប់គម្រោងទាំងអស់របស់ក្រសួងបរិស្ថាន ។<br>• ការជម្រុញការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ គប្បីត្រូវបានធ្វើ និង សំដៅលើសាធារណជន និង ក្រសួងនានារបស់រាជរដ្ឋាភិបាល ។<br>• NCCC គប្បីបន្តតាមដានផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈការធ្វើអង្កេតនិងការស្រាវជ្រាវ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ផ្នែកឯកជន គ្រឹះស្ថានសិក្សា និង សង្គមស៊ីវិល ។<br>• ផែនការនានារបស់ក្រសួងបរិស្ថាន និង ទស្សនាទានអំពីការប្រែប្រួលអាកាសធាតុ គប្បីត្រូវបានអនុវត្តលើគ្រប់គម្រោងទាំងអស់ ដើម្បីជួយឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ របៀបដែលសំណល់គ្មានការគ្រប់គ្រង រួមចំណែកដល់កំណើននៃឧស្ម័នផ្ទះកញ្ចក់ (GHS) និង របៀបសម្រាលផលប៉ះពាល់ GHG តាមរយៈផែនការនៃការគ្រប់គ្រងសំណល់រឹង។ ក្រសួងបរិស្ថានក៏អាចចាប់ផ្តើមរិះរកវិធីនានាផងដែរ ដើម្បីសម្រាលផលប៉ះពាល់ GHG តាមរយៈ របាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងលើកទឹកចិត្តដល់ការអនុវត្តប្រកបដោយនិរន្តរភាព នូវគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM) ។ គម្រោង CDM ទាំងអស់គប្បីតម្រូវឱ្យានការយល់ព្រម របស់សហគមន៍ ។<br>• ថវិកាប៉ាន់ស្មានសម្រាប់ការអនុវត្តគម្រោង និង សូចនាកររបស់វា គប្បីត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ |
| | | សំណើទូទៅដែលគប្បីត្រូវបានពិចារណានៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រួមមានៈ<br>• ប្រតិបត្តិយុទ្ធសាស្ត្រចតុកោណដោយផ្តោតលើគណនេយ្យភាព តម្លាភាព និង ការទទួលខុសត្រូវសង្គមនៅក្នុងការគប់គ្រងធនធានធម្មជាតិ ។<br>• ពង្រឹងការអនុវត្តការវាយតម្លៃផលប៉ះពាល់សង្គមនិងបរិស្ថាន មុនពេលអភិវឌ្ឍន៍គម្រោង ទន្ទឹមគ្នានឹងការកែលម្អគុណភាពនៃរបាយការណ៍អនាគតផងដែរ ។<br>• ជម្រុញឱ្យក្រុមហ៊ុនទាំងអស់ ប្រកាន់ភ្ជាប់នូវភាពចាំបាច់ នឹងមានតម្លៃរបស់ការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈប្រកប នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។<br>• បញ្ជ្រាបបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងផែនការរបស់ក្រសួងបរិស្ថាន និង |

| | | |
|---|---|---|
| | | ជំរុញអោយមានសកម្មភាពបង្កើនការយល់ដឹងជូនសាធារណជន ដើម្បីធានាឱ្យបានថាប្រជាជនក្រីក្រនិង អ្នកងាយរងគ្រោះ នឹងមិនជួបទុកវេទនាដែលបណ្តាលមកពីហេតុប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។<br>• បញ្ជ្រាប ការប្រែប្រួលអាកាសធាតុទៅក្នុងការធ្វើផែនការរបស់ក្រសួងនានា។<br>• ផ្តល់ឱកាសឱ្យអង្គការមិនមែនរដ្ឋាភិបាលនិងសហគមន៍បានសហការក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។<br>• សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល/អង្គការអន្តរជាតិ ដើម្បីផ្តល់ការបណ្តុះបណ្តាលជូនសហគមន៍ដើម្បីធ្វើឱ្យពួកគេអាចបន្សាំខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ |

* លេខទំព័រសំដៅលើលេខទំព័រដែលមានប្រើនៅក្នុងផយអជបច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី១**ផយអជ**បច្ចុប្បន្នកម ២០០៩-២០១៣

**ព័ត៌មានសម្រាប់ទំនាក់ទំនង:**


វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

លោកស្រី សេង សូទីរ៉ា មន្ត្រីគម្រោងបញ្ហាបរិស្ថាន

ទូរស័ព្ទ: (៨៥៥-១៦) ៣២ ៥១ ៩៩ / ១៧ ៦៧ ៩៨ ៨៧

ទូរសារ: (៨៥៥-២៣) ២៣ ៩៩៤ ០៦៣

អ៊ីម៉ែល: sothira@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh

## ប្រសិទ្ធិភាពជំនួយ

| ទំព័រ* | យោបល់ |
| --- | --- |
| ៣៧៣ | *"រាជរដ្ឋាភិបាលប្តេជ្ញាអនុវត្ត **"របៀបវារៈក្រុងអាក្រាដើម្បីសកម្មភាព"** ដែលតំណាងឱ្យការព្រមព្រៀងគ្នា នៅក្នុងវេទិកាជាន់ខ្ពស់ស្តីពីការកែលម្អប្រសិទ្ធភាពជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ដើម្បីពង្រឹងភាពជាម្ចាស់និងភាពជាអ្នកដឹកនាំជាតិ ភាពជាដៃគូរ និងតម្លាភាពជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ក៏ដូចជាការគ្រប់គ្រងផ្អែកលើលទ្ធផល (...)"*<br>**សំណើៈ**<br>• រាជរដ្ឋាភិបាលគប្បីបង្ហាញការប្តេជ្ញារបស់ខ្លួននិងសមិទ្ធិផលដែលសម្រេចបាន ដើម្បីអនុញ្ញាតឱ្យរដ្ឋសភានិងប្រជាពលរដ្ឋអាចចូលរួមក្នុងកិច្ចដំណើរការតាមដានលើយន្តការ/កម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ និង គណនេយ្យភាពរបស់រាជរដ្ឋាភិបាលលើលទ្ធផលអភិវឌ្ឍន៍។<br>• សូមបន្ថែមនៅក្នុងវង់ក្រចក (...)៖ និង គណនេយ្យភាពរបស់រាជរដ្ឋាភិបាលលើលទ្ធផលអភិវឌ្ឍន៍ចំពោះរដ្ឋសភានិងប្រជាពលរដ្ឋ។ |
| ៣៧៨ | *"គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍(GDCC) និង យន្តការក្រុមការងារ បច្ចេកទេស (TWG) នឹងបន្តផ្តល់មធ្យោបាយចម្បងលើការជជែកពិភាក្សារវាងរាជរដ្ឋាភិបាល និង ដៃគូ អភិវឌ្ឍន៍។ ស្នាដៃការងារនិងរចនាសម្ព័ន្ធនៃក្រុមការងារទាំងនេះ នឹងត្រូវបានតាមដាន និងពិនិត្យវាយតម្លៃ ដើម្បីធានាឱ្យបានភាពជាដៃគូរវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ ផ្អែកលើភាពជាម្ចាស់ និងគណនេយ្យភាពរបស់រាជរដ្ឋាភិបាលលើលទ្ធផលអភិវឌ្ឍន៍ "។*<br>**យោបល់**<br>• គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល*និង*ដៃគូអភិវឌ្ឍន៍ (GDCC) និង យន្តការក្រុមការងារបច្ចេកទេស នឹងបន្តផ្តល់វេទិកាសម្រាប់ការជជែកពិភាក្សាគោលនយោបាយរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល។ ស្នាដៃការងារនិងរចនាសម្ព័ន្ធនៃយន្តការទាំងនេះ នឹងត្រូវបានតាមដាននិងពិនិត្យវាយតម្លៃដើម្បីធានាឱ្យបានភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល គឺផ្អែកលើភាពជាម្ចាស់របស់ប្រទេស និង គណនេយ្យភាពលើលទ្ធផលអភិវឌ្ឍន៍។ |
| ៣៨១ | *"ភាពជាដៃគូគឺមានអត្ថន័យនៅពេលដែលក្រុមការងារបច្ចេកទេសមិនគ្រាន់តែគឺជាវេទិកាសម្រាប់ការពិភាក្សាអំពីបញ្ហានានាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាវិធានការសម្រាប់ដោះស្រាយបញ្ហាទាំងឡាយដោយមានការឯកភាព និងការតាមដានរួមរវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ (...)។ យន្តការក្រុមការងារបច្ចេកទេសនឹងត្រូវបានពង្រឹងដើម្បីជួយគាំទ្រដល់ការតាមដានលើការអនុវត្តសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍នានានៅក្នុងវិស័យឬ ផ្អែកដែលពួកគេគាំទ្រ"* |

| | |
|---|---|
| | សំណើសុំឱ្យបន្ថែមនៅក្នុង (...)៖<br>ដោយមានការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងក្រុមការងារបច្ចេកទេសទាំង ១៩ |
| **៣៨២** | *"ប្រព័ន្ធទិន្នន័យ ODA កម្ពុជា គឺជាកម្មវិធីព័ត៌មានរបស់រាជរដ្ឋាភិបាលស្តីពីសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍ដែលបានរៀបចំដល់ការគាំទ្រការធ្វើផែនការនិងការរៀបចំថវិកាទាក់ទិននឹង ការងារ ..."*<br>**សំណើសុំឱ្យសរសេរឡើងវិញថា៖**<br>• ប្រព័ន្ធទិន្នន័យ ODA កម្ពុជា នឹងផ្តល់ព័ត៌មានបច្ចុប្បន្នភាពទាន់ពេលវេលា ត្រឹមត្រូវ និង គ្រប់គ្រាន់ស្តីពីគម្រោងផ្តល់ហិរញ្ញប្បទានជំនួយ តាមរយៈការផ្សារភ្ជាប់ដែលមានលក្ខណៈជាប្រព័ន្ធ និង សមស្របតាមតម្រូវការ ជាមួយនឹងផែនការវិនិយោគជា អាទិភាព (PIP) សម្រាប់ការធ្វើផែនការនិងការរៀបចំថវិកា |
| **៣៨៦** | *"រាជរដ្ឋាភិបាលវាយតម្លៃខ្ពស់ការចូលរួមដ៏សកម្មនៅក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ជាតិរបស់អង្គការសង្គមស៊ីវិលដែលមានឆន្ទៈដ៏ពិតប្រាកដក្នុងការរួមវិភាគទានទាំងធនធានហិរញ្ញវត្ថុនិងធនធានសហប្រតិបត្តិការ ។ រាជរដ្ឋាភិបាលចាត់ទុកថាធនធាននិងជំនាញឯកទេសដែលបាននាំមកដោយអង្គការសង្គមស៊ីវិលគឺជាធាតុចូលដ៏សំខាន់មួយនៅក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ ដើម្បីសម្រេចបាននូវលទ្ធផលអភិវឌ្ឍន៍ដែលចង់បាន ។ រាជរដ្ឋាភិបាលនឹងបន្តធានាការចូលរួមដ៏ខ្លាំងក្លារបស់អង្គការសង្គមស៊ីវិលនៅក្នុងយន្តការពិភាក្សានានា (...)"* ។<br>សំណើ៖<br>• បន្ថែមនៅក្នុងវង់ក្រចក (...)៖ តាមរយៈការទទួលស្គាល់អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលជាភាគីពាក់ព័ន្ធស្របច្បាប់ ការជូនព័ត៌មានអំពីកាលបរិច្ឆេទនៃវេទិកាគោលនយោបាយទាន់ពេល ព័ត៌មានពាក់ព័ន្ធមានជាសាធារណៈ និង ទៀងទាត់អំពីថវិកាជាតិ និង លទ្ធផលអភិវឌ្ឍន៍រយៈពេលសមស្របសម្រាប់ផ្ញើធាតុចូល/យោបល់លើផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ។ |

**ព័ត៌មានសម្រាប់ទំនាក់ទំនង៖**


វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

លោក ជា គឹមសុង ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍

ទូរស័ព្ទ៖ (៨៥៥)-២៣ ២១៤ ៤២៩

ទូរសារ៖ (៨៥៥-២៣) ២៣ ៩៩៤ ០៦៣

អ៊ីម៉ែល៖ kimsong@ngoforum.org.kh

គេហទំព័រ៖ www.ngoforum.org.kh

## ការដាក់បញ្ចូលពិការភាព

## ១. សេចក្តីផ្តើម

អង្គការជនពិការកម្ពុជា (CDPO) ក្រុមប្រឹក្សាសកម្មភាពពិការ (DAC) និងអង្គការជនពិការអន្តរជាតិ (HIF) ជំនួសមុខឱ្យគណៈកម្មាធិការសមាហរណកម្មផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ ជាតិ (IC) និងវិស័យពិការភាព សូមបញ្ជាក់ជាការពិតថារាជរដ្ឋាភិបាលកម្ពុជា(RGC) បានខិតខំយ៉ាងខ្លាំងក្លាក្នុងកិច្ចការងារដើម្បីធានាឱ្យ**គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា** សម្រេចទៅបានស្របតាមសន្និសិទ **ណែរូប៊ី** ស្តីពីជំនួយជនរងគ្រោះអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (UNCRPD) ច្បាប់កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ (PPRPD) និង ផែនការសកម្មភាពជាតិ (NPA) ដែលទើបទទួលបានការអនុម័តយល់ព្រមពី រាជរដ្ឋាភិបាលកម្ពុជា (RGC) នាពេលថ្មីៗនេះ។

ដើម្បីធានាថាជនពិការទទួលផលប្រយោជន៍ និងចូលរួមចំណែកនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ កម្មវិធីអភិវឌ្ឍន៍ទាំងអស់ត្រូវលុបបំបាត់ស្ថានភាពក្រីក្រឱ្យរឹតតែប្រសើ ជាងមុនតាមរយៈការដាក់បញ្ចូលឱ្យបានច្បាស់លាស់នូវបញ្ហាពិការភាពទៅក្នុងយុទ្ធសាស្ត្រ និងការត្រួតពិនិត្យ និងការដាក់សេចក្តីយោង និងសូចនាករពិការភាពដែលជាបញ្ហាអន្តរវិស័យទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៩-២០១៣) និងផែនការ/គោលនយោបាយតាមវិស័យផ្សេងៗទៀត និងកម្មវិធីអភិវឌ្ឍន៍ទាំងអស់។

| លេខទំព័រ* | លេខកថាខ័ណ្ឌ** | អត្ថបទដើមដកស្រង់ពីសេចក្តីព្រាងលើកទីមួយ **ផយអជ**បច្ចុប្បន្នកម្ម២០០៩-២០១៣ | យោបល់អង្គការមិនមែនរដ្ឋាភិបាល ឬការស្នើឱ្យមានការកែប្រែ |
| --- | --- | --- | --- |
| ៣០ | ៥៣ | គោលដៅអភិវឌ្ឍន៍រយៈពេលវែងនៃ យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាល គឺការអភិវឌ្ឍ យ៉ាង ទូលំទូលាយ និងប្រកបដោយ ចីរភាព ការពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់ខឿន សេដ្ឋកិច្ចប្រកបដោយភាពស្វាហាប់ នៅមូលដ្ឋាន ដែលប្រជាពលរដ្ឋគ្រប់រូប មានកាលានុវត្តភាព ស្មើៗគ្នា ក្នុងការ ចូលរួមកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ការគ្រប់គ្រង បរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយ ប្រសិទ្ធភាព និងការផ្តល់សេវា សាធារណៈ ប្រកបដោយគុណភាព ដើម្បីឆ្លើយតបនឹង តម្រូវការរបស់ ប្រជាពលរដ្ឋ និងការចូល រួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ **ដោយផ្តោតជាសំខាន់ ទៅលើក្រុមជន ងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិច ស្ត្រី និងកុមារ** ។ រាជរដ្ឋាភិបាលជឿជាក់ថា ការបង្កើត និងការលើកកម្ពស់ការ អភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ នឹងអាច សម្រេចបានយ៉ាងប្រសើរនូវការ ពង្រឹង អភិបាលកិច្ច តាមបែប ប្រជាធិបតេយ្យ នៅកម្ពុជា ។ កំណែទម្រង់ប្រព័ន្ធគ្រប់គ្រង នៅថ្នាក់ រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ មាន គោលដៅជា យុទ្ធសាស្ត្រពីរ យ៉ាងគឺ (១) ការពង្រឹង | គោលដៅអភិវឌ្ឍន៍រយៈពេលវែងនៃ យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈ ការរបស់រាជរដ្ឋាភិបាល គឺការអភិវឌ្ឍយ៉ាងទូលំទូលាយ និងប្រកបដោយ ចីរភាព ការពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់ខឿន សេដ្ឋកិច្ចប្រកបដោយភាពស្វាហាប់នៅមូលដ្ឋាន ដែលប្រជាពលរដ្ឋគ្រប់រូប មានកាលានុវត្តភាព ស្មើៗគ្នា ក្នុងការចូលរួម កិច្ចអភិវឌ្ឍន៍មូលដ្ឋាន ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ប្រកប ដោយប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ ប្រជាពលរដ្ឋ និងការចូលរួមកាត់បន្ថយ ភាពក្រីក្ររបស់ប្រជាពលរដ្ឋ**ដោយផ្តោត ជាសំខាន់ ទៅលើក្រុមជនងាយរងគ្រោះ ក្រុមជនជាតិ ដើម ភាគតិច ជនពិការ ស្ត្រី និង កុមារ** ។ រាជរដ្ឋាភិបាលជឿជាក់ថា ការបង្កើត និងការលើក កម្ពស់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ នឹងអាចសម្រេចបានយ៉ាងប្រសើរនូវការពង្រឹង អភិបាលកិច្ច តាមបែបប្រជាធិបតេយ្យនៅកម្ពុជា ។ កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ មាន គោលដៅជាយុទ្ធសាស្ត្រពីរយ៉ាងគឺ (១) ការពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន (២) ការជំរុញកិច្ច អភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយ ភាពក្រីក្រ ។ |

| | | | |
|---|---|---|---|
| | | និងពង្រីក លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន (២) ការជំរុញកិច្ច អភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ ។ | |
| ៦៩/៧០ | ១៤៣<br>១៤៤<br>១៤៥ | **ផ្លូវដែក កំពង់ផែ**<br>**សេវាកម្មអាកាសចរណ៍ស៊ីវិល** | ស្នើសុំឱ្យមានការគិតគូរដល់ការបង្កនូវលក្ខណៈងាយស្រួលដល់ជនពិការនៅពេលធ្វើការ សាងសង់ហេដ្ឋារចនាសម្ព័ន្ធទាំងបីនេះ ។ |
| ៩៣ | ១៩៣ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានផ្តល់នូវសេវាកម្ម សង្គម ទៅដល់ជនគ្មានទីជម្រកនិងជនអានាថា និងផ្តល់នូវកម្មវិធីជំនួយសង្គ្រោះ បន្ទាន់ ទៅដល់ប្រជាជន ដែលបានទទួលផលប៉ះពាល់ពីគ្រោះធម្មជាតិ ជនរងគ្រោះ ដោយសារការជួញដូរផ្លូវភេទ អំពើជួញដូរមនុស្សឆ្លងដែន ការការពារ សិទ្ធិជាមូលដ្ឋានទាំង ០៤ របស់កុមារ **ការលើកដម្កើងតម្លៃគ្រួសារ ការថែទាំ ចំពោះទារកកំព្រា កុមារពិការ និងកុមារផ្ទុកមេរោគហ៊ីវ/អេដស៍** ។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានផ្តល់នូវសេវាកម្មសង្គម ទៅដល់ជនគ្មានទីជម្រកនិងជនអានាថា និងផ្តល់នូវកម្មវិធីជំនួយសង្គ្រោះបន្ទាន់ ទៅដល់ ប្រជាជនដែលបានទទួលផលប៉ះពាល់ពីគ្រោះធម្មជាតិ ជនរងគ្រោះ ដោយសារ ការជួញដូរផ្លូវភេទ អំពើជួញដូរមនុស្សឆ្លងដែន ការការពារសិទ្ធិជាមូលដ្ឋានទាំង ០៤ របស់កុមារ **លើកកម្ពស់និងការងារសិទ្ធិជនពិការ ការលើកដម្កើងតម្លៃគ្រួសារ ការថែទាំចំពោះទារកកំព្រា កុមារពិការ និងកុមារផ្ទុកមេរោគហ៊ីវ/អេដស៍** ។ |
| ៩៥ | ២០២ | គោលនយោបាយជាអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦ - ២០១០ បានផ្តោតជាសំខាន់លើ ទី១ ការធានាសមធម៌នៃការចូលរៀន ទី២ ការកែលម្អគុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ និង ទី៣ ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាព ដើម្បីអនុវត្តវិមជ្ឈការ ។ វឌ្ឍនភាពសំខាន់ៗនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ បានបង្ហាញឱ្យឃើញ | គោលនយោបាយជាអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ បានផ្តោតជាសំខាន់លើកទី១ ការធានាសមធម៌នៃការចូលរៀន ទី២ ការកែលម្អគុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ និង ទី៣ ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាព ដើម្បីអនុវត្តវិមជ្ឈការ ។ វឌ្ឍនភាពសំខាន់ៗនៃ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ បានបង្ហាញឱ្យ ឃើញជាក់ស្តែងតាមរយៈ ការធានាកុមារអាយុ ៦ឆ្នាំ បានចូលរៀននៅ សាលាបឋម |

| | | | |
|---|---|---|---|
| | | ជាក់ស្តែងតាមរយៈ ការធានាកុមារអាយុ ៦ឆ្នាំ បានចូលរៀននៅ សាលា បឋមសិក្សា និងការកាត់បន្ថយឧបសគ្គចំណាយរបស់មាតាបិតាសិស្ស នៅគ្រប់ សាលារៀន និងគ្រប់កម្រិតទូទាំងប្រទេស។ ការអនុវត្តកម្មវិធីសាលាកុមារមេត្រី ការអភិវឌ្ឍកម្មវិធីសិក្សា និងការវាយតម្លៃស្តង់ដារនៃការសិក្សាបានរួមចំណែកយ៉ាងច្រើនក្នុងការ លើកកម្ពស់គុណភាព និង ប្រសិទ្ធភាព នៃសេវាអប់រំជាក់ស្តែង គឺមានការកើនឡើងនៃចំនួនសាលាបឋមសិក្សា និង សាលាមធ្យមសិក្សាបឋមភូមិ ការកើនឡើងនៃចំនួនសិស្សនៅសាលាមធ្យម សិក្សា និងកំណើនអត្រាអក្ខរជន (អាយុ ១៥-២៤) ជាដើម ។ ទោះជាដូច នេះក្តី ក៏នៅមានគម្លាតមួយចំនួនដែលតម្រូវឱ្យ មានកិច្ចខិតខំប្រឹងប្រែងបន្ថែម ទៀត ក្នុងការអនុវត្តយុទ្ធសាស្ត្រនានាឱ្យបានជោគជ័យ ជាពិសេស ការអប់រំ កុមារតូច ការកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា ការអភិវឌ្ឍសម្ភារ រូបវ័ន្ត និងការអប់រំនៅឧត្តមសិក្សា **សម្រាប់សិស្ស-និស្សិតមក ពីគ្រួសារ ក្រីក្រ និងតំបន់ដាច់ស្រយាល**។ តារាងទី៣ បង្ហាញពីទិន្នន័យ ច្ចុប្បន្នភាព ក្នុងវិស័យ អប់រំ ។ | សិក្សា និងការកាត់បន្ថយឧបសគ្គចំណាយរបស់ មាតាបិតាសិស្ស នៅគ្រប់សាលារៀន និងគ្រប់កម្រិតទូទាំងប្រទេស។ ការអនុវត្តកម្មវិធីសាលា កុមារមេត្រី ការអភិវឌ្ឍកម្មវិធីសិក្សា និងការវាយតម្លៃស្តង់ដារនៃការសិក្សា បានរួមចំណែកយ៉ាងច្រើន ក្នុងការលើកកម្ពស់គុណភាព និង ប្រសិទ្ធភាព នៃសេវាអប់រំជាក់ស្តែងគឺមានការកើនឡើងនៃចំនួនសាលាបឋមសិក្សា និង សាលាមធ្យមសិក្សាបឋមភូមិ ការកើនឡើងនៃចំនួនសិស្សនៅសាលាមធ្យម សិក្សា និងកំណើនអត្រាអក្ខរជន (អាយុ ១៥-២៤) ជាដើម ។ ទោះជាដូចនេះក្តី ក៏នៅមានគម្លាតមួយចំនួនដែលតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការអនុវត្តយុទ្ធសាស្ត្រនានាឱ្យបានជោគជ័យជាពិសេស ការអប់រំកុមារតូច ការកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា ការអភិវឌ្ឍសម្ភារ រូបវ័ន្ត និងការអប់រំនៅឧត្តមសិក្សា**សម្រាប់សិស្ស-និស្សិតមកពីគ្រួសារ ក្រីក្រ សិស្ស-និស្សិតពិការ និងតំបន់ដាច់ស្រយាល**។ តារាងទី៣ បង្ហាញពីទិន្នន័យច្ចុប្បន្នភាព ក្នុងវិស័យអប់រំ ។ |
| ២៣៤ | ៤៦៨ | ដើម្បីអនុវត្តគោលនយោបាយអាទិភាព របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួង ព័ត៌មាន | ដើម្បីអនុវត្តគោលនយោបាយអាទិភាព របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួង ព័ត៌មាននឹងអនុវត្ត |

| | | | |
|---|---|---|---|
| | | នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :<br>• ពង្រីកវិសាលភាព និងលើកកម្ពស់ **គុណភាព និងប្រសិទ្ធ ភាពនៃបណ្តាញផ្សព្វផ្សាយជាតិ ដើម្បីផ្តល់សេវាកម្មឱ្យបាន ដល់ ៩៥ភាគរយនៃប្រជាជន ទូទាំងប្រទេស** ដល់ក្នុងតំបន់ និងទ្វិបផ្សេងទៀត រួមទាំងអាមេរិកខាងជើង។ បន្តសាងសង់ស្ថានីយវិទ្យុ និងទូរទស្សន៍ នៅតាមខេត្ត និងលើកកម្ពស់សមត្ថភាព ដើម្បីមានលទ្ធ-ភាពអាចបន្តផ្ទាល់នូវព្រឹត្តការណ៍សំខាន់ៗ នៅកម្រិតជាតិ និងមានលទ្ធភាពផលិតនូវកម្មវិធីផ្សព្វផ្សាយទៅដល់តំបន់នានា បន្ថែមទៀត ជាពិសេស បញ្ហាទាក់ទងនឹងស្ត្រីនិងកុមារ ។<br>• កសាងស្ថាប័ន និងសមត្ថភាពធនធានមនុស្ស ដោយផ្តោតលើការបង្កើនចំនួនមន្ត្រីស្ត្រី ការធ្វើឱ្យប្រសើរឡើងការផ្តល់សេវាកម្ម និងប្រសិទ្ធភាពនៃការទាក់ទាញ និងសហការ ក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ ។<br>• ជំរុញការការអនុវត្តច្បាប់ស្តីពី សារព័ត៌-មាន ដើម្បីលើកកម្ពស់ វិធានការច្បាប់ សិទ្ធិសេរីភាពសារព័ត៌មានក្នុងការសរសេរ និងបោះពុម្ពផ្សាយ ។<br>• សិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងឧបករណ៍ច្បាប់ ដើម្បីតាមដាន ត្រួតពិនិត្យការធ្វើអាជីវកម្មប្រព័ន្ធផ្សព្វផ្សាយនិងដើម្បី | សកម្មភាពមួយចំនួន ដូចខាងក្រោម :<br>• ពង្រីកវិសាលភាព និងលើកកម្ពស់**គុណភាព លទ្ធភាពទទួលបាន និងប្រសិទ្ធ ភាពនៃបណ្តាញផ្សព្វផ្សាយជាតិ ដើម្បីផ្តល់សេវាកម្មឱ្យបាន ដល់ ៩៥ភាគរយនៃប្រជាជន ទូទាំងប្រទេស ដោយរួមទាំងមនុស្សថ្លង់និងជនពិការភ្នែក**ដល់ក្នុងតំបន់ និងទ្វិបផ្សេងទៀត រួមទាំងអាមេរិកខាងជើង។ បន្តសាងសង់ស្ថានីយវិទ្យុ និងទូរទស្សន៍ នៅតាមខេត្ត និងលើកកម្ពស់សមត្ថភាពដើម្បីមានលទ្ធភាពអាចបន្តផ្ទាល់នូវព្រឹត្តការណ៍សំខាន់ៗ នៅកម្រិតជាតិ និងមានលទ្ធភាពផលិតនូវកម្មវិធីផ្សព្វផ្សាយទៅដល់តំបន់នានាបន្ថែមទៀត ជាពិសេស បញ្ហាទាក់ទងនឹងស្ត្រីនិងកុមារ ។<br>• កសាងស្ថាប័ន និងសមត្ថភាពធនធានមនុស្ស ដោយផ្តោតលើ ការបង្កើនចំនួនមន្ត្រីស្ត្រី ការធ្វើឱ្យប្រសើរឡើងការផ្តល់សេវាកម្ម និងប្រសិទ្ធភាពនៃការទាក់ទាញនិងសហការក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ ។<br>• ជំរុញការការអនុវត្តច្បាប់ស្តីពី សារព័ត៌មាន ដើម្បីលើកកម្ពស់ វិធានការច្បាប់ សិទ្ធិសេរីភាពសារព័ត៌មានក្នុងការសរសេរ និងបោះពុម្ពផ្សាយ ។<br>• សិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងឧបករណ៍ច្បាប់ ដើម្បីតាមដានត្រួតពិនិត្យការធ្វើអាជីវកម្មប្រព័ន្ធផ្សព្វផ្សាយនិងដើម្បីគាំទ្រដល់ការអភិវឌ្ឍផ្នែក ព័ត៌មាន និងសម្លេង និងបច្ចេកវិទ្យាព័ត៌មាន ។<br>•បន្តលើកទឹកចិត្តនិងបើកទូលាយ នូវការចូលរួម |

| | | | |
|---|---|---|---|
| | | គាំទ្រដល់ការអភិវឌ្ឍផ្នែក ព័ត៌មាន និង សម្លេង និង បច្ចេកវិទ្យាព័ត៌មាន ។<br>● បន្តលើកទឹកចិត្តនិងបើកទូលាយនូវការចូលរួមរបស់វិស័យសាធារណៈសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល និងផ្តល់អាទិភាពដល់ស្ត្រី ក្នុងការដើរតួនាទីរបស់ខ្លួន នៅក្នុងផ្នែកព័ត៌មាន និងសម្លេង ។ | របស់វិស័យសាធារណៈសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល និងផ្តល់អាទិភាពដល់ស្ត្រីក្នុងការដើរតួនាទីរបស់ខ្លួននៅក្នុងផ្នែកព័ត៌មាន និងសម្លេង ។ |
| ២៤២-២៤៣ | ៤៨៨ | ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោយ :<br>• ពង្រីកការបណ្តុះបណ្តាលបច្ចេកទេសនិងមុខវិជ្ជាជីវៈ ជាពិសេសនៅក្នុងតំបន់ ជនបទ តាមរយៈ :<br>➤ ការវិភាគយ៉ាងទូលំទូលាយគ្រប់ជ្រុងជ្រោយពីតម្រូវការបណ្តុះបណ្តាល បច្ចេកទេសនិងមុខវិជ្ជាជីវៈដើម្បីបំពេញសេចក្តីត្រូវការរបស់និយោជិកនៅក្នុងតំបន់ទីប្រជុំជន និងដើម្បីគាំទ្រដល់ការអភិវឌ្ឍ សហគមន៍ជនបទ ។<br>➤ បង្កើតឱ្យមានការវាយតម្លៃគុណភាពនៅថ្នាក់ជាតិស្តង់ដារសមត្ថភាពជាតិការធ្វើតេស្ត និងការទទួលស្គាល់នូវកម្មវិធី និងវគ្គបណ្តុះបណ្តាលនានា ស្តីពី បច្ចេកទេស និងមុខវិជ្ជាជីវៈ ។<br>➤ ពង្រីកវិសាលភាព | ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការ ងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោយ :<br>• ពង្រីកការបណ្តុះបណ្តាលបច្ចេកទេសនិងមុខវិជ្ជាជីវៈ ជាពិសេស នៅក្នុងតំបន់ជនបទ តាមរយៈ :<br>➤ ការវិភាគយ៉ាងទូលំទូលាយគ្រប់ជ្រុងជ្រោយពីតម្រូវការបណ្តុះបណ្តាល បច្ចេកទេស និងមុខវិជ្ជាជីវៈដើម្បីបំពេញសេចក្តីត្រូវការរបស់និយោជិក នៅក្នុង តំបន់ទីប្រជុំជន និងដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគមន៍ជនបទ ។<br>➤ បង្កើតឱ្យមានការវាយតម្លៃ គុណភាព នៅថ្នាក់ជាតិ ស្តង់ដារសមត្ថភាពជាតិការធ្វើតេស្ត និងការទទួលស្គាល់នូវកម្មវិធី និងវគ្គបណ្តុះបណ្តាលនានា ស្តីពី បច្ចេកទេស និងមុខវិជ្ជាជីវៈ ។<br>➤ ពង្រីកវិសាលភាព និងចំនួនរបស់ ស្ថាប័នបណ្តុះបណ្តាលបច្ចេកទេស និងមុខវិជ្ជាជីវៈ នៅទូទាំងប្រទេស និងជំរុញយ៉ាងខ្លាំងក្លា |

| | | | |
|---|---|---|---|
| | | និងចំនួនរបស់ ស្ថាប័នបណ្តុះបណ្តាលបច្ចេកទេស និងមុខវិជ្ជាជីវៈ នៅទូទាំងប្រទេស និងជំរុញយ៉ាងខ្លាំងក្លានូវការ ចូលរួមរបស់ផ្នែកឯកជន ក្នុងការផ្តល់ការបណ្តុះតបណ្តាលបច្ចេកទេស និងមុខវិជ្ជាជីវៈ ដែលត្រូវ ការ។<br>➤ **<u>ធានាសមធម៌យេនឌ័រ នៅក្នុងលទ្ធភាពនៃការទទួលបានការបណ្តុះ បណ្តាលបច្ចេកទេស និងមុខវិជ្ជាជីវៈ</u>**។ | នូវការចូលរួមរបស់ ផ្នែកឯកជន ក្នុងការផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងមុខវិជ្ជាជីវៈ ដែលត្រូវការ។<br>➤ **<u>ធានាសមធម៌យេនឌ័រ និងពិការភាពនៅក្នុងលទ្ធភាពនៃការទទួលបាន ការបណ្តុះបណ្តាលបច្ចេកទេស និងមុខវិជ្ជាជីវៈ</u>**។ |
| ២៩៦ | ៥១២ | ក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្ត ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់ កុមារ និងយុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និងក្រៅ ប្រព័ន្ធ ដោយមិនប្រកាន់**<u>ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត និងឋានៈ នៅក្នុងសង្គមឡើយ</u>**។ ម្យ៉ាងវិញទៀត ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្សារភ្ជាប់នឹងការអប់រំ វប្បធម៌ សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាពប្រជាធិបតេយ្យ និងយុត្តិធម៌ ដោយប្រឆាំងនឹងអំពើ ហិង្សា | ក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្ត ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់ កុមារ និង យុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់**<u>ពូជសាសន៍ ពណ៌សម្បុរ ភេទ ពិការភាព ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត និងឋានៈ នៅក្នុងសង្គមឡើយ</u>**។ ម្យ៉ាងវិញទៀត ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្សារភ្ជាប់នឹងការអប់រំ វប្បធម៌ សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរព គោលការណ៍សេរីភាពប្រជាធិបតេយ្យ និងយុត្តិធម៌ដោយប្រឆាំងនឹងអំពើហិង្សា ប្រឆាំងនឹងការប្រើប្រាស់គ្រឿង ញៀន ការជួញដូរកុមារ និងស្ត្រី និងការរើសអើងគ្រប់ប្រភេទក្នុងសង្គម។ |

| | | | |
|---|---|---|---|
| | | ប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន ការជួញដូរកុមារ និងស្ត្រី និងការរើសអើងគ្រប់ប្រភេទ ក្នុងសង្គម ។ | |
| ២៦៤ | ៩២២ | រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថា ប្រជារាស្ត្រមានសុខភាពល្អ គឺជាមូលដ្ឋាន គន្លឹះ សម្រាប់ការ អភិវឌ្ឍធនធានមនុស្ស និងការវឌ្ឍនភាពសេដ្ឋកិច្ច-សង្គមកិច្ច ប្រកបដោយចីរភាព។ រាជរដ្ឋាភិបាល កម្ពុជា បានផ្តោតការយកចិត្តទុកដាក់ លើការលើកកម្ពស់សុខមាលភាពរបស់ពល រដ្ឋជាទូទៅ **ជាពិសេស ប្រជារាស្ត្រ ក្រីក្រ ស្ត្រី និងកុមារ**។ ដើម្បីធានាឱ្យការអភិវឌ្ឍ ដែលមានលក្ខណៈ ជាប្រព័ន្ធក្នុងការផ្តល់ សេវាសុខាភិបាលចំពោះប្រជាជន រាជរដ្ឋា-ភិបាលកម្ពុជា បានប្រកាន់យកវិធីសាស្ត្រ អភិក្រមគ្រប់គ្រងទូទាំងវិស័យ និងបាន រៀបចំផែនការយុទ្ធសាស្ត្រសុខាភិបាល លើកទី១ (២០០៣-២០០៧)។ ផែនការ នេះត្រូវបានអនុវត្តដោយសហការយ៉ាង ជិតស្និទ្ធ ជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដែលពាក់ព័ន្ធ។ ផែនការយុទ្ធសាស្ត្រ សុខាភិបាល ២០០៨-២០១៥ ត្រូវបាន រៀបចំឡើង ហើយបច្ចុប្បន្ននេះកំពុងត្រូវ បានអនុវត្តដោយសហការយ៉ាងជិតស្និទ្ធ ជាមួយដៃគូអភិវឌ្ឍន៍។ ជាមួយគ្នានេះ ការអនុវត្ត សំណុំសកម្មភាពអប្បបរិមា កំពុងមានវឌ្ឍនភាពល្អ។ វិស័យសុខាភិ-បាល គឺជាវិស័យអាទិភាព មួយសម្រាប់ | រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថា ប្រជារាស្ត្រ មានសុខភាពល្អ គឺជាមូលដ្ឋាន គន្លឹះ សម្រាប់ការ អភិវឌ្ឍធនធានមនុស្ស និងការវឌ្ឍនភាព សេដ្ឋកិច្ច -សង្គមកិច្ច ប្រកប ដោយចីរភាព។ រាជរដ្ឋាភិបាល កម្ពុជា បានផ្តោតការយកចិត្តទុកដាក់ លើការលើក កម្ពស់សុខមាលភាពរបស់ពលរដ្ឋជាទូទៅ **ជាពិសេស ប្រជារាស្ត្រ ក្រីក្រ ជនពិការ ស្ត្រី និងកុមារ**។ ដើម្បីធានាឱ្យការអភិវឌ្ឍដែលមានលក្ខណៈ ជាប្រព័ន្ធក្នុង ការផ្តល់សេវាសុខាភិបាលចំពោះ ប្រជាជន រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់ យកវិធី សាស្ត្រ អភិក្រមគ្រប់គ្រងទូទាំងវិស័យនិងបាន រៀបចំ ផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី១ (២០០៣-២០០៧)។ ផែនការនេះ ត្រូវបាន អនុវត្ត ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូ អភិវឌ្ឍន៍ក្រៅប្រទេសដែលពាក់ព័ន្ធ។ ផែនការ យុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ ត្រូវបាន រៀបចំឡើងហើយបច្ចុប្បន្ននេះកំពុងត្រូវបាន អនុវត្ត ដោយសហការយ៉ាងជិតស្និទ្ធ ជាមួយដៃគូ អភិវឌ្ឍន៍។ ជាមួយគ្នានេះការអនុវត្តសំណុំ សកម្មភាពអប្បបរិមាកំពុងមានវឌ្ឍនភាពល្អ។ វិស័យសុខាភិបាល គឺជាវិស័យអាទិភាពមួយ សម្រាប់ "កម្មវិធីជាអាទិភាព" ដែលធានាការ វិភាជន៍ថវិកាគ្រប់គ្រាន់ និងការផ្តល់មូលនិធិទាន់ ពេលវេលា ទាំងថវិកាចំណាយចរន្ត និងចំណាយ |

| | | | |
|---|---|---|---|
| | | "កម្មវិធីជាអាទិភាព" ដែលធានាការវិភាជន៍ថវិកាគ្រប់គ្រាន់ និងការផ្ដល់មូលនិធិទាន់ពេលវេលា ទាំងថវិកាចំណាយចរន្ត និងចំណាយជាមូលធន។ ក្នុងនិតិ កាលទី៣ នៃរដ្ឋសភា ថវិកាចរន្តសម្រាប់វិស័យសុខាភិបាលបាន កើនឡើងទ្វេរដងគឺប្រមាណ ១០ភាគរយ នៃថវិកាចរន្តសម្រាប់ឆ្នាំ ២០០៧។ | ជាមូលធន។ ក្នុងនិតិកាលទី៣ នៃរដ្ឋសភាថវិកាចរន្តសម្រាប់វិស័យសុខាភិបាល បានកើនឡើងទ្វេរដងគឺប្រមាណ ១០ភាគរយនៃថវិកាចរន្តសម្រាប់ឆ្នាំ២០០៧។ |
| ២៦៥ | ៥២៦ | ការអនុវត្តនគោលនយោបាយជាអាទិភាពសម្រាប់វិស័យសុខាភិបាល ក្នុងរយៈ ពេល ៥ឆ្នាំខាងមុខ នឹងត្រូវបានត្រួសត្រាយដោយក្របខ័ណ្ឌយុទ្ធសាស្ត្រ ដែលបានលើកឡើងនៅក្នុង ផែនការយុទ្ធសាស្ត្រវិស័យសុខា-ភិបាល ២០០៨-២០១៥ គោលនយោបាយស្ដីអំពីការផ្ដល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្របខ័ណ្ឌគោលនយោ-បាយសម្រាប់វិមជ្ឈមការនិងវិសហមជ្ឈការ និងក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកាជាតិ ។ អាទិភាពជាយុទ្ធសាស្ត្រសម្រាប់វិស័យសុខាភិបាលរួមមានពីរផ្នែកធំៗ មានទំនាក់ទំនងគ្នាអន្តរវិស័យ ហើយដែលក្រសួងសុខាភិបាល និងដៃគូទាំងអស់ត្រូវផ្ដោតយកចិត្តទុកដាក់ជាពិសេស។ អាទិភាពទាំងពីរផ្នែកនេះ រួមមានអាទិភាពសុខភាពរបស់ប្រជាជន និងសេវាសុខភាពជាសារវ័ន្ត និងបញ្ហាប្រឈមដែលមានទាក់ទងនឹងដំណើរការមុខងារ របស់ប្រព័ន្ធសុខាភិបាល | ការអនុវត្តនគោលនយោបាយជាអាទិភាពសម្រាប់វិស័យសុខាភិបាល ក្នុងរយៈពេល៥ឆ្នាំខាងមុខ នឹងត្រូវបានត្រួសត្រាយដោយក្របខ័ណ្ឌ យុទ្ធសាស្ត្រដែលបានលើកឡើង នៅក្នុង ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល២០០៨-២០១៥ គោលនយោបាយ ស្ដីអំពីការផ្ដល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្របខ័ណ្ឌគោលនយោបាយ សម្រាប់វិមជ្ឈមការនិងវិសហមជ្ឈការ និងក្របខ័ណ្ឌ យុទ្ធសាស្ត្រថវិកាជាតិ ។ អាទិភាពជាយុទ្ធសាស្ត្រសម្រាប់វិស័យសុខាភិបាល រួមមានពីរផ្នែកធំៗ មានទំនាក់ទំនងគ្នាអន្តរវិស័យ ហើយដែលក្រសួងសុខាភិបាល និងដៃគូទាំងអស់ត្រូវផ្ដោតយកចិត្តទុកដាក់ជាពិសេស។ អាទិភាពទាំងពីរផ្នែកនេះរួមមាន អាទិភាព សុខភាពរបស់ប្រជាជន និងសេវាសុខភាពជាសារវ័ន្ត និងបញ្ហាប្រឈម ដែលមានទាក់ទងនឹងដំណើរការមុខងាររបស់ប្រព័ន្ធសុខាភិបាល "ទាំងផ្នែកផ្ដល់សេវា" និង " ទាំងផ្នែកតម្រូវការសេវា"។ ការកសាងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៨-២០១៥ |

| | | | |
|---|---|---|---|
| | | "ទាំងផ្នែកផ្តល់សេវា" និង "ទាំងផ្នែកតម្រូវការសេវា"។ ការកសាងក្របខ័ណ្ឌ យុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៨-២០១៥ រួមមាន កម្មវិធីសុខភាពចម្បងចំនួន ៣ របស់ ក្រសួងសុខាភិបាល :<br>● កម្មវិធីសុខភាពបន្តពូជ មាតា ទារកនិងកុមារ។<br>● កម្មវិធីប្រយុទ្ធនឹងជម្ងឺឆ្លង។<br>● **កម្មវិធីប្រយុទ្ធនឹងជម្ងឺមិនឆ្លង និងបញ្ហាសុខភាពដទៃ**។ | រួមមានកម្មវិធីសុខភាពចម្បងចំនួន៣របស់ក្រសួងសុខាភិបាល :<br>● កម្មវិធីសុខភាពបន្តពូជ មាតា ទារកនិងកុមារ។<br>● កម្មវិធីប្រយុទ្ធនឹងជម្ងឺឆ្លង។<br>●**កម្មវិធីប្រយុទ្ធនឹងជម្ងឺមិនឆ្លង និងបញ្ហាសុខភាពដទៃទៀត ទាក់ទងនឹងពិការ រូបរាងកាយ ពិការបញ្ញា ពិការស្មារតី ពិការនិយាយ ពិការស្តាប់ និងពិការភ្នែក**។ |
| ២៦៥ | ៥២៧ | នៅក្នុងកម្មវិធីនីមួយៗ នៃកម្មវិធីទាំង ៣ ខាងលើ ក្រសួងសុខាភិបាល នឹងផ្តោតលើការអនុវត្តយុទ្ធសាស្ត្រសុខាភិបាលប្រទាក់ក្រឡា ចំនួន ៥ ដែលរួមបញ្ចូលវិធានការទាំងផ្នែកផ្តល់សេវា និងផ្នែកតម្រូវការសេវា :<br>● ក្នុងផ្នែកនៃការផ្តល់សេវាសុខាភិបាល សកម្មភាពដែលនឹងត្រូវអនុវត្តរួមមាន :<br>➤ ពង្រីកការគ្របដណ្តប់ការផ្តល់សេវាសំណុំសកម្មភាពអប្បបរមា និងសំណុំ សកម្មភាពបង្គ្រប់យោងតាមផែនការគ្របដណ្តប់វិស័យសុខាភិបាល និងតម្រូវការរបស់អតិថិជន ។<br>➤ **ពង្រឹងប្រព័ន្ធគាំទ្រការផ្តល់សេវាសុខាភិបាលក្នុងលក្ខណៈសមាហរកម្ម**។ | នៅក្នុងកម្មវិធីនីមួយៗ នៃកម្មវិធីទាំង ៣ ខាងលើ ក្រសួងសុខាភិបាល នឹងផ្តោតលើការអនុវត្តយុទ្ធសាស្ត្រសុខាភិបាលប្រទាក់ក្រឡា ចំនួន ៥ ដែលរួមបញ្ចូលវិធានការទាំងផ្នែកផ្តល់សេវា និងផ្នែកតម្រូវការសេវា :<br>●ក្នុងផ្នែកនៃការផ្តល់សេវាសុខាភិបាល សកម្មភាពដែលនឹងត្រូវអនុវត្តរួមមាន :<br>➤ ពង្រីកការគ្របដណ្តប់ការផ្តល់ សេវាសំណុំសកម្មភាពអប្បបរមា និងសំណុំសកម្មភាពបង្គ្រប់យោងតាមផែនការគ្របដណ្តប់វិស័យសុខាភិបាល និងតម្រូវការរបស់អតិថិជន ។<br>➤ **ពង្រឹងប្រព័ន្ធគាំទ្រការផ្តល់សេវាសុខាភិបាលក្នុងលក្ខណៈសមាហរកម្ម ដោយរួមបញ្ចូលទាំងជនពិការ**។<br>➤ **កែប្រែតម្រង់ការផ្តល់សេវា និងការធ្វើអន្តរាគមន៍សុខភាពសាធារណៈ ឱ្យឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាពរបស់ប្រ** |

| | | | |
|---|---|---|---|
| | | ➤ **<u>តម្រែតម្រង់ការផ្តល់សេវា និងការធ្វើអន្តរាគមន៍សុខភាពសាធារណៈឱ្យឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាព</u>**។<br>➤ បង្កើតនិងអនុវត្ត បទដ្ឋានគុណភាពនៅទូទាំងវិស័យសុខាភិបាល (សេវារដ្ឋ សេវាឯកជន និងសេវាឯកជនមិនស្វែងរកកម្រៃ)។<br>➤ បង្កើតគំរូកិច្ចសន្យា ដែលជាចំណែកមួយនៃវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ សម្រាប់ការ ផ្តល់សេវា។ | **ជាជន ពិសេសជនពិការ**។<br>➤ បង្កើតនិងអនុវត្តបទដ្ឋានគុណភាពនៅទូទាំង វិស័យសុខាភិបាល (សេវារដ្ឋ សេវាឯកជន និងសេវាឯកជនមិនស្វែងរកកម្រៃ)។<br>➤ បង្កើតគំរូកិច្ចសន្យា ដែលជាចំណែកមួយនៃវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ សម្រាប់ការផ្តល់សេវា។ |
| ២៦៦ | ៥២៧ | • ក្នុងផ្នែក ប្រព័ន្ធពតិមានសុខាភិបាល សកម្មភាពដែលនឹងត្រូវអនុវត្ត រួមមាន :<br>➤ បង្កើនភាពត្រឹមត្រូវ ទាន់ពេលវេលា និងពេញលេញ នៃទិន្នន័យដែលមានគុណភាពខ្ពស់ ពីផ្នែករដ្ឋ និងឯកជន ជាមួយនឹងការលើកកម្ពស់ការសម្រប សម្រួល និងធនធាន សម្រាប់ប្រព័ន្ធពតិមានសុខាភិបាល ។<br>➤ **<u>លើកកម្ពស់ការចែករំលែក ការគ្រប់គ្រង ការវិភាគ ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យនៅគ្រប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល រួមទាំងទិន្នន័យ ប្រជាជន និង ទិន្នន័យប្រជាសាស្ត្រសង្គម</u>**។ | ● ក្នុងផ្នែក ប្រព័ន្ធពតិមានសុខាភិបាល សកម្មភាពដែលនឹងត្រូវអនុវត្ត រួមមាន :<br>➤ បង្កើនភាពត្រឹមត្រូវ ទាន់ពេលវេលា និងពេញលេញ នៃទិន្នន័យដែលមានគុណភាពខ្ពស់ ពីផ្នែករដ្ឋ និងឯកជន ជាមួយនឹងការលើកកម្ពស់ការសម្រប សម្រួល និងធនធាន សម្រាប់ប្រព័ន្ធពតិមានសុខាភិបាល ។<br>➤ **<u>លើកកម្ពស់ការចែករំលែកដល់សាធារណជន ពិសេសដល់មនុស្សថ្លង់ និងជនពិការភ្នែក ស្តីអំពីការគ្រប់គ្រង ការវិភាគ ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យនៅគ្រប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល រួមទាំងទិន្នន័យ ប្រជាជន និង ទិន្នន័យប្រជាសាស្ត្រសង្គម</u>**។ |

| | | | |
|---|---|---|---|
| | | ➤ លើកកម្ពស់ប្រព័ន្ធតាមដានជម្ងឺថ្នាក់ជាតិ ប្រព័ន្ធកត់ត្រាប្រវត្តិវេជ្ជសាស្ត្ររបស់អ្នកជម្ងឺនៅមូលដ្ឋានសុខាភិបាលរដ្ឋ និងពង្រឹងករណី រាយការណ៍ជម្ងឺ ការតាមដានត្រួតពិនិត្យ និងការឆ្លើយ តបទៅនឹងជម្ងឺមិន ឆ្លង។<br>➤ **ពង្រីកការចូលរួមរបស់វិស័យឯកជន នៅក្នុងប្រព័ន្ធពត៌មានសុខាភិបាលជាតិ និងសម្រួលការប្រើប្រាស់ទិន្នន័យ សម្រាប់ការរៀបចំផែនការ ការបែងចែកធនធាន ការគ្រប់គ្រងធនធានមនុស្សហេដ្ឋារចនាសម្ព័ន្ធ និងការផ្គត់ផ្គង់។** | ➤ លើកកម្ពស់ប្រព័ន្ធតាមដានជម្ងឺថ្នាក់ជាតិ ប្រព័ន្ធកត់ត្រាប្រវត្តិវេជ្ជសាស្ត្ររបស់អ្នកជម្ងឺនៅមូលដ្ឋានសុខាភិបាលរដ្ឋ និងពង្រឹងករណីរាយការណ៍ជម្ងឺ ការតាមដានត្រួតពិនិត្យ និងការឆ្លើយតប ទៅនឹងជម្ងឺមិនឆ្លង។<br>➤ **ពង្រីកការចូលរួមរបស់វិស័យឯកជន ព្រមទាំងអង្គការពាក់ព័ន្ធ នឹងសុខភាព និងពិការភាពនៅក្នុងប្រព័ន្ធពត៌មានសុខាភិបាលជាតិ និងសម្រួលការប្រើប្រាស់ទិន្នន័យ សម្រាប់ការរៀបចំផែនការ ការបែងចែកធនធាន ការគ្រប់គ្រងធនធានមនុស្សហេដ្ឋារចនាសម្ព័ន្ធ និងការផ្គត់ផ្គង់។** |
| ២៦៨ | ៥២៩ | ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់ រាជរដ្ឋាភិបាលកម្ពុជា សម្រាប់វិស័យសុខាភិបាល សកម្មភាពសំខាន់ៗរបស់អ្នកគ្រប់គ្រង និងមន្ត្រីសុខាភិបាល នៅគ្រប់ផ្នែកទាំងអស់ នឹងត្រូវបានណែនាំដោយគោលការណ៍អនុវត្តការងារ ៥ យ៉ាង ដូចខាងក្រោម :<br>● ការគាំពារសុខភាពសង្គម ជាពិសេស ប្រជាជនក្រីក្រ **ក្រុមប្រជាជនងាយរងគ្រោះ**។<br>● វិធីសាស្ត្រផ្តោតការយកចិត្តទុកដាក់លើអតិថិជន ក្នុងការផ្តល់សេវាសុខភាព។<br>● វិធីសាស្ត្រសមាហរណកម្ម នៅក្នុងការផ្នែកផ្តល់សេវាសុខភាព និងការធ្វើ | ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ វិស័យសុខាភិបាល សកម្ម-ភាពសំខាន់ៗរបស់អ្នកគ្រប់គ្រង និងមន្ត្រីសុខាភិបាល នៅគ្រប់ផ្នែកទាំងអស់ នឹងត្រូវបានណែនាំដោយគោលការណ៍អនុវត្តការងារ ៥ យ៉ាង ដូចខាងក្រោម :<br>● ការគាំពារសុខភាពសង្គម ជាពិសេស ប្រជាជនក្រីក្រ **ក្រុមប្រជាជនងាយ រងគ្រោះ និងជនពិការ**។<br>● វិធីសាស្ត្រផ្តោតការយកចិត្តទុកដាក់លើអតិថិជនក្នុងការ ផ្តល់សេវាសុខភាព។<br>● វិធីសាស្ត្រសមាហរណកម្ម នៅក្នុងការផ្នែកផ្តល់សេវាសុខភាព និងការធ្វើ អន្តរាគមន៍សុខភាពសាធារណៈមានគុណភាពខ្ពស់ ។ |

| | | | |
|---|---|---|---|
| | | អន្តរាគមន៍សុខភាពសាធារណៈមាន គុណភាពខ្ពស់ ។<br>• ការគ្រប់គ្រងធនធានមនុស្ស គឺជាសសរ ទ្រូងនៃប្រព័ន្ធសុខាភិបាល ទាំងមូល ។<br>• អភិបាលកិច្ចល្អ និងការទទួលខុសត្រូវ ។ | • ការគ្រប់គ្រងធនធានមនុស្ស គឺជាសសរ ទ្រូងនៃប្រព័ន្ធសុខាភិបាល ទាំងមូល ។<br>• អភិបាលកិច្ចល្អ និងការទទួលខុសត្រូវ ។ |
| ២៧៦ | ៩៤២ | នៅក្នុងវិស័យជាយុទ្ធសាស្ត្រទី៥ ដែលផ្តោតការយកចិត្តទុកដាក់លើការ**ជំរុញការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុង វិស័យសាធារណៈ និងក្នុងវិស័យនយោបាយ** ក្រសួងកិច្ចការនារី ដោយសហការ យ៉ាងជិតស្និតជាមួយ ភាគីដែលមានចំណែកពាក់ពន្ធ័ទាំងអស់ នឹងផ្តោតការយក ចិត្តទុកដាក់លើ សកម្មភាពសំខាន់ៗដូចខាងក្រោម :<br>• **បង្កើនចំនួនតំណាងស្ត្រីដែលសកម្ម នៅក្នុងផ្នែកនៃការធ្វើ សេចក្តីសម្រេច** នៃស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ គ្រប់កម្រិត តាមរយៈការ ស្វែងរក ការគាំទ្រ មតិជាមួយ គណបក្សនយោបាយ និងស្ថាប័នពាក់ព័ន្ធ ដើម្បី បង្កើនសមាមាត្រ ស្ត្រីជាបេក្ខជនឈរឈ្មោះ និងមានលំដាប់ លេខរៀងខ្ពស់ក្នុង បញ្ជីបេក្ខជន ឈរឈ្មោះ បោះឆ្នោតព្រឹទ្ធសភា តំណាងរាស្ត្រ និងក្រុម ប្រឹក្សា ថ្នាក់ក្រោមជាតិ ។ ការជំរុញឱ្យមាន ការពិភាក្សាគោលនយោបាយ និងការ បង្កើត យុទ្ធសាស្ត្រ និង សកម្មភាព ស្វែង រក ការគាំទ្រមតិក្នុងការ អនុវត្តសកម្មភាព ជាវិជ្ជមាន និងការ កំណត់កូតាសម្រាប់ស្ត្រី | នៅក្នុងវិស័យជាយុទ្ធសាស្ត្រទី៥ ដែលផ្តោតការយកចិត្តទុកដាក់លើការ**ជំរុញការចូលរួមរបស់ស្ត្រី ដោយរួមទាំងស្ត្រីពិការ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុង វិស័យសាធារណៈ និងក្នុងវិស័យនយោបាយ** ក្រសួងកិច្ចការនារី ដោយសហការ យ៉ាងជិតស្និតជាមួយ ភាគីដែលមានចំណែកពាក់ពន្ធ័ទាំងអស់នឹងផ្តោតការយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗដូចខាងក្រោម:<br>• **បង្កើនចំនួនតំណាងស្ត្រី រួមទាំងស្ត្រីពិការ ដែលសកម្មនៅក្នុងផ្នែកនៃការធ្វើសេចក្តីសម្រេច** នៃស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិគ្រប់កម្រិត តាមរយៈការ ស្វែង រកការគាំទ្រ មតិជាមួយ គណបក្សនយោបាយ និងស្ថាប័នពាក់ព័ន្ធ ដើម្បី បង្កើនសមាមាត្រស្ត្រីជាបេក្ខជនឈរឈ្មោះនិង មានលំដាប់លេខរៀងខ្ពស់ក្នុង បញ្ជីបេក្ខជន ឈរឈ្មោះបោះឆ្នោតព្រឹទ្ធសភា តំណាងរាស្ត្រ និងក្រុមប្រឹក្សា ថ្នាក់ក្រោមជាតិ។ ការជំរុញឱ្យមានការពិភាក្សាគោលនយោបាយ និងការបង្កើត យុទ្ធសាស្ត្រ និងសកម្មភាព ស្វែងរកការគាំទ្រមតិ ក្នុងការ អនុវត្តសកម្មភាព ជាវិជ្ជមាន និងការ កំណត់កូតាសម្រាប់ស្ត្រីនៅគ្រប់កម្រិត ។ការបង្កើន ការយល់ដឹងរបស់សាធារណៈជនពីសារៈសំខាន់នៃ ការចូលរួមរបស់ស្ត្រីនៅកម្រិតជាន់ខ្ពស់តំណាង |

| | | | |
|---|---|---|---|
| | | នៅគ្រប់កម្រិត។ ការបង្កើនការ យល់ដឹងរបស់សាធារណៈជន ពីសារៈសំខាន់ នៃការចូលរួមរបស់ ស្ត្រីនៅកម្រិត ជាន់ខ្ពស់ តំណាងរាស្ត្រ សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងសមាជិកក្រុមប្រឹក្សា ឃុំ-សង្កាត់ ។ អភិវឌ្ឍសមត្ថភាពដល់ស្ត្រី ដែលជាប់ឆ្នោត និងដែលជ្រើសតាំង តំណាងប្រជាពលរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោម ជាតិ រួមទាំង ព្រមទាំង បេក្ខនារីដែលនឹងឈរឈ្មោះ បោះឆ្នោត ក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០១២ និងតំណាងរាស្ត្រអាណត្តិទី៥។<br>• **<u>ការលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងការធ្វើ សេចក្តីសម្រេច ក្នុងវិស័យ សាធារណៈគ្រប់កម្រិត</u>**តាមរយៈ ការជំរុញឱ្យមាន ការអនុវត្តគោលនយោបាយ និងនីតិវិធីតម្លើងឋានៈ តួនាទី និងជ្រើសរើសមន្ត្រី រាជការ ដែលមានការឆ្លើយតប នឹងសមភាពយេនឌ័រ។ កិច្ចសហការជាមួយ សាលាភូមិន្ទរដ្ឋបាល ក្នុងការរៀបចំកម្មវិធីសិក្សាឆ្លើយតបនឹងយេនឌ័រ និងការបង្កើនចំនួនសិស្សស្ត្រី កិច្ចសហការជាមួយសមាគមមន្ត្រីរាជការនារី និងដៃគូពាក់ព័ន្ធ ក្នុងការបង្កើន ប្រសិទ្ធភាពក្នុងការ បំពេញការងារ និងការការ ពារសិទ្ធិ និងសុខមាលភាព | រាស្ត្រ សមាជិកក្រុមប្រឹក្សា រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងសមាជិកក្រុមប្រឹក្សា ឃុំ-សង្កាត់ ។ អភិវឌ្ឍសមត្ថភាព ដល់ស្ត្រី ដែលជាប់ ឆ្នោត និងដែលជ្រើសតាំង តំណាងប្រជាពលរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោម ជាតិ រួមទាំង ព្រមទាំង បេក្ខនារីដែលនឹងឈរឈ្មោះ បោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០១២ និងតំណាងរាស្ត្រអាណត្តិទី៥។<br>• **<u>ការលើកកម្ពស់ការចូលរួមរបស់ស្ត្រី ដោយរួមទាំងស្ត្រីពិការ នៅក្នុងការធ្វើ សេចក្តីសម្រេច ក្នុងវិស័យ សាធារណៈគ្រប់កម្រិត</u>**តាមរយៈ ការជំរុញឱ្យមាន ការអនុវត្តគោលនយោបាយ និងនីតិវិធីតម្លើងឋានៈ តួនាទី និងជ្រើសរើសមន្ត្រីរាជការ ដែលមានការឆ្លើយតបនឹងសមភាពយេនឌ័រ។ កិច្ចសហការជាមួយ សាលាភូមិន្ទរដ្ឋបាល ក្នុងការរៀបចំកម្មវិធីសិក្សាឆ្លើយតប នឹងយេនឌ័រ និងការបង្កើន ចំនួនសិស្សស្ត្រី កិច្ចសហការជាមួយសមាគមមន្ត្រីរាជការនារី និងដៃគូពាក់ព័ន្ធ ក្នុងការបង្កើនប្រសិទ្ធភាពក្នុងការ បំពេញការងារ និងការការពារសិទ្ធិ និងសុខមាលភាពរបស់មន្ត្រីរាជការនារី។ កសាងសមត្ថភាព និងជំនាញស្តីពី ភាពជាអ្នកដឹកនាំនិងគ្រប់គ្រងព្រមទាំងជំនាញពាក់ព័ន្ធនានា ដល់ថ្នាក់ដឹកនាំជាស្ត្រី ។ |

| | | | |
|---|---|---|---|
| | | របស់មន្ត្រីរាជការនារី ។ កសាង សមត្ថភាព និង ជំនាញស្តីពី ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ព្រមទាំងជំនាញពាក់ព័ន្ធនានា ដល់ថ្នាក់ដឹកនាំជាស្ត្រី ។ | |
| ២៧៧ | ៩៤៣ | សមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រី គឺជាគោលដៅអភិវឌ្ឍន៍មួយ ដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្រសួងកិច្ចការនារី មានតួនាទីយ៉ាងច្បាស់ ក្នុងការស្វែងរកការគាំទ្រមតិ និងតាមដានពីវឌ្ឍនភាពលើការងារទាំងនេះ ប៉ុន្តែ យន្តការ និងវិធីសាស្ត្រ សម្រាប់ជំរុញឱ្យសម្រេចគោលដៅ អភិវឌ្ឍន៍នេះ គឺជាការទទួលខុសត្រូវ និងភារកិច្ចរបស់ក្រសួង-ស្ថាប័នពាក់ពន្ធ័ ទាំងអស់ និង ពុំមែនជាភារកិច្ចរបស់ក្រសួងកិច្ចការនារីតែឯកឯងនោះទេ ព្រោះ បញ្ហាយេនឌ័រ គឺជាបញ្ហាអន្តរវិស័យ ដែលទាមទារឱ្យមានការបញ្ជ្រាបទៅក្នុង គ្រប់ដំណើរការ និងគោលនយោបាយតាមវិស័យទាំងអស់ ។<br>● **<u>ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយជាតិ និងប្រពន្ធ័ស្ថិតិជាតិ</u>** ផ្តោតជា សំខាន់លើ (១) ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការ រៀបចំតាមដានត្រួត ពិនិត្យ និងវាយតម្លៃ គោលនយោបាយជាតិ និង | សមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រី គឺជាគោលដៅអភិវឌ្ឍន៍មួយដ៏សំខាន់របស់រាជ រដ្ឋាភិ - បាលកម្ពុជា ដែលក្រសួងកិច្ចការនារីមានតួនាទីយ៉ាងច្បាស់ក្នុងការស្វែងរកការគាំទ្រមតិនិងតាមដានពីវឌ្ឍនភាពលើការងារទាំងនេះ ប៉ុន្តែ យន្តការ និងវិធីសាស្ត្រ សម្រាប់ជំរុញឱ្យសម្រេចគោលដៅអភិវឌ្ឍន៍នេះ គឺជាការទទួលខុសត្រូវនិងភារកិច្ចរបស់ក្រសួង-ស្ថាបន័ពាក់ពន្ធ័ ទាំងអស់ និង ពុំមែនជាភារកិច្ចរបស់ក្រសួង កិច្ចការនារីតែឯកឯងនោះទេ ព្រោះបញ្ហាយេនឌ័រ គឺជាបញ្ហាអន្តរវិស័យ ដែលទាមទារឱ្យមានការបញ្ជ្រាបទៅក្នុងគ្រប់ដំណើរការ និងគោលនយោបាយតាមវិស័យទាំង អស់ ។<br>● **<u>ការបញ្ជ្រាបយេនឌ័រ ដោយរួមទាំងស្ត្រីពិការក្នុងគោលនយោបាយជាតិ និងប្រពន្ធ័ស្ថិតិជាតិ</u>** ផ្តោតជាសំខាន់លើ (១) ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការរៀបចំតាមដានត្រួតពិនិត្យ និងវាយតម្លៃ គោលនយោបាយជាតិ និងគោលនយោបាយតាមវិស័យ (២) ការពង្រឹងនិងពង្រីកយន្តការបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (៣) ការអភិវឌ្ឍសមត្ថភាព ស្តីពីការបញ្ជ្រាបយេនឌ័រដល់ក្រសួង-ស្ថាប័នពាក់ពន្ធ័ ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ (៤) ការស្វែងរកការគាំទ្រមតិការបញ្ចុះបញ្ចូលឱ្យធ្វើសមាហរណកម្មបញ្ហា |

| | | | |
|---|---|---|---|
| | | គោលនយោបាយតាម វិស័យ (២) ការពង្រឹង និងពង្រីកយន្តការបញ្ជ្រាបយេនឌ័រ នៅថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ (៣) ការអភិវឌ្ឍសមត្ថភាព ស្តីពីការបញ្ជ្រាប យេនឌ័រដល់ក្រសួង-ស្ថាប័នពាក់ពន្ធ័ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (៤) ការស្វែងរកការគាំទ្រមតិ ការបញ្ចុះបញ្ចូលឱ្យធ្វើសមាហរណកម្មបញ្ហាយេនឌ័រទៅក្នុងដំណើរ នៃការរៀបចំ ផែនការ ការរៀបចំថវិកា និងការរៀបចំរបាយការណ៍ (៥) ពង្រឹងការរៀបចំនិងអនុវត្តផែនការបញ្ជ្រាបយេនឌ័រ តាមវិស័យ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការបញ្ជ្រាបយេនឌ័រនៅក្នុងប្រព័ន្ធស្ថិតិជាតិ។ | យេនឌ័រទៅក្នុងដំណើរនៃការរៀបចំផែនការ ការរៀបចំថវិកា និងការរៀបចំរបាយការណ៍ (៥) ពង្រឹងការរៀបចំនិងអនុវត្តផែនការបញ្ជ្រាបយេនឌ័រតាមវិស័យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការបញ្ជ្រាបយេនឌ័រនៅក្នុងប្រព័ន្ធស្ថិតិជាតិ។ |
| ២៩៩ | **តារាងទី ២៦** | លើកកម្ពស់វិស័យអប់រំ ( * )<br>១៦* អត្រាពិតនៃការសិក្សា : បឋមសិក្សា (សរុប-ប្រុស-ស្រី) ៩១,៩-៩៣,០-៩០,៧/ ១០០/ ១០០<br>១៧* អត្រាពិតនៃការសិក្សា : មធ្យមសិក្សាបឋមភូមិ ( សរុប-ប្រុស-ស្រី) ២៦,១-២៧,១- ២៤,៨ / ៧៥ សម្រាប់ទាំងអស់ / ១០០ សម្រាប់ទាំងអស់<br>១៨*<br>១៩*<br>២០* កុមារអាយុ ៦-១៤ឆ្នាំ មិនបានចូលរៀន (%) ១៨,៧ ១១ ០ | សូចនាករវិស័យអប់រំនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣) គួរតែទាក់ទងនឹងពិការភាព ដូចដែលមានចែងនៅក្នុងគោល ដៅអភិវឌ្ឍន៍សហស្សវត្សរ៍<br>**<u>គោលដៅ ២ :</u>**<br>**<u>សម្រេចនូវការអប់រំបឋមជាសកល</u>**<br>២.១ ផលធៀបការចុះឈ្មោះសរុបរបស់កុមារពិការនៅសាលាបឋមសិក្សា<br>២.២ សមាមាត្រសិស្សពិការថ្នាក់ទី១ ដែលឡើងដល់ថ្នាក់ចុង ក្រោយនៅក្នុងសាលាបឋមសិក្សា |

| | | | |
|---|---|---|---|
| | | | ២.៣ អត្រាអក្ខរកម្មរបស់ជនពិការអាយុពី១៥-២៤ឆ្នាំ ស្ត្រី និងបុរស |
| ២៩៩ | **តារាងទី ២៦** | លើកម្ពស់ក្នុងវិស័យសុខាភិបាល ( * )<br>៧* អត្រាមរណភាពទារក<br>ក្នុង១.០០០កំណើតរស់ ៦៦ ៦០ ៥០<br>៨* អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ<br>ក្នុង១.០០០កំណើតរស់ ៨២ ៧៥ ៦៥<br>៩* មរណភាពមាតា<br>ក្នុង១០០.០០០កំណើតរស់ ពុំមានតួលេខ ២៤៣ ១៤០<br>១០*<br>ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ (%) ពុំមានតួលេខ ៧០ ៨០<br>១១*<br>អត្រាប្រេវ៉ាឡង់មេរោគហ៊ីវ/ជម្ងឺអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥-៤៩ឆ្នាំ ១,៩ ១,៩ ១,៨<br>១២* ករណីជម្ងឺគ្រុនចាញ់ អត្រាស្លាប់ ០,៣៦ ០,២ ០,១<br>១៣* ករណីអ្នកផ្ទុកជម្ងឺរបេងក្នុង ១០០.០០០នាក់ ពុំមានតួលេខ ២១៤ ១៣៥<br>១៤*<br>ស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប (%) ២០,១ ៤៤ ៦០<br>១៥<br>មណ្ឌលសុខភាពដែលផ្តល់សេវាសុខភាពបន្តពូជ ៣៣ ៤៥ ៧០ | សូចនាករវិស័យសុខាភិបាលនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣) គួរតែទាក់ទងនឹងពិការភាពដូចដែលមានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្ស<br>**<u>គោលដៅ ៤ : កាត់បន្ថយអត្រាស្លាប់របស់ទារក</u>**<br>៤.១ អត្រាស្លាប់ក្រោមអាយុប្រាំឆ្នាំសម្រាប់កុមារពិការ<br>៤.២ អត្រាស្លាប់ជាទារកសម្រាប់ទារកដែលកើតមកពិការ<br>៤.៣ សមាមាត្រកុមារពិការអាយុ១ឆ្នាំរួចផុតពីជម្ងឺកញ្ជ្រិល<br>**<u>គោលដៅ ៥ : លើកកម្ពស់សុខភាពជាមាតា</u>**<br>៥.១ អត្រាស្លាប់ជាម្តាយចំពោះស្ត្រីពិការ<br>៥.២ សមាមាត្រនៃផ្តល់កំណើតក្នុងចំណោមស្ត្រីពិការដលមានជំនួយពីបុគ្គលិកសុខាភិបាលដែលមានជំនាញ<br>៥.៣ អត្រាភាគរយនៃការបង្ការមិនឱ្យមានកូនក្នុងចំណោមស្ត្រីពិការ<br>៥.៤ អត្រាកំណើតនៅវ័យក្មេងក្នុងចំណោមក្មេងស្រីពិការ<br>៥.៥ ការពិនិត្យផ្ទៃពោះ (យ៉ាងហោចណាស់១ដង និងយ៉ាងហោចណាស់៤ដង) សម្រាប់ស្ត្រីពិការដែលមានផ្ទៃពោះ<br>៥.៦ តម្រូវការមិនបានឆ្លើយតបសម្រាប់ផែនការគ្រួសារក្នុងចំណោមស្ត្រីពិការ |

| | | | |
|---|---|---|---|
| | | | **<u>គោលដៅ ៦ : ការលុបបំបាត់ជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺផ្សេងៗ</u>**<br>៦.១ អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមស្ត្រីពិការដែលមានផ្ទៃពោះ អាយុពី ១៥-២៤<br>៦.២ ការបង្កាមិនឱ្យមានកូនក្នុងសរិយាបទដ៏មានគ្រោះថ្នាក់ខ្លាំង ក្នុងចំណោមស្ត្រី និងបុរសពិការ<br>៦.៣ ភាគរយចំនួនពិការអាយុពី ១៥-២៤ដែលមានចំណេះដឹងត្រឹមត្រូវ និងទូលំទូលាយពីជម្ងឺអេដស៍<br>៦.៤ ផលធៀបនៃការចូលរៀនរបស់កុមារកំព្រាពិការ ប្រៀបធៀបកុមារកំព្រាមិនពិការ និងកុមារមិនកំព្រាអាយុពី ១០-១៤ឆ្នាំ<br>៦.៥ សមាមាត្រជនពិការមានផ្ទុកមេរោគអេដស៍ដែលមានលទ្ធភាពប្រើប្រាស់ថ្នាំ ពន្យាអាយុ<br>៦.៦ អត្រាស្លាប់ និងឧប្បត្តិហេតុពាក់ព័ន្ធជម្ងឺគ្រុនចាញ់ក្នុងចំណោមជនពិការ ដោយប្រៀបធៀបជាមួយជនមិនពិការ<br>៦.៧ សមាមាត្រកុមារពិការអាយុក្រោម៥ឆ្នាំដែលដេកក្នុងមុងជ្រលក់ថ្នាំ ដោយធៀបជាមួយកុមារមិនពិការ<br>៦.៨<br>សមាមាត្រកុមារពិការអាយុក្រោម៥ឆ្នាំមានជម្ងឺគ្រុនក្តៅដែលបានប្រើប្រាស់ថ្នាំការពារគ្រុនចាញ់ដ៏ត្រឹមត្រូវ<br>៦.៩ ឧប្បត្តិហេតុអត្រាស្លាប់ ភាគរយពាក់ព័ន្ធជាមួយជម្ងឺគ្រុនឈាមក្នុងចំណោម ជនពិការដោយធៀបជាមួយជនមិនពិការ<br>៦.១០ សមាមាត្រករណីជម្ងឺគ្រុនឈាមកើតមាន |

| | | | |
|---|---|---|---|
| | | | ក្នុងចំណោមជនពិការ និងទទួលបានការព្យាបាលក្រោមវិគ្គព្យាបាលរយៈពេលខ្លីដោយកការអង្កេតផ្ទាល់ |
| ២៩៩ | **តារាងទី ២៦** | បង្កើនល្បឿនកំណើនក្នុងវិស័យឧស្សាហកម្មនិងការងារ<br>៣៧ កំណើនប្រចាំឆ្នាំក្នុងផ្នែកកម្មន្តសាល គិតតាមថ្លៃថេរ (%) ១០,២ ៧,២<br>៣៨៖ ពលកម្មកុមារអាយុ ៥-១៧ឆ្នាំ (%) ២២,៣ ១០,៦ ៨ | សូចនាករវិស័យឧស្សហកម្ម និងការងារនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម (២០០៩-២០១៣) គួរតែទាក់ទងនឹងពិការភាព ដូចដែលមានចែង នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្ស<br>**<u>គោលដៅ ១ : កាត់បន្ថយភាពក្រីក្រ និងភាពអត់ឃ្លាន</u>**<br>១.១ សមាមាត្រជនពិការដែលរកបានក្រោម ១ដុល្លាអាមេរិកក្នុងមួយថ្ងៃ<br>១.២ ផលធៀបគម្លាតភាពក្រីក្ររវាងជនពិការ និងមិនពិការ<br>១.៣ សមាមាត្រជនពិការក្នុងរង្វង់អ្នកក្រីក្របំផុត ក្នុងការប្រើប្រាស់ថ្នាក់ជាតិ<br>១.៤ អត្រាលូតលាស់នៃផលិតផលក្នុងស្រុកសរុប ក្នុងជនពិការមួយនាក់ដែលមាន ការងារធ្វើ<br>១.៥ ការងារចំពោះផលធៀបប្រជាជនសម្រាប់ ជនពិការ<br>១.៦ សមាមាត្រជនពិការដែលមានការងារធ្វើ ដែលរស់នៅក្រោម ១ដុល្លាអាមេរិកក្នុង មួយថ្ងៃ<br>១.៧ សមាមាត្រកម្មករពិការពឹងផ្អែកខ្លួនឯង និងចូលរួមចំណែកពីគ្រួសារក្នុងការងារ ទាំងអស់<br>១.៨ ភាគរយរបស់កុមារពិការស្គមហួសហេតុអាយុក្រោម៥ឆ្នាំ |

| | | | |
|---|---|---|---|
| | | | ១.៩ សមាមាត្រជនពិការដែលទទួលថាមពលទ្រទ្រង់រៀងកាយ ពីអាហារក្រោមកម្រិតអប្បរមា |

* លេខទំព័រសំដៅលើលេខទំព័រដែលមានប្រើនៅក្នុងផយអជបច្ចុប្បន្នកម្ម២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី១**ផយអជ**បច្ចុប្បន្នកម្ម ២០០៩-២០១៣

## សម្រាប់ព័ត៌មានទំនាក់ទំនង:

**គណៈកម្មាធិកាសមាហរណកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**

សមាជិក គណៈកម្មាធិកាសមាហរណកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ : សកម្មភាពស្តីពីពិការភាព និងអភិវឌ្ឍន៍ (ADD) សមាគមពិការភ្នែកកម្ពុជា អង្គការជនពិការកម្ពុជា (ABC) កម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់ (DDP) ក្រុមប្រឹក្សាសកម្មភាពពិការ (DAC) អង្គការជនពិការអន្តរជាតិផ្នែកបារាំង (HIF) និងមជ្ឈមណ្ឌលជាតិនៃជនពិការ (NCDP) ។

ឈ្មោះអង្គការមិនមែនរដ្ឋាភិបាល: HIF, CDPO និង DAC

ឈ្មោះអ្នកទំនាក់ទំនង : លោក អ៊ុង សុភា ប្រធានគំរោង (HIF) លេខទូរស័ព្ទ: (៨៥៥-១១) ៩៧៥ ៨៦៧
អ៊ីម៉ែល: pm-prsp@hicambodia.org
លោក ខាំ ពិសដ្ឋ ប្រធានកម្មវិធី (CDPO) លេខទូរស័ព្ទ: (៨៥៥-១២) ៩៨២ ៨៧៣
អ៊ីម៉ែល: pm@cdpo.org
លោក វ៉ន សំភាស់ នាយករង (DAC) លេខទូរស័ព្ទ: (៨៥៥-១២) ៧០២ ២៧៩
អ៊ីម៉ែល: samphors@dac.org.kh

# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការវិភាជន៍ថវិកាជាតិ

## ១. កថាខ័ណ្ឌទី ៥៦៦ នៃ ផយអជ បច្ចុប្បន្នកម្ម

យើងខ្ញុំសូមស្វាគមន៍ចំពោះការយកចិត្តទុកដាក់ខ្ពស់[1] ដែលបានផ្តល់នៅក្នុងសេចក្តីព្រាងលើកទី១ ផយអជ បច្ចុប្បន្នកម្ម ស្តីពីភាពចាំបាច់ក្នុងការធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនូវការផ្សារភ្ជាប់រវាងផែនការជាតិ និងថវិកាជាតិ (ហិរញ្ញប្បទានដោយ ធនធានក្នុងស្រុក និងធនធានក្រៅប្រទេស)។ ដូចដែលមានបញ្ជាក់យ៉ាងត្រឹមត្រូវនៅក្នុងកថាខ័ណ្ឌ ៥៦៦ ស្តីពីតួនាទីរបស់ក្រុមការងារពិសេស[2] យើងខ្ញុំសុំស្នើអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធបញ្ជាក់ឱ្យកាន់តែច្បាស់បន្ថែម ទៀតអំពីពេលវេលាដែលក្រុមងារពិសេសនឹងបញ្ចប់ការងាររបស់ខ្លួនទៅលើការផ្សារភ្ជាប់ផែនការ និងថវិកាជាតិនៅក្នុងសេចក្តីព្រាងលើកក្រោយនៃ**ផយអជ** បច្ចុប្បន្នកម្ម ដូចដែលមានចែងក្នុងកថាខ័ណ្ឌ ៥៦៦។

## ២. កថាខ័ណ្ឌទី ៥៥២ នៃ ផយអជ បច្ចុប្បន្នកម្ម

ចំពោះការផ្សារភ្ជាប់ផែនការ និងថវិកាជាតិ យើងខ្ញុំសង្កេតឃើញថា ពុំទាន់មានការវិភាជថវិកាមូលធនតាមក្រសួងនៅឡើយទេនៅក្នុងសេចក្តីព្រាង**ផយអជ** បច្ចុប្បន្នកម្ម២០០៩-២០១៣នេះ។ ទោះបីជាការវិភាជថវិកាសម្រាប់ **ផយអជ** បច្ចុប្បន្នកម្មនេះត្រូវបានគូសបញ្ជាក់នៅក្នុងសារាចរណែនាំរបស់រាជរដ្ឋាភិបាលចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (ទំព័រទី ៦ ឧបសម្ព័ន្ធទី ២ ចំនុច ខ.៥) ស្តីពីការរៀបចំ **ផយអជ** បច្ចុប្បន្នកម្មយ៉ាងណាក៏ដោយ ក៏សេចក្តីព្រាង **ផយអជ** បច្ចុប្បន្នកម្មនេះ បានលើកឡើងនៅក្នុងជំពូកទី៥ កថាខ័ណ្ឌទី ៥៥២ ទំព័រទី ១៧៣ ថា "...មានតែក្រសួងមួយចំនួនតូចប៉ុណ្ណោះដែលអាចផ្តល់ ព័តិមានបានទៅតាមតម្រូវការ..." ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សុំស្នើក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់បញ្ចូលនូវសំណើរពីរដូចខាងក្រោម:

- សុំស្នើមេត្តាផ្តល់នូវសេចក្តីការបញ្ជាក់បន្ថែមទៀត នូវអ្វីដែលរាជរដ្ឋាភិបាលអាចធ្វើបាន (ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍) ដើម្បីធានាថា "ទិន្នន័យអំពីធនធានដែលត្រូវការសម្រាប់សម្រេចគោលដៅ នៅក្នុងផែនការអភិវឌ្ឍន៍នេះ និងសម្រាប់វិនិយោគសាធារណៈលើអាទិភាពអភិវឌ្ឍន៍ដែលសំដៅកាត់បន្ថយភាពក្រីក្រពិតជាមាននៅក្នុងជំពូកទី ៥ នៃ **ផយអជ**បច្ចុប្បន្នកម្មនេះ" ។
- យើងខ្ញុំក៏សុំសំណូមពរផងដែរថាជំពូកទី៥ ស្តីពីតម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយគួរយោងទៅលើតម្លៃដែលត្រូវចំណាយដែលមានទាំងវិភាជថវិកាចរន្ត និងមូលធន តាមក្រសួង ស្ថាប័នសាមុីនីមួយៗ

---

[1] ជាពិសេសកថាខ័ណ្ឌលេខ ៣០២, ៣១៥, ៣៨២, ៥៥១, ៥៦៦ នៃសេចក្តីព្រាង**ផយអជ** បច្ចុប្បន្នកម្ម ២០០៩-២០១៣។ នៅក្នុងកថា ១.១០ នៃរបាយការណ៍ ពាក់កណ្តាលអាណត្តិនៃផយអជ ២០០៦-២០១០ បញ្ហានេះក៏ត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់ថាជាបញ្ហាប្រឈមផងដែរ។

[2] ដែលរួមមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមានក្រសួងផែនការជាប្រធានក្រុមការងារ។

ដើម្បីធានានូវសង្គតិភាព និងការផ្សារភ្ជាប់គ្នារវាង **ផយអជ** បច្ចុប្បន្នកម្មនេះទៅនឹងថវិកាជាតិ និងកម្មវិធីវិនិយោគសាធារណៈ។

## ៣. តារាងទី ១៤ នៃ ផយអជ បច្ចុប្បន្នកម្ម

ជាចុងបញ្ចប់ យើងខ្ញុំសូមថ្លែងនូវការកោតសរសើរចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ដូចជាក្រសួងផែនការក្នុង ការបង្កើននូវព័ត៌មានស្តីពីវិភាជន៍ថវិកានៅក្នុងសេចក្តីព្រាង**ផយអជ**បច្ចុប្បន្នកម្មនេះតាមរយៈការរៀបចំឱ្យមានតារាងទី ១៤ ស្តីពី ចំណាយថវិកាចរន្ត ដែលបានស្នើឡើងសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ ២០០៨-២០១៣។ តាមការពិនិត្យផ្ទៀងផ្ទាត់ និងវិភាគតួលេខ ជាពិសេសនិន្នាការវិភាជន៍ថវិកានៅក្នុងតារាងនេះ យើងខ្ញុំសូមស្នើនូវយោបល់មួយចំនួនដូចខាងក្រោម៖

១. ទិន្នន័យចំណាយជាក់ស្តែងនៅក្នុងឆ្នាំ២០០៩ គួរដាក់បញ្ចូលជំនួសនូវទិន្នន័យចំណាយជាក់ស្តែងនៅក្នុងសេចក្តីព្រាង លើកក្រោយ និងចុងក្រោយនៃ **ផយអជ** បច្ចុប្បន្នកម្មនេះ។

២. តួលេខប៉ាន់ស្មានការវិភាជថវិកាជាតិចរន្តឆ្នាំ២០១០ គួរត្រូវបានជំនួសដោយតួលេខវិភាជន៍ជាក់ស្តែង ដែលមាននៅក្នុង ច្បាប់ថវិកាជាតិឆ្នាំ ២០១០។

៣. ចំពោះតួលេខវិភាជន៍នៅក្នុងតារាងទី ១៤ នៃ **ផយអជ** បច្ចុប្បន្នកម្ម ២០០៩-២០១៣៖

- សូមស្នើដាក់បញ្ចូលនូវក្រសួង/ស្ថាប័នចំនួន ៤ នៅក្រោមផ្នែកការចំណាយរដ្ឋបាលទូទៅដែលមិនទាន់ត្រូវបានដាក់បញ្ចូល ឬរំលេចនៅក្នុងតារាងរួមមាន ១) ព្រះបរមរាជវាំង, ២) រដ្ឋសភាជាតិ, ៣) ព្រឹទ្ធសភា និង, ៤) ក្រុមប្រឹក្សាធមនុញ្ញ។
- យើងខ្ញុំសូមគាំទ្រចំពោះការកាត់បន្ថយការវិភាជចំណាយសំរាប់ផ្នែករដ្ឋបាលទូទៅ ដែលយើងឃើញថាមានតែ ក្រសួងយុត្តិធមិមួយទេ ដែលមានការកើនឡើងនូវវិភាជន៍ចំណាយចរន្តនេះ ប៉ុន្តែគេសង្កេតឃើញវិភាជន៍ ចំណាយចរន្តសម្រាប់អាជ្ញាធរសវនកម្មជាតិនៅក្នុងតារាងនេះគួរតែត្រូវបានបង្កើនផងដែរដោយសារអាជ្ញាធរ សវនកម្មជាតិមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកធ្វើឱ្យប្រសើរឡើងថែមទៀតនូវអភិបាលកិច្ចល្អនៅក្នុងកម្ពុជា ម្យ៉ាងទៀតក៏ដោយសារទំហំថវិកាសម្រាប់អាជ្ញាធរនេះនៅមានកំរិតតូចនៅឡើយក្នុងការផ្តល់ លទ្ធភាពឱ្យអាជ្ញាធរសវនកម្មបំពេញតួនាទីពេញលេញក្នុងការធ្វើសវនកម្មលើគ្រប់ស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។

បើធ្វើការប្រៀបធៀបទៅនឹងវិស័យដែលមានសារៈសំខាន់ចាំបាច់សម្រាប់ការកាត់បន្ថយភាពក្រីក្រជាបន្ត និងជម្រុញឱ្យមានកំណើនសេដ្ឋកិច្ចការវិភាជកំណើនថវិកាសម្រាប់វិស័យការពារជាតិ និងសន្តិសុខជាតិមានកំណើនខ្ពស់ពេក។ យើងខ្ញុំសូមស្នើឱ្យមានការបន្ថយកំណើនវិភាជន៍ថវិកាលើវិស័យនេះ ហើយថវិកាបន្ថយនេះគួរត្រូវបានវិភាជបន្ថែមទៀតទៅកាន់ក្រសួង កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួង ធនធានទឹកនិងឧតុនិយម។ ទោះបីជាក្រសួងទាំងបីនេះទទួលបាននូវអាទិភាពមួយចំនួននៅក្នុងការវិភាជថវិកាចរន្តនេះក៏ដោយក្តី ក៏យើងខ្ញុំសូមស្នើឱ្យមានការវិភាជថវិកាបន្ថែមទៀតទៅកាន់ក្រសួងទាំងបីដោយសារទំហំ ថវិកាសម្រាប់ក្រសួងទាំងបីនៅមានកំរិតតិចតួចនៅឡើយ ហើយថវិកាសម្រាប់ក្រសួងទាំងបីនេះត្រូវបំពេញទៅនឹងតម្រូវការដ៏ធំ និងចាំបាច់សំរាប់ការអភិវឌ្ឍន៍តំបន់

ជនបទ (ដែល៩១% នៃប្រជាជនដែលក្រីក្ររស់នៅ តំបន់ជនបទ ហើយ៧០%នៃប្រជាជនកម្ពុជាប្រកបរបរ និងធ្វើការក្នុងវិស័យកសិកម្ម)។

**ព័ត៌មានសម្រាប់ទំនាក់ទំនង៖**

| |
|---|
| វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា |
| លោក ជា គឹមសុង ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍ |
| ទូរស័ព្ទ៖ (៨៥៥)-២៣ ២១៤ ៤២៩ |
| ទូរសារ៖ (៨៥៥-២៣) ២៣ ៩៩៤ ០៦៣ |
| អ៊ីម៉ែល៖ kimsong@ngoforum.org.kh |
| គេហទំព័រ៖ www.ngoforum.org.kh |

## **ការដាក់បញ្ចូលសមិទ្ធផល គោលដៅ និងសកម្មភាពសំខាន់ៗរបស់អាជ្ញាធរសវនកម្មជាតិ**

លេខៈ...............NGOF/DIP

**សូមគោរពជូន**

**ឯកឧត្តម អ៊ុត ឈន**

**អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ**

**<u>កម្មវត្ថុ</u>:** ការដាក់បញ្ចូលសមិទ្ធផល និងគោលដៅ និងសកម្មភាពសំខាន់ៗនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ ២០០៧-២០១១ របស់អាជ្ញាធរសវនកម្មជាតិទៅក្នុង**ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** (ផយអជ) **បច្ចុប្បន្នកម្ម ២០០៩-២០១៣**

តាងនាមឱ្យវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បាននិងកំពុងធ្វើការសម្របស្រួលអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលគ្រប់ វិស័យក្នុងការចូលរួមចំណែកផ្តល់យោបល់ទៅលើផ្នែកដែលពាក់ព័ន្ធតាមវិស័យនៅក្នុងសេចក្តីព្រាងលើកទី១ នៃផែនការយុទ្ធសាស្រ្ត អភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ និងធ្វើការផ្ញើជូននូវយោបល់ដែលមានការសម្របសម្រួលតាមវិស័យទាំងនោះទៅកាន់ ក្រសួងឬស្ថាប័នសាមីរបស់រាជរដ្ឋាភិបាលតាមរយៈយន្តការក្រុមការងារបច្ចេកទេសឬក្រុមការងារទទួលបន្ទុករៀបចំធាតុចូល និងផ្តល់យោបល់លើសេចក្តីព្រាងផយអជ បច្ចុប្បន្នកម្មមុននឹងក្រសួង និង/ឬ ស្ថាប័នទាំងនោះផ្ញើជូន យោបល់របស់ខ្លួនទៅកាន់ក្រសួងផែនការ ដែលជាស្ថាប័នដឹកនាំដំណើរការសម្របសម្រួលការរៀបចំផយអជបច្ចុប្បន្នកម្មនេះត្រឹម កាលបរិច្ឆេទផ្លូវការថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១០។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានទទួលសេចក្តីព្រាងលើកទី១នៃ **ផយអជ** បច្ចុប្បន្នកម្មផ្លូវការពីក្រសួងផែនការទាំងជាភាសាខ្មែរ និងអង់គ្លេស កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៩។ យើងខ្ញុំបានធ្វើការសិក្សានិងវិភាគទៅលើសេចក្តីព្រាងនេះ ហើយពិនិត្យឃើញថាសេចក្តីព្រាងនេះមិនបានលើកឡើងពីតួនាទីដ៏មាន សារៈសំខាន់របស់អាជ្ញាធរសវនកម្ម ជាតិឡើយ ដែលផ្ទុយពី ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០០៦-២០១០ ដែលបានលើកឡើងពីការពង្រឹងតួនាទីរបស់អាជ្ញាធរ សវនកម្មជាតិនៅក្នុងវិស័យ អភិបាលកិច្ចល្អ ក្នុងវាក្យខណ្ឌ ២.១៤ ទំព័រទី១៥ ដែលថា: "រាជរដ្ឋាភិបាលបានពង្រឹងសមត្ថភាពរបស់អាជ្ញាធរសវនកម្មជាតិ និងបានពង្រីកវិសាលភាពនៃការអនុវត្តអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈទៅកាន់គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល..." ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមផ្តល់ការលើកទឹកចិត្តនិងការគាំទ្រដ៏ស្មោះចំពោះអាជ្ញាធរសវនកម្មជាតិក្នុងការលើកឡើងពីលទ្ធផលការងារ តួនាទី និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ដ៏មានសារៈសំខាន់របស់ខ្លួនទៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។ តាមទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ការដាក់បញ្ចូលនូវតួនាទី និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍របស់អាជ្ញាធរសវនកម្មពិតជាមានសារៈសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល។ យើងខ្ញុំយល់ឃើញថា លទ្ធផលល្អប្រសើរ

និងបញ្ហាប្រឈមនានារបស់អាជ្ញាធរនៅក្នុងការចូលរួមចំណែកពង្រឹង អភិបាលកិច្ចល្អ តម្លាភាពនិងធានាដម្រុញគណនេយ្យភាពតាមវិស័យរបស់រាជរដ្ឋាភិបាលគួរត្រូវបានដាក់បញ្ចូលទៅក្នុងផែនការជាតិនេះ ជាពិសេសធាតុផ្សំសំខាន់ពីរខាងក្រោមៈ

១- នៅក្នុងជំពូកទី២ នៃសេចក្តីព្រាងលើកទី១ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ស្តីពី សមិទ្ធផល និងបញ្ហាប្រឈមនានានៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ អាជ្ញាធរសវនកម្មជាតិអាចធ្វើការគូសបញ្ជាក់ពីការបោះផ្សាយជាសាធារណៈនូវរបាយការណ៍សវនកម្មជាតិ ២០០៦ ដែលត្រូវបានផ្សព្វផ្សាយកាលពីខែវិច្ឆិកា ឆ្នាំ ២០០៩

២- នៅក្នុងជំពូកទី៤ នៃសេចក្តីព្រាងនេះ ដែលបរិយាយអំពីអាទិភាពគោលនយោបាយ និងសកម្មភាពនានាមានសកម្មភាព មួយចំនួនដែលសំខាន់ និងគួរត្រូវបានដកស្រង់ចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ២០០៧-២០១១ របស់អាជ្ញាធរ សម្រាប់ដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មនេះ ដោយយោងទៅនឹងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ខាងលើ ចំពោះផែនការ និងសកម្មភាពលម្អិតនីមួយៗ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមសម្តែងនូវស្មារតីធ្វើការរួមគ្នាក្នុងន័យស្ថាបនាជាមួយអាជ្ញាធរសវនកម្មជាតិក៏ដូចជាក្រសួងផែនការដើម្បីធ្វើឱ្យផែនការអភិវឌ្ឍន៍នេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានយន្តការច្បាស់លាស់ សម្រាប់ធានានូវភាពចាំបាច់នៃការបន្តពង្រឹងអភិបាលកិច្ចល្អតាមរយៈការធានាបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានតម្លាភាព និងគណនេយ្យភាពដែលនឹងកាន់តែឆ្លើយតបបានប្រសើរឡើងថែមទៀតទៅនឹងតំរូវការជាក់ស្តែងលើសេវាសាធារ ណៈចាំបាច់សម្រាប់ប្រជាពលរដ្ឋក្រីក្រនិងក្រុមជនងាយរងគ្រោះ។ យើងខ្ញុំត្រៀមខ្លួនជាស្រេចក្នុងការផ្តល់នូវការបំភ្លឺចំពោះយោបល់ដែលបានលើកឡើង ខាងលើ។

សេចក្តីគួរពុំគួរ សូមឯកឧត្តមមេត្តាអភ័យទោស។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញថ្ងៃទី០៥ ខែមករាឆ្នាំ២០១០

នាយកប្រតិបត្តិ

**ឈិត សំអាត**

**សូមជូនភ្ជាប់មកជាមួយៈ**

**- សេចក្តីព្រាងលើកទី១ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ភាសាខ្មែរ និងអង់គ្លេស ១ ច្បាប់**

## ការដាក់បញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

### ការរីកចំរើនក្នុងការបញ្ជ្រាបគ្រោះភ័យនៃគ្រោះមហន្តរាយនៅកម្ពុជាៈ

រាជរដ្ឋាភិបាលកម្ពុជាជាហត្ថាលេខីមួយ ក្នុងចំណោយហត្ថលេខីទាំង ១៦៨ ប្រទេសលើក្របខ័ណ្ឌការងារយូហ្គោ២០០៥-២០១៥ ដែលជាបទដ្ឋានច្បាប់ដ៏រឹងមាំដល់ចំណេះដឹង និងអនុវត្តលើការគ្រប់គ្រងគ្រោះមហន្តរាយនៅជុំវិញពិភពលោក។ សន្និសិទនៅទីក្រុងប៉េកាំងក៏បានបញ្ជាក់ឡើងវិញផងដែរអំពីសកម្មភាពការកាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយនៅតំបន់អាស៊ីដោយបានសម្រេចថាបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីត្រូវរៀបចំ ផែនការសកម្មភាពថ្នាក់ជាតិសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយដើម្បីឱ្យស្របតាមគោលការណ៍របស់ក្របខ័ណ្ឌការងារយូហ្គោ។ គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងក្រសួងផែនការបន្ទាប់មកបានធ្វើការងាររួមគ្នារៀបចំឡើងនូវ "**ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះ ភ័យនៃគ្រោះមហន្តរាយ២០០៨-២០១៣**" ហើយរាជរដ្ឋាភិបាលក៏បានប្តេជ្ញាចិត្តអនុវត្ត និងត្រួតពិនិត្យដំណើរ ការរីកចម្រើនលើវិស័យនេះផងដែរ។

នៅឆ្នាំ២០០២ រាជរដាភិបាលបានបង្កើតគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងយន្តការគ្រប់គ្រងគ្រោះមហន្តរាយ ដែលយន្តការនេះមានរចនាសម្ព័ន្ធចាត់តាំងពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។ ក្រៅពីគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយនៅតាមខេត្តមានគណៈកម្មការជាតិគ្រប់គ្រង គ្រោះមហន្តរាយ ខេត្ត-ក្រុង នៅថ្នាក់ស្រុកមានគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ និងតាមឃុំមានគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់។ល។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានរៀបចំផងដែរនូវព្រះរាជក្រឹត្យ-អនុក្រឹត្យ-និងគោលនយោបាយមួយចំនួន ដើម្បីប្រយុទ្ធកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយឯកសារគោល នយោបាយទាំងនោះរួមមានៈ

- ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, ១៦ កុម្ភៈ ២០០២
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (ថ្នាក់ ជាតិ និងក្រោមជាតិ), ៩ មេសា ២០០២
- ចូលរួមអនុម័តលើក្របខ័ណ្ឌការងារយូហ្គោ ឆ្នាំ២០០៥-២០១៥ [HFA (HYOGO Framework Action)], ២០០៥

- សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន សម្រាប់ការរៀបចំផែនការសកម្មភាពជាតិនៃយុទ្ធសាស្រ្ត សម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ២០០៨-២០០១៣, ២៥ តុលា ២០០៧
- ផែនការសកម្មភាពជាតិនៃយុទ្ធសាស្រ្ត សម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ (SNAP) ២០០៨-២០១៣
- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ( កំពុងធ្វើសេចក្តីព្រាង)

នាពេលចុងក្រោយនេះ មានគ្រោះមហន្តរាយជាច្រើនបានកើនឡើងគួរឱ្យកត់សំគាល់បានជះឥទ្ធិពលជាអវិជ្ជមានដល់ប្រជាពលរដ្ឋជាច្រើននាក់ និងមានការខាតបង់ដ៏ច្រើនសន្ធឹកសន្ធាប់នៅកម្ពុជា[៣] ។ ឧទាហរណ៍ថ្មីៗនេះព្យុះទីហ្វុនកេតសាណាបានបោកបក់មកលើកម្ពុជានាចុងខែកញ្ញា ឆ្នាំ២០០៩ ជាលទ្ធផលមិនគ្រាន់តែធ្វើឱ្យមនុស្សស្លាប់បាត់បង់ជីវិតជាច្រើននាក់ប៉ុណ្ណោះទេ និងថែមទាំងបានបំផាញនូវផលដំណាំសត្វពាហនៈ និងក៏ធ្វើឱ្យមានការខាតបង់ថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់ការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវ ស្ពាន ប្រព័ន្ធទឹកទទួលទាន និងអនាម័យ ។ល ។

## <u>មូលហេតុចំបងៗ នៃការបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ:</u>

ដើម្បីធ្វើឱ្យប្រទេសជាតិចាកផុតពីការខាតបង់ដោយសារគ្រោះមហន្តរាយ និងមានការត្រៀមលក្ខណៈឱ្យ បានប្រសើរដល់ស្ថាប័ននានា និងធនធាន ដែលជាការចាំបាច់ត្រូវបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគ្រប់ជ្រុងទាំងអស់នៃដំណើរការអភិវឌ្ឍន៍ ។ ការបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ វាទៀមទារឱ្យមានភាពច្បាស់លាស់និងម៉ឺងម៉ាត់ខាងគោលនយោបាយដើម្បីធ្វើឱ្យការអនុវត្តអាចសម្រេចបាននៅគ្រប់កម្រិតទាំងអស់ ។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ជាឯកសារគោលដែលចាំបាច់ត្រូវមានការបញ្ជាក់ និងបញ្ជ្រាបនូវការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅគ្រប់វិស័យដែលមានការពាក់ព័ន្ធ ។

---

[3] *ផែនការសកម្មភាពជាតិនៃយុទ្ធសាស្រ្តសម្រាប់កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ២០០៨-២០១៣*

ក្រៅពីការប្តេជ្ញាចិត្តជាសកលលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ដែលកម្ពុជាបានអនុវត្ត មួយទៀតការបញ្ច្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:

- នឹងការពារ ផ្តល់ផលដល់ការកាត់បន្ថយភាពក្រីក្រ
- ត្រូវការទុនវិនិយោគតិចតួច ជាមួយនឹងផលប្រយោជន៍មានកំរិតខ្ពស់
- នាំឱ្យមានស្ថេរភាពសង្គមដ៏រឹងមាំ
- ជាវិធីមួយដើម្បីប្រយុទ្ធនឹងបញ្ហាបំរែបំរួលអាកាសធាតុ
- នាំឱ្យមានផលចំណេញបន្ថែមជាច្រើនសម្រាប់កម្ពុជា ជាពិសេសសូម្បីតែមិនបានរងការខូចខាតដ៏ធំមួយ តែវាបានធ្វើឱ្យមានការតក់ស្លុតជាញឹកញាប់ វាទាមទារឱ្យមានការតស៊ូពីគ្រប់ផ្នែក និងគ្រប់ពេលវេលា ដែលត្រូវចាប់ផ្តើមពីគោលនយោបាយ ។

យោងតាមការពន្យល់ខាងលើ វេទិកាអង្គការមិនមែនរដ្ឋាភិបាល សូមផ្តល់អនុសាសន៍ ដល់រាជរដ្ឋាភិបាលកម្ពុជា គួរធ្វើការពិនិត្យនិងពិចារណាពីបញ្ហាការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ បញ្ជ្រាក់ចូលក្នុងសេចក្តីព្រាងចុងក្រោយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣។

អនុសាសន៍ជាក់លាក់មួយចំនួន ដើម្បីធ្វើការបញ្ជ្រាប រួមមានដូចខាងក្រោម:

- គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយគួរមានតំណាងរបស់ខ្លួន នៅក្នុងក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ បច្ចុប្បន្នកម្ម ដើម្បីជាជំនួយដល់ក្រសួងផែនការលើការងារកាត់បន្ថយគ្រោះភ័យនៃ គ្រោះមហន្តរាយ
- ដូចបញ្ហាយែនឌ័រ និងបញ្ហាឆ្លងវិស័យផ្សេងទៀតដែរ គួរមានការបញ្ជាក់ឱ្យបានច្បាស់អំពី បញ្ហាកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ក្នុងការរៀបចំ អនុវត្ត និងវាយតំលៃគម្រោងនៅគ្រប់ វិស័យពាក់ព័ន្ធ ជាពិសេសវិស័យអប់រំ សុខាភិបាល រដ្ឋបាលមូលដ្ឋាន កសិកម្ម ព្រៃឈើ និងជលផល ធនធានទឹកនិងឧតុនិយម វិស័យពត៌មាន គ្រប់គ្រងដីធ្លី សាធារណៈការ និងដឹកជញ្ជូន ដើម្បីកាត់ បន្ថយការខាតបង់ ដោយសារគ្រោះមហន្តរាយ លើរាល់គម្រោងវិនិយោគឱ្យមានកម្រិតទាប
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គួរបញ្ជាក់ជាពិសេសជាមួយនាយកដ្ឋានឧតុនិយមអំពីការបង្កើតនូវប្រព័ន្ធផ្តល់ពត៌មានមានលក្ខណៈមេត្រីភាព

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គួរគាំទ្រដល់ការបង្កើតនូវតួនាទីសមស្របនៃគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីពង្រឹងតួនាទីសម្របសម្រួលលើការឆ្លើយតបសង្គ្រោះបន្ទាន់ និង កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គួរគាំទ្រគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយលើការកសាងសមត្ថភាពថ្នាក់ជាតិ និងមូលដ្ឋាន តាមរយៈការបែងចែកថវិកាជាតិដល់វិស័យនេះ
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គួរធ្វើតាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ រៀបចំឧបករណ៍ផ្សព្វផ្សាយនិងកសាងសមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់
និងប្រជាពលរដ្ឋតាមសហគមន៍ ដើម្បីពួកគេអាចវិភាគអំពីហានិភ័យ និងកាន់តែមានលទ្ធភាពត្រៀមខ្លួនជាស្រេចដើម្បីការកាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយ
- តាមរយៈក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ ធ្វើឱ្យប្រាកដថាក្រុមប្រឹក្សាឃុំនឹងពិចារណា ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់។ ការដាក់បញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ ឃុំ/សង្កាត់នឹងត្រូវបានផ្តល់អាទិភាពក្នុងផែនការវិនិយោគ។

## សូចនាករមួយចំនួន នៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

យើងខ្ញុំសូមស្នើនូវសូចនាករមួយចំនួន ដើម្បីសម្រួលដល់ការត្រួតពិនិត្យ និងវាយតម្លៃលើវិស័យនេះមាន ដូចខាងក្រោម៖

- មានការបញ្ជ្រាប/ធ្វើសមាហរណកម្មការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុង ផែនការវិនិយោគខេត្ត /ស្រុក/ឃុំ/សង្កាត់
- មានការបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយ ទៅក្នុងកម្មវិធី និងគម្រោងថ្មីៗ
- ធ្វើសមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងកម្មវិធីសិក្សាតាមសាលា
- ប្រព័ន្ធប្រកាសឱ្យដឹងមុនព្រមានពីភាពអាសន្ន នៅតំបន់គ្រោះទឹកជំនន់មានប្រសិទ្ធភាព
- ឃុំ/សង្កាត់ដែលជួបហានិភ័យខ្ពស់ មានសមត្ថភាពយល់ដឹងពីការប្រកាសឱ្យដឹងមុនព្រមានពីភាពអាសន្ន (ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ជំងឺរាតត្បាតដល់មនុស្ស-សត្វ សត្វល្អិតចង្រៃ)

- ក្រសួងកសិកម្មមានសមត្ថភាព អភិវឌ្ឍន៍ដំណាំដែលធុននឹងគ្រោះទឹកជំនន់ និងរាំងស្ងួត
- ធ្វើផែនការត្រៀមបំរុងទុកជាមុន (រួមទាំងផែនការត្រៀមបំរុងទុកជាមុននិងសង្គ្រោះបន្ទាន់) និង ពិនិត្យឡើងវិញប្រចាំឆ្នាំ សម្រាប់អន្តរវិស័យ និងហានិភ័យ នៅថ្នាក់ខេត្តនិងស្រុក
- យន្តការធ្វើផែនការត្រៀមបំរុងទុកជាមុននិងសង្គ្រោះបន្ទាន់ ដ៏មានប្រសិទ្ធភាពនិងសម្រប សម្រួលត្រូវបានបង្កើតឡើងនៅគ្រប់កំរិត
- ស្ថាប័នពាក់ព័ន្ធ តែងតាំងមន្ត្រីជំនាញជាជនបង្គោលសម្រាប់ការងារកាត់បន្ថយគ្រោះភ័យនៃ គ្រោះមហន្តរាយ នៅថ្នាក់ជាតិនិងក្រោមជាតិ
- ក្រុមបច្ចេកទេសនៃគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយទាំងអស់មានការជួបប្រជុំពីរ ដងក្នុងមួយឆ្នាំ ហើយផ្សព្វផ្សាយកំណត់ហេតុប្រជុំទៅដល់គ្រប់ជនបង្គោលតាមស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិនិងខេត្ត
- ភាគរយនៃថវិការជាតិ/ខេត្ត បែងចែកដល់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ សម្រាប់ក្រសួងនិមួយៗ និងសម្រាប់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ
- ភាគរយនៃការចំណាយរបស់រដ្ឋាភិបាលកណ្តាលនិងខេត្ត លើការងារកាត់បន្ថយគ្រោះភ័យនៃ គ្រោះ មហន្តរាយ សម្រាប់ក្រសួងនិមួយៗ និងសម្រាប់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ

## ឯកសារភ្ជាប់មកជាមួយ:

សូមភាប់មកជាមួយនូវ ឯកសារគន្លឹះចំនួន២ ដែលបានរៀបចំឡើងដោយគណៈកម្មការជាតិគ្រប់គ្រង គ្រោះមហន្តរាយមានការចូលរួមពីសំណាក់ក្រសួងពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។ ឯកសារ ទាំងនោះរួមមាន:

១- ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រ សម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ២០០៨-២០១៣។

ឯកសារនេះជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្ត រាយ និងក្រសួងផែនការ ធ្វើនៅឆ្នាំ២០០៨។

២- គំនិតផ្តួចផ្តើមពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ដើម្បីដាក់បញ្ជ្រាបក្នុងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣។ ជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងគណៈ

កម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ធ្វើនៅខែកញ្ញា ឆ្នាំ ២០០៩។

**ព័ត៌មានសម្រាប់ទំនាក់ទំនង:**


អុកហ្វាម

លោក ជច វើរ៍ ប្រធានកម្មវិធីមនុស្ស

ទូរស័ព្ទ: (៨៥៥)-១២ ៩៩៧ ២៧៨

អ៊ីមែល: gwere@oxfam.org.kh

## វិស័យអប់រំ

| លេខទំព័រ* | លេខកថាខ័ណ្ឌ** | អត្ថបទដើមដកស្រង់ពីសេចក្តីព្រាងលើកទី១ **ផយអជ** បច្ចុប្បន្នកម្ម ២០០៩-២០១៣ | យោបល់អង្គការមិនមែនរដ្ឋាភិបាល ឬការស្នើឱ្យមានការកែប្រែ |
|---|---|---|---|
| ៩៥ | ២០២ | ការកាត់បន្ថយឧបសគ្គចំណាយរបស់មាតាបិតាសិស្ស | យើងខ្ញុំសូមស្នើ រាជរដ្ឋាភិបាល មេត្តាផ្តល់នូវសម្ភារៈសិក្សាដល់សិក្សានុសិស្ស និងជួយដល់គ្រួសារក្រីក្រ និងងាយនឹងទទួលរងគ្រោះថ្នាក់ តាមរយៈបន្តការផ្តល់អាហារូបករណ៍សម្រាប់សិស្សានុសិស្សទាំងនោះ ។ |
| ៩៦ | ២០៣ | លុបបំបាត់នូវការបង់លុយក្រៅផ្លូវការ | យើងខ្ញុំសូមស្នើរាជរដ្ឋាភិបាល បង្កើនប្រាក់ខែគ្រូបង្រៀនដល់កម្រិតមួយដែលពួកគាត់អាចចិញ្ចឹមជីវិតបាន ហើយការពង្រឹងវិន័យនឹងរឹតបន្តឹងចំពោះគ្រូបង្រៀនណាដែលយកកំរៃសាលាក្រៅផ្លូវការអាចធ្វើបាននៅជំហានបន្ទាប់ ។ |
| ៩៧ | ២០៣ | គ្រូបង្រៀនចំនួន ៥០០០នាក់នឹងត្រូវជ្រើសរើសប្រចាំឆ្នាំ | រាជរដ្ឋាភិបាលប្តេជ្ញាជ្រើសរើសគ្រូបង្រៀនចំនួន ៥០០០នាក់ប្រចាំឆ្នាំ ។ |
| ២៥៨ | ៥១៧ | ការលើកទឹកចិត្តចំពោះគ្រូបង្រៀន | សូមស្នើ រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដល់គ្រូបង្រៀនដែលរួមមានៈ ប្រាក់លើកទឹកចិត្ត ការសរសើរជាពាកពេចន៍ ការបណ្តុះបណ្តាល និងការតម្លើងឋានៈទៅតាមលទ្ធផលការងារ ។ |
| ២៥៨ | ៥១៧ | ការផ្គត់ផ្គង់ថវិកាដំណើរការគ្រឹះស្ថានសិក្សា | សូមស្នើ បង្កើនថវិកាដំណើរការគ្រឹះស្ថានសិក្សាដើម្បីបំពេញតំរូវការរបស់សាលា និង កែសម្រួលនិតិវិធីដំណើរវៀបចំសំណើ និងរបាយការន៍ ។ |

* លេខទំព័រសំដៅលើលេខទំព័រនៅក្នុង **ផយអជ** បច្ចុប្បន្នកម្ម ២០០៩-២០១៣

** លេខកថាខ័ណ្ឌសំដៅលើលេខកថាខ័ណ្ឌនៃសេចក្តីព្រាងលើកទី១ **ផយអជ** បច្ចុប្បន្នកម្ម ២០០៩-២០១៣

សម្រាប់ព័ត៌មានទំនាក់ទំនងៈ


ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ (NEP)

លោក អ៊ុន សិរីទ្ធី នាយកប្រតិបត្តិ

លេខទូរស័ព្ទៈ ០២៣ ២២៤ ៧៧៤

អ៊ីម៉ែលៈ info@nepcambodia.org or dir@nepcambodia.org; គេហទំព័រៈ www.nepcambodia.org